ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- គម្រោងស្តីពីការដំឡើងពាក្យស្លោកតាមសាលារៀន
- សាក្សី! ទីនេះមិនមែនជាមន្ទីរស-២១ទេ!

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៩៩ ខែកក្កដា ឆ្នាំ២០១៦

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៩៩ ខែកក្កដា ឆ្នាំ២០១៦

## មាតិកា


◆ គម្រោងស្តីពីការដំឡើងពាក្យស្លោកតាមសាលារៀន ............................១

**ផ្នែកឯកសារ**

◆ ទិត ឈន់ អតីតលេខាស្រុកដាំក្បាន្ត ...............................................២

◆ សម្ព័ន្ធយុវកកជាដៃស្តាំរបស់បក្ស .....................................................៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ពីយោធាខ្មែរក្រហមមកជាប្រជាជនសាមញ្ញ ....................................១៦

◆ អតីតអនុប្រធានភ័ស្តុភារតំបន់៤១ សុន កាន.................................១៧

◆ អតីតកងការពារ និងអ្នកបើកឡានឲ្យលេខាតំបន់៤១ .........................១៩

◆ យក់ ង៉ូវ ប្រធានមន្ទីរសន្តិសុខតំបន់៤១ ភូមិភាគកណ្តាល ................២២

◆ រី ញ៉ៅរ អតីតកងការពារតំបន់៤១ ភូមិភាគកណ្តាល ........................២៤

◆ឌុប ចាន់ថា អតីតនីរសារគណៈតំបន់២ ភូមិភាគពាយ័ព្យ ...................២៦

◆វេទិកាថ្នាក់រៀន ស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ ................២៨

◆ ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំ បាលី ..........................៣៦

◆ អាថ៌កំបាំងរបស់ ប៉ុល ពត.......................................................៤២

**ផ្នែកច្បាប់**

◆ “សាក្សី! ទីនេះមិនមែនជាមន្ទីរស-២១ទេ!” ..................................៤៧

**វេទិកាពិភាក្សាសាធារណៈ**

◆ ការឈឺចាប់ពីអតីតកាលមិនគួរប្រៀបធៀបគ្នា ...............................៥២

◆ ការសម្ពោធពាក្យស្លោកស្តីអំពីការអប់រំអំពើប្រល័យ .........................៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ រសាត់តាមខ្យល់ .....................................................................៥៦





## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩


រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


***ស្នេរលេខនេះ*** ៖ កែវ សុភី, មាស ប៊ុនថាន, សុខ វណ្ណៈ, ស៊ាង ចិន្តា, រី លក្ខិណា, ដេង ពង្សរ៉ាស៊ី, អាណាម៉េ វីសវ៉ាណាថាន, អេង កុកថាយ, ទេព ម៉េងឃាន, អាលីស មើហ្គើរ, ស្ទីវិន ចាង, ស្ទីវិន វូ, ប៉ុក ប៊ុនសូម៉ាដ ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ ទាវ សារៈមុនិន្ទ ***អ្នកបកប្រែ*** ៖ សុភ័ក្ត្រ ភាណា ***និពន្ធនាយកទូទៅ*** ៖ ឆាំង យុ និង ញាណ សុជាតិ ***ជំនួយការនិពន្ធនាយក*** ៖ សោម ប៊ុនថន ***ក្រាហ្វិកកុំព្យូទ័រ*** ៖ សោម ប៊ុនថន ***គ្រប់គ្រងការចែកផ្សាយ*** ៖ ឆេង វើង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# គម្រោងស្តីពីការដំឡើងពាក្យស្លោកតាមសាលារៀន

វិទ្យាស្ថានស្លឹករឹតដែលជាមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍កំពុងរៃអង្គាសថវិកាចំនួន១ម៉ឺនដុល្លារសហរដ្ឋអាមេរិក ដើម្បីយកមកដំឡើងពាក្យស្លោកចំនួនដប់កន្លែងបន្ថែមទៀតនៅតាមវិទ្យាល័យចំនួនដប់ក្នុងខេត្តមួយចំនួន ក្នុងរយៈពេលពីរឆ្នាំខាងមុខនេះ ។ ពាក្យស្លោកនីមួយៗមានចំនួនពីរប្រយោគគឺ ៖ ១) និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឲ្យអត់ឱន អធ្យាស្រ័យគ្នា និង២) រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា គ្រោងរៀបចំដំឡើងផ្ទាំងពាក្យស្លោកស្តីពីការប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នៅគ្រប់វិទ្យាល័យទាំងអស់ទូទាំងប្រទេសនាពេលអនាគត ក្នុងន័យអប់រំ និងរម្លឹកពីការចងចាំពីរបបខ្មែរក្រហម និងដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឲ្យកើតឡើងជាថ្មីម្តងទៀត ។ ជាមួយគ្នានេះដែរ ពាក្យស្លោកនេះមានអត្ថន័យគ្រប់គ្រាន់ក្នុងការជំរុញ និងលើកទឹកចិត្តដល់សិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយឲ្យនិយាយរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមជាមួយឪពុកម្តាយ ជីដូនជីតា និងបងប្អូនរបស់ខ្លួនដើម្បីស្វែងយល់បន្ថែមពីរបបនេះ ក្នុងន័យលើកកម្ពស់ការយល់ដឹងឲ្យកាន់តែទូលំទូលាយថែមទៀត ។ ម្យ៉ាងវិញទៀត សិស្សានុសិស្សអាចរៀនសូត្រពីការអត់ឱន អធ្យាស្រ័យគ្នា ផ្សះផ្សាគ្នា ដើម្បីបញ្ចប់ការរើសអើងរវាងជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម និងដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅលើពិភពលោកទាំងមូល ។




ពិធីសម្ពោធពាក្យស្លោកនិយាយពីរបបខ្មែរក្រហម នៅវិទ្យាល័យព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ

ថវិកាដែលបានមកពីការបរិច្ចាគរបស់សប្បុរសជននឹងយកទៅប្រើប្រាស់ដើម្បីឆ្លាក់ពាក្យស្លោកបន្ថែមនៅលើថ្មម៉ាប ឬបន្ទះលោហៈធាតុ និងដំឡើងនៅតាមវិទ្យាល័យចំនួនដប់ដូចជា វិទ្យាល័យអូរសំព័រ (ខេត្តបន្ទាយមានជ័យ) វិទ្យាល័យកំរៀង វិទ្យាល័យសំពៅលូន និងវិទ្យាល័យសំឡូត (ខេត្តបាត់ដំបង) វិទ្យាល័យភ្នំស្រួច (ខេត្តកំពង់ស្ពឺ) វិទ្យាល័យកោះស្លា (ខេត្តកំពត) វិទ្យាល័យចម្ការដូង (ខេត្តកែប) វិទ្យាល័យវាលវែង (ខេត្តពោធិ៍សាត់) វិទ្យាល័យចុងកាល់ និងវិទ្យាល័យត្រពាំងប្រាសាទ (ខេត្តឧត្តរមានជ័យ) ។

ក្រោយពីដំឡើងរួច ពិធីសម្ពោធជាផ្លូវការនឹងត្រូវប្រារព្ធឡើងដោយមានការចូលរួមពីសំណាក់មន្ត្រីជាន់ខ្ពស់របស់ក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ។

សូមជម្រាបថា ចាប់តាំងពីឆ្នាំ២០១០មក មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានដំឡើងពាក្យស្លោកចំនួន១៩ផ្ទាំងរួចហើយ នៅវិទ្យាល័យចំនួន១៩ នៅទូទាំងប្រទេស ។ ក្នុងពិធីសម្ពោធពាក្យស្លោកនីមួយៗ សិស្សានុសិស្សបានចូលរួមវេទិកាពិភាក្សា និងសំណួរចម្លើយស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងទទួលបានឯកសារមួយចំនួន ដូចជាសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងទស្សនាវដ្តីស្វែងរកការពិត ។

សប្បុរសជនអាចបរិច្ចាគថវិកាសម្រាប់គម្រោងដំឡើងពាក្យស្លោកតាមសាលារៀននេះតាមរយៈគេហទំព័រខាងក្រោម ។ រាល់សំណួរផ្សេងៗ សូមទាក់ទងមកវិទ្យាស្ថានស្លឹករឹត តាមរយៈទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ឬ គេហទំព័រ *www.generosity.com/memorial-fundraising/genocide-education-memorial-project-cambodia* ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ទិត ឈន់ អតីតលេខាស្រុកជាំក្សាន្ត

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J ០០៨២៩*

ឈ្មោះ ទិត ឈន់ ហៅ យ៉ាត អាយុ៤២ ឆ្នាំ សញ្ជាតិខ្មែរ កើតនៅភូមិខ្វាង ឃុំបាក់ក្តោង ស្រុករវៀង តំបន់ព្រះវិហារ សព្វថ្ងៃធ្វើលេខាស្រុកជាំក្សាន្ត ។ ប្រពន្ធឈ្មោះ វណ្ណ សាវេន មានកូន៧នាក់ ប្រុស៥នាក់ ស្រី២នាក់ ។ កូនប្រុសបងឈ្មោះ យ៉ាត ឈឿន ហៅ សំរេច អង្គការបញ្ជូនទៅឧត្តរមានជ័យ (មិនដឹងនៅខាងណាទេ) ។ ឪពុកឈ្មោះ សូ ទិត (ស្លាប់) , ម្តាយឈ្មោះ សោម រដ្ឋ (រស់) ប្រកបរបរធ្វើស្រែនៅភូមិកំណើត ។

ទិត ឈន់មានបងប្អូនបង្កើត៣នាក់ (ប្រុស១ ស្រី២នាក់) ។ ឈ្មោះ ទិត ហ៊ុន បងស្រី មានប្តី សព្វថ្ងៃនៅភូមិកំណើត ឈ្មោះ ទិត ឈន់ ហៅ យ៉ាត ប្រុស ត្រូវបានអង្គការចាប់ខ្លួន, ឈ្មោះ ទិត ហឿង ប្អូនស្រី សព្វថ្ងៃនៅភូមិកំណើត ។ ឈន់ មានអាយុ១៥ឆ្នាំបានទៅនៅវត្តខ្វាង ឃុំបាក់ក្តោង ហើយបួសបាន៥ឆ្នាំទើបសឹកវិញ ។ បន្ទាប់ពីសឹក ឈន់ នៅរកស៊ីធ្វើស្រែជាមួយឪពុកម្តាយ នៅភូមិកំណើតរហូតដល់ឆ្នាំ១៩៧៥ ទើបមានប្រពន្ធ ។ ក្រោយពីរៀបការរួច ឈន់ នៅរកស៊ីធ្វើស្រែជាមួយគ្រួសារនៅភូមិកំណើតដដែល ។

ឆ្នាំ១៩៧០ ឈន់ ចូលធ្វើបដិវត្តន៍នៅភូមិដូង នៅក្នុងក្រុមរបស់ អាវ៉ុធ ។ នៅខែកញ្ញា ឆ្នាំ១៩៧២ ឈន់មកធ្វើជាប្រធានពាណិជ្ជកម្មឃុំបាក់ក្តោង ។ នៅពេល ឈន់ នៅទទួលពាណិជ្ជឃុំ ឈ្មោះ អាន់ និង ហ៊្វា បានហៅបក្ខពួក ឈន់ ដែលមានចំនួន៥នាក់ ទៅបញ្ចូលជាបក្សតែមួយ ការបញ្ចូលនេះគឺជាវិធីស្របច្បាប់មួយ ។ ពេលធ្វើពិធីបញ្ចូលបក្ស គឺ អាន់ និង ហ៊្វា យកទង់របស់បក្សកុម្មុយនីស្តកម្ពុជាមកដាក់ចំពីមុខ ហើយនាំគ្នាគោរព ដែលខ្លឹមសារនិយាយអំពីបក្សពលករកម្ពុជា ។ នៅពេលបញ្ចូលនោះ អាន់ បានខ្ទេសនាមថា ការបញ្ចូលមិត្តយើងទាំងអស់នេះ មិនមែនចូលបក្សកុម្មុយនីស្តកម្ពុជាទេ យើងចូលជាបក្សពលករកម្ពុជា បក្សពលករយើងនេះ ជាបក្សមួយស្របច្បាប់ ដែលធ្វើបដិវត្តន៍នៅលើសកលលោក ដូច្នេះយើងចូលបក្សពលករនេះ ជាបក្សរបស់យើង នៅកម្ពុជាយើង គ្មានបក្សណាក្រៅពីបក្សយើងឡើយ ហេតុនេះហើយ យើងទាំងអស់គ្នាត្រូវស្មោះត្រង់ និងបក្សពលករកម្ពុជាយើង ជាបក្សស្របច្បាប់តែមួយនៅលើសកលលោក ។ ឈ្មោះ ហង់ បានលើកឡើងថានៅពេលនេះយើងត្រូវដើរតាមបក្សកុម្មុយនីស្តកម្ពុជាសិន ម្យ៉ាងមកពីបក្សយើងមិនបាននៅក្នុងប្រទេស គឺនៅក្រៅប្រទេស ។ យើងមិនចូលមកទេ តែយើងត្រូវធ្វើស្របច្បាប់តាមបក្សកុម្មុយនីស្តកម្ពុជា ដើម្បីកុំឲ្យគេដឹងពីផែនការរបស់យើង ដែលជាយុទ្ធវិធីទៅថ្ងៃខាងមុខទៀត ។

ឆ្នាំ១៩៧៣ សភាពការណ៍នៅក្នុងប្រទេសយើងមានការប្រែប្រួលហើយ ព្រោះនៅពេលនេះប្រទេសវៀតណាមមកចរចាឯកម្ពុជាបានបដិសេធ ។ ដូច្នេះកងទ័ពវៀតណាមដែលជារៀមច្បងរបស់យើងក៏ត្រូវដកចេញពីកម្ពុជាយើងដែរ ហេតុនេះឃើញថាសភាពការណ៍នេះ មិនអំណោយផលដល់យើងទេ ដោយសារកងទ័ពវៀតណាមចេញទៅប្រទេសគេ ពីព្រោះមកពីបក្សកុម្មុយនីស្តកម្ពុជាដេញឲ្យគេចេញ មកពីបក្សខ្វាចវៀតណាមដណ្តើមរដ្ឋអំណាច ។ ដូច្នេះបក្សកុម្មុយនីស្តកម្ពុជាប៉ាន់ស្មាន ថាយើងទាំងអស់គ្នាជាកម្លាំងរបស់បក្ស ពីព្រោះយើងធ្វើស្របច្បាប់របស់បក្ស ។ យើងចង់បញ្ជាក់ជូនសមាជិកទាំងអស់កុំឲ្យភាន់ច្រឡំ យើងត្រូវដើរឲ្យទាន់សភាពការណ៍ ឲ្យទាន់បដិវត្តន៍ យើងត្រូវប្រមូលកម្លាំងឲ្យបានច្រើន ។

ដល់ខែតុលា ឆ្នាំ១៩៧៤ ឈ្មោះ ហង់ និង អាន់ បានចាត់តាំងឲ្យ ឈន់ ធ្វើជាអនុប្រធានស្រុកត្បែងមានជ័យ និងទទួលខុសត្រូវឃុំមួយឈ្មោះឃុំឈានមុខ រហូតដល់ខែកក្កដា ឆ្នាំ១៩៧៥ ឈ្មោះ ហង់ បានចាត់តាំងឲ្យ ឈន់ ធ្វើជាលេខាស្រុកជាំក្សាន្ត រហូតដល់សព្វថ្ងៃ ។

ឆ្នាំ១៩៧៥ មានធ្វើពិធីសន្និបាតមួយ នៅខាងក្នុងតំបន់ ១០៣ ព្រះវិហារ ដោយមានគណៈស្រុកគ្រប់ស្រុក និងក្រសួង

មន្ទីរខ្លះ ផ្នែកយោធាខ្លះក៏ចូលរួមពិធីនេះដែរ ការប្រជុំនេះមានលក្ខណៈជាក្រុម សន្និបាតនេះ ហង់ បានលើកឡើងថា ឥឡូវយើងទាំងអស់គ្នា ត្រូវវាយពួកក្បត់ លន់ នល់ ឲ្យឈ្នះនៅឆ្នាំ១៩៧៥ ពេលយើងវាយពួកក្បត់ លន់ នល់ ឈ្នះហើយ យើងក៏ដណ្ដើមរដ្ឋអំណាចពីបក្សកុម្មុយនីស្តកម្ពុជាដែរ ចំណែកនៅវៀតណាមក៏គេវាយខ្លាំងដែរ ។ បើវៀតណាមវាយឈ្នះពួកអាធិរាជីហើយ គឺគេមកជួយវាយយើងដែរ ដើម្បីឲ្យចប់សង្គ្រាមទាំងអស់គ្នា ។ យើងវាយរំលំបក្សកុម្មុយនីស្តកម្ពុជាស្របនឹងទិសរបស់បក្ស ដូច្នេះបក្សមិនដឹងថាយើងវាយរំលំវានៅពេលណាទេ ។ បក្សទុកចិត្តយើង ថាយើងជនកុម្មុយនីស្តកម្ពុជាជាមួយនឹងវា ។ យើងមិនចរចាជាមួយបក្សកុម្មុយនីស្តកម្ពុជាដាច់ខាត យើងនៅតែប្រឆាំង ពីព្រោះបក្សកុម្មុយនីស្តកម្ពុជា នឹងមិនចូលជាមួយបក្សពលករកម្ពុជាយើង និងបក្សឥណ្ឌូចិនរបស់យើងទេ ។ ដូច្នេះ តាមស្រុកត្រូវប្រមូលយកសម្ភារមកទុកនៅតាមតំបន់ ពីព្រោះមន្ទីរតំបន់នៅជិត ងាយស្រួលក្នុងការដឹកជញ្ជូន ។ យើងទាំងអស់ត្រូវប្រមូលសម្ភារផ្សេងៗទៀតសម្រាប់ធ្វើសង្គ្រាម រួមទាំង គោ-ក្របី ជាដើម ។

ឆ្នាំ១៩៧៧ ក្រោយប្រជុំចប់ ឈន់ បានចុះតាមមូលដ្ឋានរបស់ខ្លួនវិញ និងបានធ្វើសកម្មភាព ដោយដកយកស្រូវពីប្រជាជនយកមកដាក់នៅមន្ទីរតំបន់ ដោយបំភាន់មតិប្រជាជនថា អង្គការឲ្យដកស្រូវដើម្បីឧបត្ថម្ភរដ្ឋ និងដកគោពីប្រជាជនឲ្យបានច្រើន ហើយយកមកប្រគល់ឲ្យឈ្មោះ ធិន ជាអ្នកទទួលខុសត្រូវ ។ ឈន់ ផ្ទាល់បានខិតខំខ្នះខ្នែងជាងគេ ព្រោះយល់ឃើញថា ផែនការនេះបានសម្រេច និងបានឡើងតួនាទីថែមទៀត ។ ឈន់ ខ្នះខ្នែងក្នុងការប្រមូលស្បៀងអាហារទុកត្រៀមលក្ខណៈរបស់ខ្លួន និងបក្ខពួកខ្លួន ហេតុនេះហើយបានជាប្រជាជនអត់បាយ ។ ចំណែកសម្ភារផ្សេងៗទៀត ឈន់ មិនចែកជូនប្រជាជនប្រើទេ ដាក់ស្ដែងដូចជាថ្នាំពេទ្យសុខចិត្តទុកឲ្យខូចចោល ។

ចុងឆ្នាំ១៩៧៧ បក្ខពួក ឈន់ មិនបាន ធ្វើសកម្មភាពអ្វីទេ គឺសម្ងំលាក់ខ្លួនជាមួយបដិវត្តន៍ រង់ចាំមើលសភាពការណ៍ជាបន្តទៅទៀត ។ ឈន់ បានបញ្ជាក់ថា គាត់នៅពេលនោះគឺមិនបានធ្វើសកម្មភាពអ្វីទេ ។ បន្ទាប់មក ដោយសារឃើញអង្គការចាប់បក្ខពួករបស់ខ្លួនអស់មួយចំនួន ពេលនោះ ឈន់ ក៏បានរត់ទៅរកអ្នកដែលនៅសេសសល់ដែលធ្លាប់បានចូលរួមផែនការប្រឆាំងនឹងបដិវត្តន៍ ក្នុងគោលបំណងប្រមូលកម្លាំងមេដឹកនាំនៅតាមស្រុក ដើម្បីប្រឆាំងនឹងអង្គការបដិវត្តន៍វិញ ។ បើប្រឆាំងនឹងបដិវត្តន៍មិនឈ្នះទេគឺនាំបក្ខពួកទាំងអស់រត់ទៅសៀមដើម្បីទៅ ទាក់ទងជាមួយ អ៊ិន តាំ ។ បើទាក់ទងជាមួយ អ៊ិន តាំ បានហើយ គឺនាំកម្លាំងរបស់ អ៊ិន តាំ មកវាយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីដណ្ដើមអំណាចពីបក្សកុម្មុយនីស្តកម្ពុជាវិញ ។ ប៉ុន្តែនៅពេល ឈន់ រត់គេចខ្លួន ក៏ជួបនឹងប្រជាជនកំពុងដាំដំណាំនៅចម្ការ ពេលនោះប្រជាជនឃើញ ឈន់ ក៏ចាប់ ឈន់ យកមកប្រគល់ឲ្យមន្ទីរឃុំឃាំង ។

**កែវ សុភី**



# សម្ព័ន្ធយុវជន ជាដៃស្តាំរបស់បក្ស

*(ដកស្រង់ចេញឯកសារយុវជន និងយុវនារីបដិវត្តន៍លេខពិសេសខែសីហា-កញ្ញា ១៩៧៤ D២១៣៨០)*

នៅគ្រប់ប្រទេសលើសកលលោក គេតែងចាត់ទុកយុវជន យុវនារី ជាអនាគតរបស់ប្រទេសជាតិ ។ បើប្រទេសណាមានយុវជន យុវនារី មានការភ្ញាក់រលឹកនយោបាយខ្ពស់ មានគោលជំហរសតិអារម្មណ៍ជាតិរឹងប៉ឹង មានកម្លាំងពលំមាំទាំ និងមានសីលធម៌ថ្លៃថ្នូរស្អាតស្អំ ប្រទេសនោះនឹងមានជំហររឹងប៉ឹងនៅលើឆាកអន្តរជាតិ មានកម្លាំងខ្លាំងពូកែ អាចវាយឈ្នះសត្រូវឈ្លានពានបានទាំងអស់ ហើយពិតជាមានអនាគតរុងរឿង ខ្លាំងពូកែ សម្បូរសប្បាយ ។ ដូច្នេះហើយ បានជាចក្រពត្តិ ពេលវាឈ្លានពានបានប្រទេសណាហើយ ទោតាមរូបភាពអាណានិគមចាស់ក្តី ថ្មីក្តី វាខំប្រើគ្រប់មធ្យោបាយ ដើម្បីក្តាប់យុវជនយុវនារី តាមរូបភាព និងតាមវិធីផ្សេងៗ ។ មានការពន្លក់បំពុលឲ្យយុវជន យុវនារី ពុករលួយ ពាលាអាវាសែ លង់ខ្លួនទៅក្នុងអំពើអបាយមុខផ្សេងៗ ការឃោសនាអប់រំ បំពាក់បំប៉នឲ្យយុវជន យុវនារីយើងនូវវប្បធម៌ចក្រពត្តិពុករលួយនូវលោកទស្សនៈ និងមនោគមវិជ្ជានៃវណ្ណៈជិះជាន់ជាដើម ។ ឆ្លងតាមមធ្យោបាយទាំងនេះ ចក្រពត្តិរួមជាមួយវណ្ណៈកាន់អំណាចដែលតំណាងឲ្យសក្តិភូមិ នាយទុនប្រតិកិរិយាផុតលេខនៅក្នុងប្រទេស វាប្រែកាឡៃយុវជន យុវនារីយើងឲ្យទៅជាឧបករណ៍ដាច់ថ្លៃរបស់ពួកវា ក្នុងការការពារ អំពើឈ្លានពាន ជិះជាន់របស់ពួកវា ការពាររដ្ឋអំណាចហ្វាស៊ីស ក្បត់ជាតិ ក្បត់ប្រជាជនរបស់ពួកវា ឲ្យរស់នៅបានយូរអង្វែងតទៅ ។ ដូច្នេះ វាប្រែកាឡៃយុវជន យុវនារីយើង ឲ្យទៅជាឧបករណ៍ផ្តាច់ការរបស់ពួកវា សម្រាប់ជិះជាន់ កាប់សម្លាប់ ឆក់ប្លន់ប្រជាជាតិ និងប្រជាជនឯងទៅវិញ ។ បើចក្រពត្តិវាក្តាប់យុវជន យុវនារី នៅប្រទេសនោះបានយ៉ាងនេះហើយ វានឹងអាចរក្សានឹមអាណានិគមទោះចាស់ក្តី ថ្មីក្តី ទៅលើប្រទេសជាតិ និងប្រជាជននោះ បានដោយស្រួល និង



កងយុវជន និងយុវនារីបដិវត្តន៍ ថតនៅលើភ្នំគូលែន ខេត្តសៀមរាប

យូរអង្វែងតទៅ ។

## ១) ឧបាយកលចក្រពត្តិ ចំពោះយុវជនយុវនារីកម្ពុជាយើង

នៅប្រទេសកម្ពុជាយើង កាលពីជំនាន់អាណានិគមបារាំងក៏ចក្រពត្តិបារាំងបានប្រើវិធីខាងលើ ដើម្បីក្តាប់យុវជន យុវនារីយើង ហើយ រក្សានឹមត្រួតត្រាហ្វូស៊ីសវា នៅកម្ពុជាបានក្នុងរយៈពេលអស់ជិតមួយសតវត្ស (១០០ឆ្នាំ) ។ បច្ចុប្បន្ននេះ ដើម្បីដិះជាន់ឈ្លានពានប្រទេសជាតិ និងប្រជាជនកម្ពុជា ឲ្យបានយូរអង្វែងតទៅ ចក្រពត្តិអាមេរិក បាននឹងកំពុងប្រើវិធី និងមធ្យោបាយដ៏លាមកដូចតែចក្រពត្តិឯទៀតៗដែរ ដើម្បីក្តាប់យុវជនយុវនារីយើងសម្រាប់ធ្វើជាប្រភពផ្តល់កម្លាំងឲ្យវាយកទៅវេងគ្រាប់រំសេវ ស្ពាប់ការពារក្បាល ពួកអាក្បត់ លន់ នល់, សេរីមតៈ, សឺង ង៉ុកថាញ់, អ៊ិន តាំ, ចេង ហេង, ឡុង បូរ៉េត, សុស្តែន នៅភ្នំពេញ ។ នៅក្នុងទីក្រុងភ្នំពេញ និងក្នុងតំបន់ខ្មាំងកាន់កាប់បណ្តោះអាសន្នមួយក្រវេចតូច សព្វថ្ងៃនេះ ចក្រពត្តិអាមេរិក វាបានខិតខំបញ្ចូលវប្បធម៌ពុករលួយ យូកូងកាប់ចាក់ម នោគមវិជ្ជាចក្រពត្តិ ជិះជាន់ឆក់ប្លន់ និងសង្គមកិច្ចពុលរលួយពាលាអាវ៉ាសែគ្រប់ប្រភេទមកពង្រក់បំពុលប្រជាជនពិសេសយុវជនយុវនារីយើង ឲ្យភ្លើតភ្លើន ហ៊ឺហា ពុករលួយ ពាលាអាវ៉ាសែ រត់តាមអារ្យធម៌ចក្រពត្តិ ភ្លេចអស់នូវគោលជំហរជាតិ និងប្រពៃណី ថ្លៃថ្នូរស្អាតស្អំរបស់ជាតិខ្លួន ។ តាមរយៈនេះ ចក្រពត្តិអាមេរិក វាធ្វើឲ្យសាបរលាបអស់ រហូតដល់រលំដួលទាំងស្រុងនូវគោលជំហរស្នេហាជាតិ គោលជំហរវណ្ណៈ និងតស៊ូវណ្ណៈរបស់ប្រជាជន និងយុវជនយុវនារីយើង ។ ដូច្នេះហើយ បានជានៅទីក្រុងភ្នំពេញ និងក្នុងតំបន់ខ្មាំងកាន់កាប់បណ្តោះអាសន្នសព្វថ្ងៃមានយុវជន យុវនារីមួយចំនួន បានធ្លាក់ខ្លួនទៅជាអ្នកអនុវត្តឧបាយកលពិសពុលនេះរបស់ចក្រពត្តិអាមេរិក យ៉ាងសកម្មបំផុត និងដោយមិនដឹងខ្លួន ។ ទាំងសម្លៀកបំពាក់ ទាំងសក់ក្បាល ទាំងឫកពារ ទាំងដំណើរដំណៅ ទាំងអាកប្បកិរិយាសំដីសំដៅ គ្មានអ្វីជាលក្ខណៈជាតិបន្តិចសោះ គេខំកាច់ ខំគ្រាប់ធ្វើតាមចក្រពត្តិអាមេរិកទាំងអស់ ។ ទាំងមនោសញ្ចេតនា និងចិត្តថ្លើមទៀតសោតក៏គ្មានអ្វីជាប់នឹងជាតិខ្លួនដែរ ។

គេគោរព ស្រឡាញ់ សរសើរតែអ្វីដែលជារបស់ចក្រពត្តិ ពិសេសចក្រពត្តិអាមេរិក ហើយអ្វីដែលជារបស់ជាតិខ្លួន គេមើលងាយ មើលថោក បន្អាប់បន្ថោកទាំងអស់ ។ ដូច្នេះ គេគិតតែពីរត់តាមគ្រាប់តាមចក្រពត្តិអាមេរិកទាំងអស់ ។ ម៉្លោះហើយ ដើម្បីស្លៀកពាក់តុបតែងកាយ សប្បាយហ៊ឺហា ពាលាអាវ៉ាសែបែបចក្រពត្តិអាមេរិក មានយុវជន យុវនារីប្រភេទនេះ ត្រូវការលុយកាក់ច្រើន ។ ក្នុងសភាពសង្គ្រាមដែលកាចសាហាវដូចសព្វថ្ងៃនេះ ជីវភាពនៅក្នុងគ្រួសារទូទៅលើកលែងតែគ្រួសារពួកអាក្បត់មួយក្តាប់តូចចេញ សុទ្ធតែមានការលំបាក មានការខ្វះខាតទាំងអស់គ្នា ដូច្នេះគ្មានលុយកាក់ផ្តល់ឲ្យយុវជន យុវនារី ជាកូនចៅឲ្យហ៊ឺហាបានតាមចិត្តទេ ។ ដូច្នេះ យុវជន យុវនារីភ្លើតភ្លើនជំពូកនេះ មានតែផ្លូវពីរទេ ដើម្បីបំពេញតណ្ហារបស់គេបាន ឬមួយធ្លាក់ខ្លួនធ្វើជាចោរលួចប្លន់ឆក់ នៅកណ្តាលក្រុង ឬធ្លាក់ខ្លួនទៅជាស្រីខូច បើជាយុវនារី ឬមួយលក់ខ្លួនឲ្យចក្រពត្តិអាមេរិក ។ ចំពោះយុវជន យុវនារីប្រភេទនេះ ទោះបីត្រូវបំភ្លិចបំផ្លាញ កាប់សម្លាប់ជាតិឯង ប្រជាជនឯង ក៏គេមិនញញើតនឹងធ្វើដែរ ធ្វើយ៉ាងណាឲ្យតែបានលុយកាក់មកបំពេញតណ្ហាគេ ។ យុវជន យុវនារីបែបនេះហើយ ដែលចក្រពត្តិអាមេរិក វាចង់បាន វាត្រូវការបំផុត សម្រាប់ធ្វើជាឧបករណ៍ផ្តាច់ការ បម្រើ និងការពារអំពើជិះជាន់ឈ្លានពានរបស់វា នៅកម្ពុជាឲ្យបានយូរអង្វែងតទៅ ។ ដូច្នេះហើយ បានជាមានយុវជន យុវនារីមួយចំនួនដែលចូលចិត្តសប្បាយ ហ៊ឺហា ភ្លើតភ្លើន តាមបែបចក្រពត្តិអាមេរិក ដែលលោភលន់ចង់បានលុយកាក់ បុណ្យស័ក្តិ ក៏ត្រូវធ្លាក់ចូលក្នុងអន្ទាក់ដ៏ខ្មៅងងឹតរបស់ចក្រពត្តិអាមេរិក ហើយធ្លាក់ខ្លួនទៅជាចំណីរបស់ចក្រពត្តិអាមេរិក យ៉ាងអណោចអាធ័មបំផុត ។ យុវជន យុវនារីខ្លះ ត្រូវចក្រពត្តិអាមេរិក និងពួកអាក្បត់លន់ នល់, សិរីមតៈ, ស៊ឹង ង៉ុកថាញ់, អ៊ិន តាំ, ចេង ហេង, ឡុង បូរ៉េត, សុស្តែន វាបញ្ជូនឲ្យធ្វើទាហានកាន់កាំភ្លើង ទៅវេងគ្រាប់រំសេវ ស្ពាប់ការពារក្បាលពួកវា យ៉ាងអាម៉ាស់បំផុត ។ យុវជន យុវនារីខ្លះទៀត ត្រូវចក្រពត្តិអាមេរិកបង្ហាត់ហ្វឹកហ្វឺន រួចបញ្ជាឲ្យមកធ្វើកម្ម៉ង់ដូ ធ្វើចារបុរស ចារនារី ធ្វើចោរព្រៃ ធ្វើសកម្មភាពស៊ើរូង បំផ្លិចបំផ្លាញបដិវត្តន៍ និងប្រជាជននៅក្នុងតំបន់រំដោះ ហើយត្រូវកងកម្លាំងប្រដាប់អាវុធ និងប្រជាជនតំបន់រំដោះយើងចាប់បានកម្ទេចចោលយ៉ាងថោកទាបបំផុត ។

នេះជាគ្រោះថ្នាក់ និងគ្រោះមហន្តរាយមួយធំ ចំពោះប្រទេសជាតិ ដ៏ដូចចំពោះយុវជន យុវនារីកម្ពុជាយើងផ្ទាល់ខ្លួនដែរ ដែលចក្រពត្តិបារាំង ចក្រពត្តិអាមេរិក និងពួកអាក្បត់ជាតិនៅភ្នំពេញ បាននិង

កំពុងតែសាបព្រោះ ដើរខបាយកល និងធ្វើសកម្មភាពយ៉ាងមមាញឹក ។

### ២) គោលជំហរ និងសកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជា ចំពោះយុវជន យុវនារីយើង

បក្សកុម្មុយនីស្តកម្ពុជា ចាត់ទុកយុវជន យុវនារីកម្ពុជា ជាកម្លាំងរបស់ជាតិ យ៉ាងធំសំខាន់ និងមានសារសំខាន់បំផុត ក្នុងការតស៊ូរំដោះជាតិ បច្ចុប្បន្នក៏ដូចក្នុងការកសាងជាតិទៅអនាគត ។ បក្សមើលឃើញច្បាស់ថា បើបណ្តែតបណ្តោយឲ្យចក្រពត្តិឈ្លានពាន វាពន្លក់បំពុលយុវជន យុវនារីយើងបាន ធ្វើឲ្យយុវជន យុវនារីយើង ពុករលួយ ពាលាអាវាសែហើយនោះ សង្គមជាតិយើងមុខជានឹងរលំរលាយ ប្រទេសជាតិមុខជានឹងជួបគ្រោះមហន្តរាយជារៀងរហូត គ្មានអ្វីទប់ទល់ ឬស្តាបានឡើយ ។ បក្សបានមើលឃើញគ្រោះថ្នាក់ទាំងនេះ ដែលចក្រពត្តិឈ្លានពាន វាបាននឹងកំពុងសាបព្រោះទៅលើយុវជន យុវនារីយើង ក៏ដូចជាចំពោះប្រទេសជាតិយើង តាំងពីជំនាន់អាណានិគមនិយមបារាំងមកម្ល៉េះ ។ ដូច្នេះហើយ បានជានៅពេលដែលបក្សបានចាប់ផ្តើមបដិសន្ធិឡើងភ្លាម នៅថ្ងៃទី៣០-៩-៥១ បក្សកុម្មុយនីស្តកម្ពុជា បានចាប់អារម្មណ៍ជាខ្លាំង ចំពោះបញ្ហាយុវជនយុវនារីកម្ពុជាភ្លាមដែរ ។ ពេលនោះ ប្រទេសជាតិ និងប្រជាជនកម្ពុជា កំពុងស្ថិតនៅក្រោមនឹមដែកហ្វាស៊ីសរបស់ចក្រពត្តិអាណានិគមបារាំង ។ បក្សបានពុះពារគ្រប់ឧបសគ្គ ឆ្លងកាត់គ្រោះថ្នាក់ច្រើនរាប់មិនអស់ ធ្វើការតស៊ូយ៉ាងមានះព្យាយាម ស្វិតស្វាញ ដើម្បីឃោសនាអប់រំយុវជន យុវនារីកម្ពុជាយើង ឲ្យមានការភ្ញាក់រលឹកនយោបាយ ឲ្យមានស្មារតីស្នេហាជាតិ មាតុភូមិ ឲ្យមានកំហឹងជាតិ និងកំហឹងវណ្ណៈពុះពោរចំពោះខ្មាំង សត្រូវជាចក្រពត្តិឈ្លានពាន ប្រទេសជាតិ និងខ្មាំងសត្រូវវណ្ណៈដែលជិះជាន់ជញ្ជក់ឈាមអង្គៀមឆ្អឹងប្រជាជនក្រីក្រយើង ។

ឆ្លងតាមការប្រយុទ្ធដយ៉ាងតឹងតែង ស្វិតស្វាញក្នុងការឃោសនាអប់រំយុវជន យុវនារីកម្ពុជាយើង តាមគ្រប់វិធី និងតាមគ្រប់រូបភាពចំហ ពាក់កណ្តាលចំហ សម្ងាត់ ស្របច្បាប់ (ខ្លាំង) ពាក់កណ្តាលស្របច្បាប់ នឹងមិនស្របច្បាប់មក បក្សក៏អាចរំដោះយុវជន យុវនារីយើង ពីមនោគមវិជ្ជា និងពីលោកទស្សនចក្រពត្តិអាណានិគមសក្តិភូមិ នាយទុន បានជាបណ្តើរៗ នូវមនោគមវិជ្ជា និងលោកទស្សនៈថ្មីបដិវត្តន៍នូវស្មារតីស្នេហាជាតិ នូវកំហឹងជាតិ និងកំហឹងវណ្ណៈ ហើយបំពាក់បាននូវស្មារតីប្រយុទ្ធ ស្មារតីលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីបុព្វហេតុរំដោះប្រទេសជាតិ រំដោះប្រជាជន រំដោះវណ្ណៈក្រីក្រ និងរំដោះយុវជន យុវនារីខ្លួនឯង ។ ដូច្នេះហើយ បានជាតាំងពីពេលដែលបក្សកុម្មុយនីស្តកម្ពុជា ចាប់បដិសន្ធិឡើង កាលណាយុវជន យុវនារីកម្ពុជាយើង ក៏រកឃើញមាគ៌ាភ្លឺស្វាងថ្មីមួយរបស់ខ្លួនសម្រាប់ដើរទៅកាន់អនាគតដ៏ត្រចេះត្រចង់ ពោលគឺធ្វើបដិវត្តន៍រំដោះជាតិរំដោះប្រជាជននិងរំដោះយុវជនយុវនារីខ្លួនឯង ហើយឈានទៅកសាងសង្គមនិយម និងកុម្មុយនីស្តនិយម នៅកម្ពុជាទៀតដែលជាសង្គមមួយគ្មានមនុស្សជិះជាន់មនុស្ស ។ ឧត្តមគតិកុម្មុយនីស្តនេះ ក៏ចាប់មានពន្លកនៅក្នុងយុវជន យុវនារីកម្ពុជាយើង តាំងពីពេលនោះមកដែរ ។

ក្នុងសម័យតស៊ូដណ្តើមឯករាជ្យពីអាណានិគមនិយមបារាំង បក្សបានចលនាបំផុសយុវជន យុវនារីយ៉ាងច្រើនកុះករ ចូលរួមប្រាស្រ័យក្នុងចលនាបដិវត្តន៍ ដោយធ្វើយុទ្ធជន ធ្វើពេទ្យដឹកជញ្ជូនបង្កបង្កើនផល ។ល។

ក្រោយមកទៀត ក្នុងសម័យតស៊ូនយោបាយ ចាប់ពីចុងឆ្នាំ ១៩៥៤មក បក្សក៏បានយកចិត្តទុកដាក់ឃោសនាអប់រំកម្លាំងយុវជនយុវនារី ទាំងទីក្រុង ទាំងជនបទជាបន្តទៀត ។ យុវជន យុវនារីកម្ពុជា ពេលបានទទួលនូវការអប់រំខាងគោលជំហរនយោបាយ ខាងសតិអារម្មណ៍បដិវត្តន៍អំពីបក្ស គេទាំងឡាយមានកំហឹងផុសផុលខ្លាំងក្លា ស្វែងចេញជាចលនាតស៊ូប្រឆាំងចក្រពត្តិអាមេរិក និងពួកវណ្ណៈជិះជាន់ តាមគ្រប់រូបភាព ទាំងនៅទីក្រុង ទាំងនៅជនបទ ។

ដូច្នេះ យុវជន យុវនារីកម្ពុជាយើង ត្រូវបានបក្សកុម្មុយនីស្តកម្ពុជា អប់រំថែបំប៉ន កសាងជាប់ជាបន្តបន្ទាប់ ទាំងខាងគោលជំហរនយោបាយសតិអារម្មណ៍បដិវត្តន៍ ទាំងខាងចាត់តាំងឲ្យធ្វើសកម្មភាពបដិវត្តន៍ផ្សេងៗ ។ ដូច្នេះ យុវជនយុវនារីបដិវត្តន៍យើង ក៏ត្រូវបានសាកល្បងក្នុងចលនាបដិវត្តន៍ក្តៅជាប់ជាបន្តបន្ទាប់ដែរ ធ្វើឲ្យគោលជំហរបដិវត្តន៍របស់ខ្លួន ត្រូវបានពង្រឹងថែមទៀតជាលំដាប់ ។ ដូច្នេះ យុវជន យុវនារីបដិវត្តន៍យើង ក៏បានប្រែក្លាយទៅជាកម្លាំងស្នូល និងបញ្ចេះនៃការតស៊ូបដិវត្តន៍នៅគ្រប់ទិសទី ទាំងនៅទីក្រុង ទាំងនៅជនបទ ។

### ៣) សម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា ជាដៃស្តាំរបស់បក្ស

ដើម្បីបំផុស និងជំរុញចលនាយុវជន យុវនារីយើងឲ្យកាន់តែខ្លាំងក្លាថែមទៀត សមស្របតាមសភាពការណ៍នៃចលនាតស៊ូបដិវត្តន៍ ដែលកាន់តែឆាបឆេះសន្ធោសន្ធៅខ្លាំងឡើងៗ នឹងសមស្របនឹងគោលដៅប្រយុទ្ធរបស់យុវជន យុវនារីយើងផង ដែលកាន់តែអង់អាចឈានមុខ និងរឹងប៉ឹងឡើងជាលំដាប់ នៅក្នុងឆ្នាំ ១៩៦០ បក្សក៏បានសម្រេចបង្កើតអង្គការយុវជន យុវនារីកម្ពុជាមួយដែលនៅពេលនោះមានឈ្មោះថា "សម្ព័ន្ធយុវជនកម្ពុជាប្រជាធិបតេយ្យ" ឬហៅកាត់ថា "សម្ព័ន្ធយុវកក" សម្រាប់ដឹកនាំ និងបំផុសបំផុលចលនាយុវជន យុវនារីកម្ពុជា ក្នុងការតស៊ូបដិវត្តន៍ប្រឆាំងការជ្រៀតជ្រែក ឈ្លានពានរបស់ចក្រពត្តិអាមេរិក និងបរិវារនៅពេលនោះផង និងតស៊ូវាយប្រហារ និងវាយកម្ទេចរបបជិះជាន់ផ្តាច់ការ ហ្វាស៊ីស របស់ពួកសក្តិភូមិ នាយទុនប្រតិកិរិយា នៅជំនាន់នោះផង ។ ចាប់តាំងពីពេលមានកំណើតឡើងកាលណាសម្ព័ន្ធយុវកក បានពុះពារគ្រប់ឧបសគ្គ និងឆ្លងកាត់គ្រោះថ្នាក់គ្រប់បែបយ៉ាងប្រយុទ្ធធ្វើសកម្មភាពយ៉ាងអង់អាចក្លៀវក្លា ក្នុងមជ្ឈដ្ឋានយុវជនយុវនារីយើងកម្ពុជា ពិសេសក្នុងមជ្ឈដ្ឋានយុវជន យុវនារី កម្មករពលករ កសិករ និងយុវជនយុវនារីសិក្សា ។ ក្រោមការដឹកនាំដ៏ភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជា សម្ព័ន្ធយុវកកយើង បានធ្វើការឃោសនាអប់រំយ៉ាងសកម្ម ដោយដឹកនាំពាំយូរនូវមាគ៌ានយោបាយ គោលនយោបាយ និងសេចក្តីសម្រេចចិត្តផ្សេងៗរបស់បក្ស យកទៅផ្សព្ផ្សាយក្នុងយុវជន យុវនារីកម្ពុជាដ៏កុះករ និងក្នុងប្រជាជនកម្ពុជាទូទៅហើយចូលជ្រៅជាពិសេសទៅក្នុងស្រទាប់យុវជន យុវនារីប្រជាជនមូលដ្ឋាន ។ តាមរយៈនៃការឃោសនាអប់រំ តាមគ្រប់រូបភាពនេះសម្ព័ន្ធយុវកកយើង បានធ្វើឲ្យមាគ៌ានយោបាយ គោលនយោបាយនិងសេចក្តីសម្រេចចិត្តផ្សេងៗរបស់បក្សបានជ្រួតជ្រាបជាបណ្តើរៗទៅក្នុងយុវជន យុវនារីកម្ពុជាក៏កុះករ និងក្នុងប្រជាជនកម្ពុជាទូទៅធ្វើឲ្យកម្លាំងមហាជនទាំងនេះ មានការភ្ញាក់រលឹកជាតិ និងភ្ញាក់រលឹកវណ្ណៈ កាន់តែខ្ពស់ឡើងៗ ហើយប្រែក្លាយទៅជាកម្លាំងបដិវត្តន៍មួយដ៏ខ្លាំងក្លា វាយកម្ចាត់នូវរាល់ឧបាយកលពិសពុល ខ្មៅងងឹតរបស់ចក្រពត្តិអាមេរិក និងបរិវារ បានជាបន្តបន្ទាប់រហូតដល់វាយបណ្តេញពួកចក្រពត្តិអាមេរិកអស់ពីកម្ពុជា នៅពាក់កណ្តាលឆ្នាំ១៩៦៥ ព្រមទាំងវាយប្រហារ វែកញែក បកអាក្រាតអំពើរបជាន់ ឆក់ប្លន់អយុត្តិធម៌ និងការបង្ក្រាបរាតត្បាត ចាប់ចង កាប់សម្លាប់ យ៉ាងឃោរឃៅ ហ្វាស៊ីស របស់ពួកវណ្ណៈកាន់អំណាចជំនាន់នោះ ដែលតំណាងផលប្រយោជន៍ឲ្យសក្តិភូមិ នាយទុន ប្រតិកិរិយាផង ។ ក្រៅពីនេះ សម្ព័ន្ធយុវកកយើង នៅបានចាត់តាំងចលនាតស៊ូ ដឹកនាំចលនាតស៊ូ និងរួមប្រឡូកផ្ទាល់ ក្នុងគ្រប់ចលនាតស៊ូបដិវត្តន៍ដ៏សន្ធោរសន្ធៅរបស់យុវជន យុវនារីកម្ពុជា ប្រឆាំងចក្រពត្តិអាមេរិក បរិវារ និងពួកអាវណ្ណៈកាន់អំណាចឃោរឃៅ ប្រតិកិរិយាជំនាន់នោះ យ៉ាងផុសផុល គគ្រឹកគគ្រេង ទាំងនៅទីក្រុង ទាំងនៅជនបទ ។

ដូច្នេះ សម្ព័ន្ធយុវកក បានទៅជាអ្នកផ្សព្វផ្សាយ និងជាអ្នកអនុវត្តមាគ៌ានយោបាយ គោលនយោបាយ និងសេចក្តីសម្រេចចិត្តផ្សេងៗរបស់បក្សយ៉ាងសកម្មប្រយុទ្ធ និងអង់អាចឈានមុខបំផុតក្នុងមជ្ឈដ្ឋានយុវជកម្ពុជា ពិសេសយុវជនកម្មករ ពលករ កសិករ និងយុវជនសិក្សា ក៏ដូចក្នុងចំណោមប្រជាជនកម្ពុជាទូទៅ ។ ដូច្នេះសម្ព័ន្ធយុវកកបានក្លាយទៅជាដៃស្តាំរបស់បក្សយ៉ាងពិតប្រាកដ ។ ក្រោមការដឹកនាំ អប់រំ ថែបំប៉នអំពីបក្ស ទាំងខាងគោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំង ទាំងខាងការសាកល្បង ហ៊ឹកហ៊ឺនលត់ដំខ្លួន ក្នុងចលនាតស៊ូបដិវត្តន៍ក្តៅជាបន្តបន្ទាប់ សម្ព័ន្ធយុវកកយើង មានធាតុជាអង្គការយុវជនបដិវត្តន៍កម្ពុជា ដ៏រឹងប៉ឹងមួយហើយបានក្លាយទៅជាកម្លាំងជំនួយដ៏សំខាន់ ចំពោះគ្រប់កិច្ចការទាំងអស់របស់បក្សកុម្មុយនីស្តកម្ពុជា ។

ដូច្នេះហើយ បានជានៅខែមករា ឆ្នាំ១៩៧១ បក្សបានប្រែឈ្មោះអង្គការបដិវត្តន៍យុវជនកម្ពុជានេះ ទៅជា "សម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា" ដែលហៅកាត់ថា "សម្ព័ន្ធយុវកក" ដើម្បីឲ្យសមស្របទៅនឹងសកម្មភាព ធាតុពិត និងតួនាទីរបស់យុវជន យុវនារីបដិវត្តន៍កម្ពុជាយើង នៅក្នុងចលនាតស៊ូធ្វើសង្គ្រាមប្រជាជនប្រឆាំងនឹងសង្គ្រាមឈ្លានពានដ៏កាចសាហាវរបស់ចក្រពត្តិអាមេរិក និងបរិវារសព្វថ្ងៃនេះ ។ តាំងពីពេលនោះរហូតមកដល់បច្ចុប្បន្ននេះ សម្ព័ន្ធយុវកក បានប្រកាន់នាទីជាកម្លាំងស្នូល ដឹកនាំ បំផុសបំផុលចលនាយុវជន យុវនារីកម្ពុជានៅទូទាំងប្រទេស ទាំងសមរភូមិមុខ ទាំងសមរភូមិក្រោយ ទាំងនៅតាមមន្ទីរក្រសួង និងការដ្ឋានផ្សេងៗ ។ សម្ព័ន្ធយុវកកយើង បានធ្វើជាគំរូល្អ និងគំរូឈានមុខគេ អង់អាចក្លាហាន និងសកម្មប្រយុទ្ធក្នុងគ្រប់កាលៈទេសៈ ក្នុងគ្រប់កិច្ចការ

បដិវត្តន៍តូចធំ ធ្ងន់ ស្រាល លំបាក ស្រួល ទាំងអស់ដែលបក្សត្រូវការ ទោះក្នុងភារកិច្ចវាយកម្ទេចខ្មាំងនៅសមរភូមិមុខក្តី ទោះក្នុងភារកិច្ចដឹកជញ្ជូន លីសែង ហាលភ្លៀង ហាលថ្ងៃ ក្រោមគ្រាប់បែក គ្រាប់កាំភ្លើង ច្រើនដូចគ្រាប់ភ្លៀងយ៉ាងណាក្តី ទោះក្នុងភារកិច្ចធ្វើពលកម្មលើកទំនប់ ជីកស្រះ ជីកប្រឡាយ ដោះស្រាយបញ្ហាទឹកជូនប្រជាជន បង្កបង្កើនផលក្តី ឬក្នុងចលនាបង្កបង្កើនក្តី កែប្រែជីវភាពប្រជាជនមូលដ្ឋាន ឬក្នុងចលនាចាត់តាំងពង្រឹងពង្រីកសហករណ៍នៅសមរភូមិក្រោយក្តី ទោះនៅក្នុងភារកិច្ចបដិវត្តន៍ផ្សេងៗទៀត នៅតាមមន្ទីរ ការដ្ឋាន និងក្រសួងនានាក្តី ។ ដូច្នោះ ឃើញថា តាំងពីដើមរៀងរហូតមកដល់សព្វថ្ងៃនេះ សម្ព័ន្ធយុវកកយើង បានរួមចំណែកយ៉ាងសកម្ម និងយ៉ាងសំខាន់បំផុតជាមួយបក្ស និងប្រជាជនកម្ពុជាយើងទាំងមូលក្នុងការដណ្តើមយកជ័យជម្នះយ៉ាងធំទំហំអស្ចារ្យលើគ្រប់វិស័យលើខ្មាំងសត្រូវគ្រប់ប្រភេទនាបច្ចុប្បន្ននេះ ។ នេះគឺជាការសប្បាយរីករាយ និងជាមោទកភាពបដិវត្តន៍ដ៏ខ្ពង់ខ្ពស់របស់យុវជន យុវនារីបដិវត្តន៍យើង ក៏ដូចជារបស់បក្ស បដិវត្តន៍ និងប្រជាជនយើងទាំងមូលដែរ ។ ការរីកចម្រើនដុះដាល និងធាតុរឹងប៉ឹងរបស់អង្គការបដិវត្តន៍យុវជនកម្ពុជាយើងនេះ គឺពិតជាបេះមិនដាច់អំពីសកម្មភាព និងគោលជំហររបស់បក្សកុម្មុយនីស្តកម្ពុជាឡើយ ។ បក្សកុម្មុយនីស្តកម្ពុជានេះហើយ ដែលជាអ្នកចាត់តាំង កសាង បង្កើត អង្គការបដិវត្តន៍យុវជនកម្ពុជានេះឡើង ឲ្យមានទាំងរូបរាង មានទាំងសកម្មភាពជាក់ស្តែង បំពាក់បំប៉នពង្រឹងទាំងទស្សនៈគោលជំហរ និងមនោសញ្ចេតនាជាបដិវត្តន៍ថ្មី ។ ដូច្នេះបក្សកុម្មុយនីស្តកម្ពុជា បានរំដោះយុវជន យុវនារីកម្ពុជាយើងទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ទាំងខាងស្មារតី ទាំងខាងទស្សនៈគោលជំហរ និងមនោគមវិជ្ជា ឲ្យរួចចាកផុតពីរណ្តៅងងឹតសូន្យសុងនៃទស្សនៈ គោលជំហរ និងមនោគមវិជ្ជាពុករលួយ ខិនថយជិះជាន់របស់ចក្រពត្តិ សក្តិភូមិ នាយទុន ឲ្យឃើញ ឲ្យស្គាល់នូវពន្លឺរស្មីនៃអនាគតដ៏រុងរឿងមួយ ពោលគឺឧត្តមគតិកុម្មុយនីស្តដ៏ត្រចះត្រចង់ ។

ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៤ នេះ ជាថ្ងៃខួបទី២៣ នៃកំណើតបក្សកុម្មុយនីស្តកម្ពុជាដ៏រុងរឿង ។ ដើម្បីជាកិច្ចតបស្នងសងគុណដល់បក្សផង និងដើម្បីឲ្យសមស្របតាមសេចក្តីសង្ឃឹម និងសេចក្តីជឿទុកចិត្តរបស់បក្សបដិវត្តន៍ និងប្រជាជនកម្ពុជាទាំងមូលមកលើខ្លួន យុវជន យុវនារីបដិវត្តន៍កម្ពុជា ប្តេជ្ញាកសាងខ្លួនឲ្យទៅជាដៃស្តាំរបស់បក្សយ៉ាងពិតប្រាកដ ដោយប្តេជ្ញាខិតខំកសាងបំពាក់ឲ្យខ្លួននូវធាតុពិតរបស់សម្ព័ន្ធយុវកក ឲ្យបានកាន់តែរឹងប៉ឹង និងល្អបរិសុទ្ធឡើង ។ ជាក់ស្តែង៖

១) ត្រូវខិតខំកសាង និងបំពាក់ឲ្យខ្លួននូវធាតុវណ្ណៈកម្មកររបស់បក្ស ហើយកម្ចាត់នូវធាតុវណ្ណៈផ្សេងៗដែលមិនបដិវត្តន៍ដែលមាននៅសេសសល់នៅក្នុងខ្លួន ឬក្នុងជួរនៅឡើយ ឲ្យបានដាច់ខាត និងជ្រះស្រឡះ ។

២) ត្រូវខិតខំកសាង និងបំពាក់នូវធាតុឈានមុខរបស់បក្សអង់អាចក្លាហាន មោះមុត ស្មុះស្មារ សកម្មប្រយុទ្ធជាងគេបំផុតក្នុងការអនុវត្តមាគ៌ានយោបាយ គោលនយោបាយ និងសេចក្តីសម្រេចចិត្តផ្សេងៗរបស់បក្ស ក្នុងគ្រប់ការងារតស៊ូបដិវត្តន៍យោធា នយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច ការពារ នីរសារដឹកជញ្ជូន បច្ចេកទេសផ្សេងៗ ។ល។ នៅគ្រប់សមរភូមិខាងមុខក្តី ខាងក្រោយក្តី ក្នុងគ្រាស្រួលក្តី ក្នុងគ្រាលំបាកក្តី គ្មានរាថយតាមគោលជំហរវីរភាពបដិវត្តន៍ និងតាមស្មារតីគោរពវិន័យអង្គការដោយភ្ញាក់រលឹកខ្ពស់បំផុត ។

បើយុវជន យុវនារីបដិវត្តន៍យើង មានធាតុទាំងពីរនេះរឹងមាំ យុវជន យុវនារីយើង នឹងទៅជាកម្លាំងជំរុញចលនាតស៊ូបដិវត្តន៍យ៉ាងខ្លាំងក្លានាបច្ចុប្បន្ន និងជាអ្នកបន្តវេនកាន់កាប់វាសនាបដិវត្តន៍យ៉ាងរឹងមាំទៅអនាគត ។ ដូច្នេះ អនាគតបដិវត្តន៍កម្ពុជានឹងនៅតែមានពណ៌ក្រហមឆ្អិនឆ្អៅ ជារៀងរហូតទៅ ។

**ឆេង ម៉េង**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* . ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសារ ចាប់ពីខែមេសា ដល់ ខែធ្នូ ឆ្នាំ២០១៦
















*កាលបរិច្ឆេទបញ្ចាំង៖ រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង១០ ៖ ០០ព្រឹក និង ម៉ោង៥ ៖ ១៥ រសៀល*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖*

លោក ម៉ែន ពិចិត្រ
មជ្ឈមណ្ឌលឯកសារកម្ពុជា
ទូរស័ព្ទលេខ ០២៣ ២១៤ ០០៩
អ៊ីម៉ែលៈ truthmpechet@dccam.org
គេហទំព័រៈ www.dccam.org l www.cambodiasri.org

**ខែមេសា ឆ្នាំ២០១៦**

◆ ថ្ងៃទី១ ខែមេសា វេលាម៉ោង ១ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង "គុកឥតជញ្ជាំង" ដោយទូរទស្សន៍ ជាតិកម្ពុជា (៩៥ នាទី)

◆ ថ្ងៃទី៨ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង "ការងារសម្ងាត់នៅមន្ទីរស-២១" ដោយ ដេវីត អូកូហ្វូណា (David Okuefuna) (៣០ នាទី)

◆ ថ្ងៃទី២២ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង "ឋាននរក៩ជាន់" ដោយ Cinema Dept. FPD ក្នុងឆ្នាំ១៩៨៧ (១៣១.២៨ នាទី)

◆ ថ្ងៃទី២៩ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង "ប្រាសាទអង្គរវត្តដែលកំបាំង" ដោយ Discover Magazine ក្នុងឆ្នាំ១៩៩៩ (៣០.១៥ នាទី)

**ខែឧសភា ឆ្នាំ២០១៦**

◆ ថ្ងៃទី២០ ខែឧសភា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង "កម្ពុជា ៈ ការស្លាប់ និង ការចាប់កំណើត" ដោយ Germany ក្នុងឆ្នាំ១៩៨០ (៩០ នាទី)

◆ ថ្ងៃទី២០ ខែឧសភា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង "អន្តការ" ដោយ Germany ក្នុងឆ្នាំ ១៩៨១ (៩០ នាទី)

**ខែមិថុនា ឆ្នាំ២០១៦**

◆ ថ្ងៃទី៣ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង "សង្គ្រាមក្នុងព្រៃ" ដោយ Germany ក្នុងឆ្នាំ ១៩៨៣ (៩០ នាទី)

◆ ថ្ងៃទី១០ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង "រវាងសន្តិភាព និងយុត្តិធម៌ ៈ រឿងកន្ទួលហួសទៅសួមឲ្យកន្ទួលហួសទៅចុះ" ដោយ ព្រូណូ ការ៉ាតេ (Bruno Carette) ក្នុងឆ្នាំ១៩៩៩ (៣៧ នាទី)

◆ ថ្ងៃទី១៧ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង "ជីវិ២ (ជីវិជនភៀសខ្លួន)" ដោយ រិទ្ធី ប៉ាន់ ក្នុងឆ្នាំ១៩៨៩ (៦០ នាទី)

◆ ថ្ងៃទី១៧ ខែមិថុនា វេលា ម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៈ ១៥ រសៀល បញ្ចាំងរឿង "ប៉ុល ពត ៈ ការសម្លាប់" ដោយ ភីធើ ហើខំ (Peter Hercombe) (៥១ នាទី)

**ខែកក្កដា ឆ្នាំ២០១៦**

◆ ថ្ងៃទី១ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «សាក្សីកម្ពុជា» បណ្ណសាររបស់ ដេវីត ហក (David Hawk Archives) (១១១.២នាទី)

◆ ថ្ងៃទី៨ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «សកម្មភាពគោរពវិញ្ញាណក្ខន្ធនៅបូជនីយដ្ឋានជើងឯក» ដោយ FPD ក្នុងឆ្នាំ១៩៩៨

◆ ថ្ងៃទី១៥ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ព្រះអាទិទេពចុងក្រោយ» ដោយ ជេមស៍ ជើរ៉ាន (James Gerrand) (១១៨នាទី)

◆ ថ្ងៃទី២២ ខែកក្កដា វេលាម៉ោង១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «តំបន់អន្ទង់វែង (តាម៉ុក)» ដោយ ជេមស៍ ជើរ៉ាន (James Gerrand) (១៧៨.៥៧នាទី)

◆ ថ្ងៃទី២៩ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «កម្ពុជា ៣បូក៨ ឆ្នាំទីសូន្យ និងឆ្នាំទី១» ក្នុងឆ្នាំ១៩៧៩ (១៥៦នាទី)

**ខែសីហា ឆ្នាំ២០១៦**

◆ ថ្ងៃទី៥ ខែសីហា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ស្រមោលអតីតកាល : រឿងចំនួនបួនដែលនិយាយអំពីការផ្សះផ្សា» ដោយ Express TV (១២០ នាទី)

◆ ថ្ងៃទី១២ ខែសីហា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ :១៥ រសៀល បញ្ចាំងរឿង «ស្រមោលរបស់ ប៉ុល ពត» ដោយ អាមេនដា ផៃក (Amanda Pike) ក្នុងឆ្នាំ២០០២ (២៥នាទី)

◆ ថ្ងៃទី១៩ ខែសីហា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «ក្តីសង្ឃឹមដ៏តិចតួចចេញពីវាលពិឃាត» ដោយ ធារ៉ា ដេលហ្គាដូ (Tiara Delgado) (៣៨នាទី)

◆ ថ្ងៃទី២៦ ខែសីហា វេលាម៉ោង១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ទម្លាយភាពស្ងប់ស្ងាត់» ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា (៦៩នាទី)

**ខែកញ្ញា ឆ្នាំ២០១៦**

◆ ថ្ងៃទី២ ខែកញ្ញា វេលាម៉ោង១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «បទសម្ភាសន៍ជាមួយ ប៉ុល ពត» ដោយ ភីធើ ហ្វ្រូបឹក (Peter Froberg) ក្នុងឆ្នាំ២០០៤ (៥១នាទី)

◆ ថ្ងៃទី៩ ខែកញ្ញា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ប៉ុល ពត : ដំណើរទៅកាន់វាលពិឃាត» ដោយ ជេន ចនស្តុន (Jane Johnston) (៥០ នាទី)

◆ ថ្ងៃទី១៦ ខែកញ្ញា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «យុត្តិធម៌ដែលបានពន្យាពេល និងយុត្តិធម៌ដែលបានបដិសេធ (ការកាត់ទោសមេដឹកនាំខ្មែរក្រហម)» ក្នុងឆ្នាំ២០០៥ (៥៨.២៨នាទី)

◆ ថ្ងៃទី២៣ ខែកញ្ញា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «រឿងរ៉ាវពីទឹកដីកម្ពុជាក្រោម» (៧០ នាទី)

**ខែតុលា ឆ្នាំ២០១៦**

◆ ថ្ងៃទី៧ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង "នៅក្រោយជញ្ជាំងមន្ទីរស-២១" ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០០៧ (៣០ នាទី)

◆ ថ្ងៃទី១៤ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង "ដំណើរទៅកាន់វាលពិឃាត" ដោយ ជេន ចនស្តុន (Jane Jonhston) (៥០ នាទី)

◆ ថ្ងៃទី២១ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង "ដល់ពេលស្វែងរកយុត្តិធម៌" ដោយ KMF Films ក្នុងឆ្នាំ២០០៧ (៤០ នាទី)

◆ ថ្ងៃទី២៨ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង "មើលទៅមុខ មើលទៅក្រោយ" ដោយ DMC ក្នុងឆ្នាំ២០០៧ (៥២.៣០ នាទី)

**ខែវិច្ឆិកា ឆ្នាំ២០១៦**

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង "ការរាំទៅរកការស្លាប់ : សត្តស្វា មន្តអាគម និងភាពរិលរល់របស់កម្ពុជា" ដោយ ចេនេត ហ្គាតនើ (Janet Gardner) ក្នុងឆ្នាំ២០១០ (៥៦ នាទី)

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង "ការកាត់ទោស ប៉ុល ពត នៅអន្លង់វែង នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧" ដោយ ឡុង សារិន ក្នុងឆ្នាំ ១៩៩៧ (៤៣.៣០ នាទី)

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "៣ឆ្នាំ ៨ខែ ២០ថ្ងៃ" ដោយ រ៉ូសេន សេដណាតា (Roshane Saidnattar) ក្នុងឆ្នាំ២០០៩ (៩៨.០៦ នាទី)

◆ ថ្ងៃទី២៥ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង "ក្មេងសម្រាប់ដាក់លក់" ដោយ NBC TV ក្នុងឆ្នាំ២០០៤ (៤៣នាទី)

**ខែធ្នូ ឆ្នាំ២០១៦**

◆ ថ្ងៃទី២ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង "វិប្បដិសារី" ក្នុងឆ្នាំ២០០៨ (Royal Archives)

◆ ថ្ងៃទី៩ ខែធ្នូ វេលាម៉ោង១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង "កងទ័ពខ្មែរក្រហម" ដោយ ព្រូណូ ការ៉ាតេ (Bruno Carette) និង សេន មេត្តា (Sien Meta) ក្នុងឆ្នាំ ២០០៧ (៩៥ នាទី)

◆ ថ្ងៃទី១៦ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង "ពេលព្រះអាទិត្យអស្តង្គត" ដោយ ព្រះបាទ នរោត្តម សីហនុ

◆ ថ្ងៃទី២៣ ខែធ្នូ វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "កុំស្មានបងភ្លេច : ខ្មែរបាត់បង់តន្ត្រីរ៉ក់" ដោយ ចន ពីរ៉ូស៊ី (Jonh Pirozzi) (១០៧នាទី)

◆ ថ្ងៃទី៣០ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ត្បូងទឹកទន្លេ" ដោយ កល្យាណី ម៉ម ក្នុងឆ្នាំ២០១២ (៨៣នាទី)

# ការិយាល័យព័ត៌មានសាធារណៈ

*“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ឆេង វ៉េង តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthveng.c@dccam.org ។*





















# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthmpechet@dccam.org ។

**◆ ទីកន្លែង ៖ អគារ “ក” ជាន់លើ ◆ ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# www.cambodiatribunal.org

*គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយ នៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។*

*សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបានប្រកាសសាលក្រមលើកទីមួយកាលពីខែសីហា ឆ្នាំ២០១៤ ។*

*ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូ សវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការ និងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។*

*គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់ សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញ និងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី "សហកម្មខុក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "Join Criminal Enterprise" ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម "ផែនការឧក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "Common Criminal Plan" ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេ ដែលមានយោបល់ទៅលើបញ្ហានេះ?*

*ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។* **វ៉ាន់ថាន់ ពោធារ៉ា**

# ពីយោធាខ្មែរក្រហមមកជាប្រជាជនសាមញ្ញ

មានស្រុកកំណើត នៅខេត្តស្ទឹងត្រែង ទុយ យឿន សព្វថ្ងៃមានអាយុ៥៣ឆ្នាំ ធ្លាប់ធ្វើជាសមាជិកកងចល័តភូមិ បន្ទាប់មកគាត់ចូលកងទ័ពបដិវត្តន៍ខ្មែរក្រហម ធ្វើការនៅក្នុងព្រៃខេត្តរតនគិរីអស់រយៈពេលជាច្រើនឆ្នាំ ។ យឿន បានរស់នៅរតនគិរីរហូតដល់ពេលវៀតណាមចូលមកឆ្នាំ១៩៧៩ ទើបគាត់ភៀសខ្លួនមកនៅតាមបណ្ដោយព្រំដែនខ្មែរ-ថៃ ។ នៅក្នុងឆ្នាំ១៩៨៩ គាត់រៀបការប្រពន្ធឈ្មោះ ភេង ផង់ អាយុ៤២ឆ្នាំ នៅក្នុងទឹកដីថៃជិតតំបន់អានសេះ ខេត្តព្រះវិហារ ។ ក្រោយមក គ្រួសារគាត់ផ្លាស់មករស់នៅតំបន់អន្លង់វែង ។ យឿន និងប្រពន្ធបានប្រកបរបរចិញ្ចឹមសត្វដូចជា មាន់ទា ជ្រូក តែជាច្បាប់ទម្លាប់គ្រប់គ្រងរបស់ខ្មែរក្រហម នៅក្នុងតំបន់នេះ គឺតម្រូវឱ្យប្រជាជនប្រមូលផលយកមកចែកគ្នាហូបជាសមូហភាព ។ នៅពេលនោះ អង្គការក៏បានចែកសណ្ដែកសៀង គ្រាប់ធញ្ញជាតិ និងម្ហូបអាហារដល់ប្រជាជនបរិភោគថែមទៀតផង ដែលខុសស្រឡះពីក្រោយពេលសមាហរណកម្ម ឆ្នាំ១៩៩៨ ដែលប្រជាជនត្រូវធ្វើស្រែចម្ការ និងដោះស្រាយជីវភាពដោយខ្លួនឯង ។

គ្រួសាររបស់ យឿន ទោះមិនមានទ្រព្យសម្បត្តិនៅពេលនោះ តែគាត់មានហូបគ្រប់គ្រាន់ព្រោះអង្គការបានផ្គត់ផ្គង់នូវសម្ភារប្រើប្រាស់ ស្បៀង និងអាហារហូបចុក ដោយប្រជាជនម្នាក់ទទួលបានអង្ករ១ប៉ោត ជារៀងរាល់ខែ ។ សម័យនោះ អង្គការមានតួនាទីជាអ្នកផ្គត់ផ្គង់ ចិញ្ចឹមបីបាច់ និងគាំពារក្រុមគ្រួសាររបស់គាត់ ។ យឿន នៅចាំបានថា គ្រួសារគាត់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មេបញ្ជាខ្មែរក្រហមឈ្មោះ សារឿន ហៅ តា០៥ នៅតំបន់អន្លង់វែង ។ ចំណែកឪពុកម្ដាយរបស់គាត់នៅស្រុកកំណើតបានគិតថា គាត់បានស្លាប់បាត់ហើយ ថែមទាំងធ្វើបុណ្យឧទ្ទិសដល់គាត់ថែមទៀតផង ។ ក្រៅពីរបបអង្ករ អង្គការបានចែក ត្រីខ មី អំបិល ប៊ីចេង ប្រហុក រួមទាំង សម្លៀកបំពាក់ដែលនាំចូលមកពីប្រទេសថៃដល់គ្រួសារគាត់ទៀត ហើយសាលារៀននៅពេលនោះ អង្គការក៏បើកឱ្យសិស្សចូលរៀនសូត្រដែរ តែមិនបានតាំងនៅជាប់លាប់ទេ និងត្រូវផ្លាស់ប្ដូរទីកន្លែងជាច្រើនលើកច្រើនសាដោយសារតែសង្គ្រាម ។ ក្រោយមក យឿន និងគ្រួសារប្រកបរបរធ្វើចន្ទុះ និងក្រងស្បូវលក់ទៅឱ្យប្រជាជនថៃដើម្បីយកប្រាក់ទៅទិញរបស់របរប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃវិញ ។

ក្រោយពីធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាលក្នុងឆ្នាំ១៩៩៨ អន្លង់វែងមានសន្តិភាពពេញលេញ ទើបប្រជាជនចំណូលថ្មីបាននាំគ្នាចូលមករស់នៅតំបន់នេះកាន់តែច្រើន ។ នៅពេលនោះ យឿន បានសន្សំប្រាក់រហូតមានលទ្ធភាពសាងសង់ផ្ទះលើកដុតពីដីមួយខ្នង ហើយក្រោយមកគាត់ទិញបានម៉ូតូថ្មីមួយគ្រឿងទៀត ។ មិនខុសពីគ្រួសារ យឿន អ្នកភូមិជិតខាងរបស់គាត់ក៏មានលទ្ធភាពទិញរថយន្ត និងសាងសង់ផ្ទះថ្មធំៗដែរ ។ យឿន បានបន្ថែមថា នៅពេលបច្ចុប្បន្នដោយសារតម្លៃដីឡើងថ្លៃ ដូច្នេះប្រជាជនអាចលក់ដីកម្មសិទ្ធិរបស់ខ្លួន ដែលធ្វើឱ្យជីវភាពរបស់ពួកគេមានការផ្លាស់ប្ដូរជាងមុន ។

យឿន បាននិយាយថា គាត់ចាប់ផ្ដើមពីបាតដៃទទេចេញពីការរត់លួន គេចវេះពីការប្រឈមមុខ ដោយអាវុធរវាងយោធាខ្មែរក្រហម និងកងទ័ពរដ្ឋាភិបាល និងជម្លោះផ្ទៃក្នុង ក្នុងចំណោមមេដឹកនាំខ្មែរក្រហម ។ គាត់ត្រូវរត់ឡើងភ្នំទៅនៅជរំមួយដែលគាត់មិនចាំឈ្មោះ និងចុះមកវិញជាច្រើនលើកច្រើនសា ។ គាត់បានបាត់បង់ទ្រព្យសម្បត្តិស្ទើរតែទាំងអស់នៅពេលនោះ ។

សព្វថ្ងៃ យឿន ត្រូវធ្វើការងារជាច្រើន គិតចាប់ពីធ្វើស្រែ ចិញ្ចឹមមាន់-ទា ជ្រូក រកត្រី និងដាំដំឡូងមីដើម្បីផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ ព្រោះមិនមានអង្គការមកផ្គត់ផ្គង់ និងចិញ្ចឹមគ្រួសារគាត់ដូចពេលមុននោះទេ ។ យឿន ក៏មិនបានទទួលការឧត្ដម្ភក្រោយពីរាជរដ្ឋាភិបាលប្រកាសរំសាយគាត់ពីកងទ័ពដែរ ។ យឿន បានសំណូមពរឱ្យរាជរដ្ឋាភិបាលជួយស្វែងរកទីផ្សារដើម្បីឱ្យកសិផលរបស់គាត់ដែលផលិតលក់បានក្នុងតម្លៃខ្ពស់ បន្ថែមលើសន្តិភាពដែលគាត់ទទួលបានរួចមកហើយនៅក្នុងតំបន់អន្លង់វែង ។ **មាស ប៊ុនថាន**

# អតីតអនុប្រធានភ័ស្តុភារតំបន់៤១ : សុន កាន់

សុន កាន់ មានអាយុ៦៥ឆ្នាំ មានឪពុកឈ្មោះ សុន ម្តាយឈ្មោះ ស៊ុំ និងមានបងប្អូនបង្កើតចំនួនប្រាំនាក់ ។ កាន់ មានស្រុកកំណើតនៅឃុំខ្នុរដំបង ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ នៅពេល កាន់ អាយុ៧ឆ្នាំ ឪពុកម្តាយ កាន់ ឲ្យគាត់ទៅរៀននៅសាលាវត្តភូមិវាល ហើយ កាន់ បានបួសភិក្ខុ រយៈពេលពីរវស្សានៅទីនោះ ។ នៅឆ្នាំ១៩៧០ ពេលមានរដ្ឋប្រហារ និងសង្គ្រាមកើត ឡើងរវាងកងទ័ពរំដោះជាតិក្នុងព្រៃ (កម្លាំងខ្មែរក្រហម) និងទាហាន លន់ នល់ ដែលសុទ្ធជាខ្មែរដូចគ្នា ពេលនោះ កាន់ បានលាចាកសិក្ខាបទមករស់នៅជាមួយឪពុកម្តាយដើម្បីធ្វើស្រែចម្ការវិញ ។ នៅអំឡុងឆ្នាំ១៩៧១-៧២ សង្គ្រាមចាប់ផ្តើមផ្ទុះឡើងកាន់តែខ្លាំងធ្វើឲ្យប្រជាជនរស់នៅកាន់តែលំបាក និងរត់គេចខ្លួនជាញឹកញាប់ដោយសារមានការទម្លាក់គ្រាប់បែកពីសំណាក់ទាហាន លន់ នល់ ។

នៅឆ្នាំ១៩៧២ កម្លាំងខ្មែរក្រហមបានមកគ្រប់គ្រងនៅភូមិឃុំរបស់ កាន់ ដូចនេះ យុវជន យុវនារីដែលមានអាយុ១៦-១៧ឆ្នាំឡើងទៅ ត្រូវបានខ្មែរក្រហមប្រមូលមកអប់រំ ឃោសនាឲ្យចូលបម្រើយោធា ខ្លះធ្វើពេទ្យទៅតាមការចាត់តាំង ។ នៅឆ្នាំ១៩៧៣ កាន់ បានស្ម័គ្រចិត្តចូលធ្វើជាសេនាជនភូមិ បន្ទាប់មកអង្គការបានបញ្ជូនគាត់ឲ្យទៅជួយសែងអ្នករបួសនៅម្តុំព្រែកតាសេកខាងកើតភ្នំពេញ ។ នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមឡើងកាន់អំណាច អង្គការបានបញ្ជូន កាន់ ឲ្យទៅធ្វើការងារនៅតំបន់៤១ ដែលកាលនោះមានឈ្មោះមិត្តតាំង និងមិត្ត ស្រេង ជាគណៈតំបន់ ចំណែក មិត្ត សោ ជាគណៈស្រុកព្រៃឈរ ។ ប្រធានរបស់ កាន់ ឈ្មោះ មិត្តហោ គ្រប់គ្រងភ័ស្តុភារតំបន់៤១ដែលមានទីតាំងនៅព្រៃទទឹង ។ ភ័ស្តុភារតំបន់មានតួនាទីដឹកអង្ករ ត្រី ប្រហុក ត្រីងៀត ត្រីឆ្អើរ ពីទន្លេសាបយកទៅចែកជូនបងប្អូនកម្មករចម្ការកប្បាស ក្រសួង-មន្ទីរក្នុងតំបន់ អង្គភាពទ័ព និងក្រសួងពាណិជ្ជកម្មជាដើម ។

ពេលនោះ មានកម្មាភិបាលខ្មែរក្រហមរាប់រយនាក់ធ្វើការងារនៅក្នុងតំបន់៤១ តែបានបែងចែកទៅជាក្រុមផ្សេងៗ ដូចជា៖ ក្រុមកងការពារ ក្រុមនីរសារ ក្រុមបើកឡាន និងកងភ័ស្តុភារ ។ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦ ប្រជាជនបានធ្វើការងាររួម ហូបបាយរួមនៅតាមសហករណ៍ តែរបបហូបចុកពេលនោះមិនគ្រប់គ្រាន់ទេ ថែមទាំងមានការចាប់ប្រជាជនថ្មីចាស់មួយចំនួនទៀតផង ជាពិសេសប្រជាជនដែលទើបតែជម្លៀសមកពីក្រុងភ្នំពេញ ។ អង្គការបានចាប់ខ្លួនប្រជាជនទាំងនោះយកទៅដាក់មន្ទីរសន្តិសុខតំបន់នៅក្រូច-គរ ឬយកទៅសម្លាប់ចោលតែម្តង ។ កាន់ ធ្លាប់បានសុំអង្គការមកលេងស្រុកកំណើតម្តង ទើបដឹងថាប្រជាជនរស់នៅតាមសហករណ៍ខ្វះខាតអាហារ និងធ្លាក់ខ្លួនឈឺជាបន្តបន្ទាប់ ដែលខុសពីអង្គភាពតំបន់របស់គាត់ដែលមានអាហារហូបចុកគ្រប់គ្រាន់មិនអត់ឃ្លានដូច្នេះឡើយ ។

នៅឆ្នាំ១៩៧៧ កាន់ ឃើញកម្មាភិបាលជាច្រើននាក់មកពីភូមិភាគនិរតីមកធ្វើការងារនៅកន្លែងគាត់ ដោយយកទាំងន័ក្កលរនាស់មកជាមួយផង ។ កម្មាភិបាលខ្លះមានក្រុមគ្រួសារមកជាមួយ ខ្លះទៀតមកតែឯង ។ ពេលមកដល់ គណៈតំបន់ចាស់បានធ្វើពិធីស្វាគមន៍ និងមានកម្មវិធីជប់លៀងជូនកម្មាភិបាលមកពីភូមិភាគនិរតីដែលមាន តាអាន ជាតំណាង (ក្រោយមកឡើងជាគណៈតំបន់៤១ថ្មី) ។ ដំបូងគណៈតំបន់ចាស់ មិត្តស្រេង មិត្តតាំង ធ្វើការងារជាមួយគណៈតំបន់ថ្មីបានល្អ បន្តិចក្រោយមក ស្រាប់តែមានការចាប់ខ្លួនគណៈតំបន់ចាស់ ទាំងមិត្តស្រេង មិត្តតាំង, មិត្តហោ ប្រធានភ័ស្តុភារ និង មិត្តសោ គណៈស្រុកព្រៃឈរ ដាក់ឡានហ្ស៊ីបយកទៅបាត់អស់ទើបធ្វើឲ្យកម្មាភិបាលថ្នាក់ក្រោមដែលនៅសេសសល់មួយចំនួនភ័យខ្លាចគ្រប់គ្នា ។ កាន់ បានឃើញយោធារបស់ តាអាន ចាប់ចង មិត្តហោ បោះឡើងលើឡានដោយផ្ទាល់ភ្នែក តែមិនដឹងដឹកយកទៅខាងណានោះទេ ។ កាន់ បានដឹងថា យោធាតំបន់៤១ ដែលមានឈ្មោះ មិត្តសុខ មិត្តទ្រី និងប្រធានមន្ទីរតំបន់ឈ្មោះ មិត្តអាំ មិត្តអួន សុទ្ធតែជាកម្មាភិបាលមកពីភូមិភាគនិរតី ។ យោធាតំបន់របស់ តាអាន បានចាប់កូនចៅតាអាន ផ្ទាល់ឈ្មោះ មិត្តអាំ យកទៅបាត់ដែរ ទោះបី មិត្តអាំ មានប្រពន្ធឈ្មោះ មិត្តនារី យុត ជាគណៈស្រុកកំពង់សៀមក៏មិនអាចជួយ

ប្ដីបានដែរ ។

នៅចន្លោះឆ្នាំ១៩៧៧-៧៨ កម្មាភិបាលចាស់ចាប់ពីគណៈឃុំ រហូតដល់ថ្នាក់ស្រុក ត្រូវបានកម្មាភិបាលមកពីនិរតីចាប់ខ្លួនស្ទើរតែទាំងអស់ រួចហើយដាក់កម្មាភិបាលថ្មីមកគ្រប់គ្រងជំនួសវិញ ។ ចំពោះការចាប់ខ្លួន គឺតំបន់ឲ្យនីរសារយកសំបុត្រទៅអញ្ជើញកម្មាភិបាលចាស់ៗទាំងនោះមកប្រជុំនៅមន្ទីរតំបន់ ។ ពេលកម្មាភិបាលទាំងនោះមកដល់ភ្លាម ប្រធានយោធាឈ្មោះ មិត្តអួន បានដឹកនាំកម្លាំងយោធារាប់រយនាក់ ក្រោមបញ្ជារបស់ តាអាន មកចាប់កម្មាភិបាលទាំងនោះចងដាក់លើឡានតែម្ដង ដោយចោទថា “ក្បត់អង្គការ” ។ អ្នកទោសដែលជាប្រជាជនធម្មតា ភាគច្រើនអង្គការចាប់ដាក់ឡានប្អូបណ្ដើរយកទៅដាក់នៅមន្ទីរសន្តិសុខក្រូច-គរ ដែលមាន មិត្តសុបជាប្រធាន ។ តែមិនយូរប៉ុន្មាន ប្រធានមន្ទីរសន្តិសុខឈ្មោះ មិត្តសុបនោះក៏ត្រូវអង្គការចាប់ខ្លួនដែរ ហើយ មិត្តហង់ ដែលឡើងជំនួសក៏ត្រូវអង្គការចាប់ខ្លួនបន្តទៀត ។ ចុងក្រោយ មិត្តង៉ូវ មកពីភូមិភាគនិរតីនៅគ្រប់គ្រងគុកនេះ ។

នៅឆ្នាំ១៩៧៨ តាអាន បានដឹកនាំកម្លាំងយោធាផ្ទាល់ចំនួន ១០នាក់ ដោយមានកាំភ្លើងគ្រប់ដៃ ជិះឡានទៅចាប់ មិត្តកាន់ ដែលមានតួនាទីជាអនុប្រធានភ័ស្ដុភាតំបន់៤១ ។ តាអាន បានចោទថា មិត្ត កាន់ បានដឹកស្បៀងយកទៅឲ្យខ្មាំងនៅទឹកឆាចំនួន៤០ឡាន ប៉ុន្តែពេលនោះ មិត្តកាន់ ឆ្លើយតបទៅ តាអាន វិញថា “អឺ! ខ្ញុំបានដឹកស្បៀងឲ្យកម្មករចម្ការកប្បាស និងកម្មករនៅក្រសួងពាណិជ្ជកម្ម មិនមែនចំនួន៤០ឡានទេ គឺរាប់រយឡានឯណោះ ។ ខ្ញុំមិនបានដឹងថា កម្មករនៅក្នុងសហជីពទាំងនេះជាខ្មាំងទេ អ៊ីចឹងអ៊ីចាត់ទុកថា កម្មករទាំងអស់នោះជាខ្មាំងដែរឬ? បើអ៊ីចាប់ខ្ញុំថ្ងៃនេះ ថ្ងៃក្រោយអ៊ីក៏មិនរួចខ្លួនដែរ” ។ ពេលស្ដាប់ហើយ តាអាន បាននិយាយទៅ កាន់ ថា “មិត្តត្រូវតាំងស្មារតីឡើង និងខិតខំធ្វើការងារវិញ ព្រោះបើតាមសំបុត្រដែលបោះត្រាចេញពីមន្ទីរសន្តិសុខក្រូច-គរ គឺត្រូវចាប់ មិត្តឯង (កាន់) តែឥឡូវមិត្តឯងនៅធ្វើការបន្តទៀតចុះ” រួចហើយ តាអាន ក៏នាំកម្លាំងយោធាត្រឡប់ទៅតំបន់វិញ ។ ចាប់ពីពេលនោះ កាន់ ក៏លែងមានអារម្មណ៍ភ័យខ្លាច ព្រោះគាត់គិតថា ថ្ងៃនេះបានរួចខ្លួន តែថ្ងៃក្រោយប្រាកដជាជាមិនបានរួចខ្លួនទេ តែគាត់ក៏មិនរង់ចាំឲ្យយោធាមកចាប់ខ្លួនដែរ ។ កាន់ ក៏មានសំណាងល្អដែរដោយមានមិត្តភក្ដិចាស់ឈ្មោះ សុទ្ធ ធ្វើការងារនៅភ័ស្ដុភារជាមួយគ្នា បានស្រឡាញ់មិត្តនារី កាន់ ប្រធានភ័ស្ដុភារ បន្ទាប់ពីចាប់ មិត្តហោ ។ នារី កាន់ មកពីភូមិភាគនិរតី ត្រូវជាសាច់ញាតិ តាអាន ។ តាអាន បានដឹងច្បាស់ថា មិត្តសុទ្ធ និងមិត្តកាន់ លួចស្រឡាញ់គ្នា ហើយ តាអាន ក៏យល់ព្រមរៀបការឲ្យដោយមិនយកទោសពៃរ៍ដែរ ។

នៅពាក់កណ្ដាលឆ្នាំ១៩៧៨ តាអាន បានកោះហៅថ្នាក់ដឹកនាំធំៗ នៅក្នុងតំបន់ និងកម្មករមួយចំនួនមកប្រជុំនៅវត្តតាមះ ។ តាអាន បាននិយាយពីគោលនយោបាយបក្ស ប្រវត្តិតស៊ូរបស់ ប៉ុល ពត ដែលខិតខំដើម្បីជាតិ ព្រមទាំងលើកពីគោលនយោបាយយួនឈ្លានពានទឹកដី និងឲ្យអ្នកចូលរួមប្រជុំតស៊ូទាំងអស់គ្នា ទោះបីមានបញ្ហាផ្ទៃក្នុងខ្លះមិនទាន់បានដោះស្រាយរួចក៏ដោយ និងឲ្យប្រុងប្រយ័ត្នជានិច្ច ។ នៅពេល តាអាន ប្រជុំគ្មាននរណាហ៊ាននិយាយស្ដីទេ ម្នាក់ៗខិតខំស្ដាប់ដោយយកចិត្តទុកដាក់ និងប្រុងប្រយ័ត្ន ព្រោះពេលប្រជុំមុនៗមានការចាប់មនុស្សមួយចំនួនរួចមកហើយដែរ ។

នៅឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមកដល់ប្រទេសកម្ពុជា តាអាន និងកម្មាភិបាលមួយចំនួនបានរត់គេចខ្លួន ព្រោះខ្លាចប្រជាជនសងសឹក ។ ចំណែក កាន់ ក៏រត់តាមពួកនិរតីបានមួយរយៈខ្លីដែរ រួចហើយក៏សម្រេចចិត្តវិញមកស្រុកកំណើតវិញ ។ នៅឆ្នាំ១៩៨០ កាន់ បានរៀបការប្រពន្ធនិងមានកូនស្រីមួយក៏លែងលះគ្នាវិញ ។ រហូតមកសព្វថ្ងៃ កាន់ មិនយកប្រពន្ធទេ គាត់សម្រេចចិត្តមករស់នៅជាមួយព្រះសង្ឃក្នុងវត្តភូមិវាល រៀនធម៌ដើម្បីសន្សំបុណ្យកុសល្យទៅជាតិខាងមុខ ។

**សុខ ខណ្ណៈ**



ប្រជាជនកម្ពុជាវិលត្រឡប់មកស្រុកកំណើត ក្រោយរបបខ្មែរជួលរលំឆ្នាំ១៩៧៩

# អតីតកងការពារ និងអ្នកបើក ឡានឱ្យលេខាតំបន់៤១ ភូមិភាគកណ្ដាល



អ៊ឹម ប៊ុន នៅផ្ទះរបស់គាត់

អ៊ឹម ប៊ុន អាយុ៦២ឆ្នាំ អតីតកងការពារ និងអ្នកបើកឡានឲ្យ តាអាន លេខាតំបន់៤១ ភូមិភាគកណ្ដាល ។ ប៊ុន មានស្រុកកំណើតនៅស្រុកឈូក ខេត្តកំពត ។ ជាកូនទី៣ក្នុងចំណោមបងប្អូន៨នាក់ នៅក្នុង គ្រួសារកសិករ ប៊ុន រៀនសូត្របានត្រឹមថ្នាក់ទី៩ចាស់ប៉ុណ្ណោះ បន្ទាប់ពីមានរដ្ឋប្រហារឆ្នាំ១៩៧០ ពីព្រោះស្ថានភាពនៅក្នុងភូមិកើតចលាចល ហើយអ្នកភូមិជាច្រើនត្រូវបានបង្ខំជ្រើសរើសឲ្យធ្វើទាហាន ដូច្នេះហើយទើបបានជាឪពុកម្ដាយរបស់គាត់មិនអនុញ្ញាតឲ្យគាត់ទៅសាលា ។ បន្ទាប់ពីឈប់រៀន ប៊ុន បានមកជួយធ្វើស្រែចម្ការឪពុកម្ដាយវិញ ។

រហូតដល់ឆ្នាំ១៩៧០ ប៊ុន បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ ហើយក្រោយមកត្រូវបាន តាញឹប យកទៅធ្វើការជាមួយនៅសាលាស្រុកកោះស្លា ។ ដំបូង តាលីម ជាគណៈស្រុកកោះស្លា តែក្រោយមកត្រូវបានផ្លាស់ចេញ ទើប តាញឹប ឡើងជាគណៈស្រុកជំនួសវិញ ។ ពេលនោះដោយសារតែនៅតូចពេក ទើប ប៊ុន ត្រូវបានចាត់តាំងឲ្យធ្វើជានីសាររត់សំបុត្រពីស្រុកកោះស្លាទៅតាមភូមិ ឃុំ និងស្រុក មានដូចជា៖ ស្រុកកំពត ខាងលិច, ស្រុកកំពតខាងកើត, ស្រុកទូកមាស, ស្រុកកំពង់ត្រាច, ស្រុកស្រែក្នុង និង ស្រុកឈូក ។ ស្រុកទាំងអស់នេះ ស្ថិតនៅក្នុងតំបន់៣៥ ដែលមាន តាចាប ជាលេខាតំបន់ ហើយ តារិន និង តាអាន ជាអនុលេខាតំបន់ ។

នៅឆ្នាំ១៩៧៤ ប៊ុន បានផ្លាស់ទៅមន្ទីរកាត់ដេរនៅម្ដុំដងទង់ចាស់ ។ អង្គភាពកាត់ដេរនេះ គឺត្រូវផ្គត់ផ្គង់សម្ភារទៅសមរភូមិមុខ ។ រយៈពេលមួយខែក្រោយមក ប៊ុន ត្រូវបានបញ្ជូនបន្តទៅចម្ការកប្បាស នៅជិតដំណាក់ចង្អើរ និងកែប ។ នៅកងកុមារ ប៊ុន ត្រូវទៅយាមការពារក្រុមនារីៗដែលត្រូវទៅសែងយោធារងរបួសពីសមរភូមិមុខរហូតដល់រំដោះឆ្នាំ១៩៧៥ ។

ក្រោយរំដោះភ្លាម ប៊ុន ត្រូវបានចាត់តាំងឲ្យទៅបោសសម្អាតទីក្រុងកំពតរយៈពេលមួយសប្ដាហ៍ ទើបត្រូវបានបញ្ជូនឲ្យទៅយាមចម្ការធុរេន និងសាវម៉ាវ នៅម្ដុំទឹកឈូវិញ ។ ពេលនោះមានកុមារចំនួន៣០នាក់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ដុន និង នី ។ នៅដើមឆ្នាំ១៩៧៦ ប៊ុន ត្រូវបានបញ្ជូនបន្តទៅនៅទូកមាសអស់រយៈពេលជាច្រើនខែទៀត ។ ក្រោយមក គាត់ត្រូវបានផ្លាស់មកកាន់ព្រលានយន្តហោះចាស់ នៅជិតភ្នំកែសដើម្បីធ្វើស្រែ និងមើលថែរក្សាយន្តហោះចាស់ៗដែលត្រូវបានបោះបង់ចោល ។ បន្ទាប់មក ប៊ុន ត្រូវបានបញ្ជូនទៅធ្វើការជាមួយ តាចាប គណៈតំបន់៣៥ នៅទីរួមខេត្តកំពត ។ ប៊ុន ត្រូវបានតែងតាំងជាអ្នកទទួលភ្ញៀវ ជាពិសេសទទួលគណៈប្រតិភូចិន និងកូរ៉េខាងជើងដែលបានមកទស្សនកិច្ចនៅកម្ពុជា ។ នៅពេលនោះ តាអាន និង តារិន បានមកធ្វើការនៅមន្ទីរតំបន់ម្ដងម្កាលប៉ុណ្ណោះ ដោយមិនបានស្នាក់នៅធ្វើការជាអចិន្ត្រៃយ៍ ដូចតា ចាប ឡើយ ។ នៅពេលនោះ លាប ជាប្រធានមន្ទីរតំបន់ ។

នៅពាក់កណ្ដាលឆ្នាំ១៩៧៧ អួន ជាកម្មាភិបាលនៅមន្ទីរតំបន់៣៥ ដែលមានប្រពន្ធឈ្មោះ ផុក និងប្អូនថ្លៃឈ្មោះ ពឹត និង ប៊ុន ត្រូវបានយាយ យុត ជាអតីតកម្មាភិបាលតំបន់៣៥ ដែលបានផ្លាស់ទៅ (ធ្វើការនៅខេត្តកំពង់ចាម) យកទៅនៅជាមួយ ។ មុនពេលបញ្ជូន ប៊ុន ទៅធ្វើការនៅខេត្តកំពង់ចាម តាចាប លេខាតំបន់៣៥ ក៏

ត្រូវបានផ្លាស់ទៅធ្វើការនៅតំបន់សៀមរាបដែរ ដោយ តាបិត បានឡើងជាលេខាតំបន់៣៥ ជំនួសវិញ ។ នៅតាមផ្លូវទៅកំពង់ចាម ប៊ុន និងអ្នកផ្សេងទៀត បានសម្រាកនៅមន្ទីរចម្ការកៅស៊ូ នៅភ្នំពេញមួយយប់ ។ នៅព្រឹកបន្ទាប់ ប៊ុន បានបន្តដំណើរតាមរថយន្តរហូតដល់មន្ទីរតំបន់៤១ ស្ថិតនៅព្រៃទទឹង ។ នៅទីនោះ ប៊ុន ត្រូវបានចាត់តាំងឲ្យធ្វើជានីរសាររបស់ អួន ប្រធានមន្ទីរតំបន់៤១ ដែលទើបតែត្រូវបានតែងតាំងថ្មីបន្ទាប់ពី តាអាំ ត្រូវបានផ្ទេរចេញ ។ ដោយសារ ប៊ុន ជានីរសារតំបន់ ទើបអាចចំណាំកម្មាភិបាលមួយចំនួនដែលធ្វើការនៅក្នុងមន្ទីរតំបន់ និងផ្នែកសន្តិសុខមានដូចជាៈ

ទី១) សុខ មកពីកំពង់ឆ្នាំង ជាប្រធានកងការពារ និងនីរសារលេខាតំបន់៤១ (ត្រូវបានកងទ័ពវៀតណាមបាញ់សម្លាប់នៅឆ្នាំ១៩៧៩) ។

ទី២) សៅ ធ្វើការនៅមន្ទីរតំបន់ (ក្រោយមកបានស្លាប់)

ទី៣) វ៉ែន ជានីរសារតំបន់

ទី៤) ថន ជានីរសារតំបន់ (ក្រោយមកបានស្លាប់)

ទី៥) ហឺ ជាប្រធានយោធាតំបន់ (ក្រោយមកត្រូវបានចាប់យកទៅសម្លាប់)

ទី៦) ទ្រី ជាអនុយោធាតំបន់ ក្រោយរំដោះឆ្នាំ១៩៧៩ ទ្រី ភៀសខ្លួនទៅនៅជំរំក្នុងទឹកដីថៃ (ក្រោយមក ឮថាគាត់ត្រូវបានបាញ់ស្លាប់នៅក្នុងសមរភូមិ នៅឆ្នាំ១៩៩៣)

និងទី៧) ង៉ូវ ជាប្រធានមន្ទីរសន្តិសុខតំបន់ ៤១ ស្ថិតនៅក្រូច-គរ (បច្ចុប្បន្នរស់នៅខេត្តឧត្តរមានជ័យ) ។

ខណៈពេល ប៊ុន កំពុងធ្វើជានីរសារនៅមន្ទីរតំបន់ម្តងម្កាល តាអាន បានមកយកគាត់ទៅជួយការពារ ពេលដែល តាអាន ចុះទៅតាមមូលដ្ឋាន ។ បន្ទាប់ពី តាចាប ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៨ ប៊ុន ត្រូវបានជ្រើសរើសជាអ្នកបើកឡានឲ្យលេខាតំបន់ តាអាន ពេលចុះទៅប្រជុំ និងបំពេញបេសកកម្ម នៅតាមស្រុក និងសហករណ៍ ជំនួសឲ្យអតីតតៃកុងឡានរបស់គាត់ឈ្មោះ ឡាយ ដែលត្រូវបានចោទថា ខុសសីលធម៌ និងបានផ្ទេរទៅខាងនិរតីវិញ ។ ក្រោយមក ប៊ុន បានទទួលដំណឹងថា ឡាយ ត្រូវបានចាប់យកទៅសម្លាប់ បន្ទាប់ពីត្រឡប់មកតំបន់៤១វិញ ដើម្បីជួបនារីដែលខ្លួនស្រលាញ់ ។

តាអាន មានកាលវិភាគសម្រាប់ចុះទៅបំពេញការងារនៅតាមស្រុក និងសហករណ៍ ។ ចំណែកគណៈស្រុកក៏ឡើងទៅប្រជុំនៅមន្ទីរតំបន់ជាប្រចាំខែដែរ ។ ពេលចុះបំពេញបេសកកម្មម្តងៗ តាអាន ធ្វើដំណើរតាមឡានហ្ស៊ីប ដោយមានតែតៃកុងឡាន និងកងការពារបីបួននាក់ប្រដាប់ដោយកាំភ្លើងអមទៅជាមួយ មានដូចជាៈ

ទី១) ឡាយ ជាតៃកុងឡានរបស់ តាអាន ឡាយ ត្រូវបានចោទពីបទខុសសីលធម៌ បន្ទាប់ពីបានស្រលាញ់នារី វ៉ែន រួចហើយត្រូវបានបញ្ជូនទៅនិរតីវិញ ។ ក្រោយមក ឡាយ ត្រូវបានចាប់យកទៅសម្លាប់ (បន្ទាប់ពីត្រឡប់មកជួបនារីដែលខ្លួនស្រលាញ់)

ទី២) ម៉ូយ ជាអ្នកបើកឡានតំបន់៤១ដែរ ប៉ុន្តែក្រោយ មកត្រូវបានបញ្ជូនឲ្យទៅបើកត្រាក់ទ័រវិញ (ម៉ូយ បានស្លាប់ដោយសារជំងឺកាលពី៧-៨ឆ្នាំមុន)

ទី៣) ប៊ុន បានក្លាយជាអ្នកបើកឡាន ឲ្យ តាអាន បន្ទាប់ពី ឡាយ ត្រូវបានដកចេញនៅក្នុងឆ្នាំ១៩៧៨ ។

ទី៤) មឿន បានក្លាយជាអ្នកបើកឡានឲ្យតំបន់ បន្ទាប់ពី ម៉ូយ បានផ្លាស់ទៅអង្គភាពត្រាក់ទ័រ (មឿន បានស្លាប់ ដោយសារតែដើរជាន់មីន (នៅក្នុងទឹកដីថៃ)

ទី៥) ផន ជាកងការពាររបស់ តា អាន

និង ទី៦) ស៊ឹម នៅខាងខេត្តកំពង់ចាម ជាកងការពាររបស់តាអាន (ស៊ឹម ស្លាប់ដោយសារជំងឺកាលពី៣-៤ឆ្នាំមុន) ។

បន្ទាប់ពីកំណត់ផែនការចាប់ប្រជាជន ជនសង្ស័យរួចមក ហឺ ដែលជាប្រធានយោធាតំបន់ត្រូវបានចាត់តាំងដោយគណៈតំបន់ឲ្យចុះអនុវត្តកិច្ចការនេះ ។ ប៊ុន បានឃើញប្រជាជនត្រូវបានចាប់បញ្ជូនទៅគុកក្រូច-គរ ប៉ុន្តែគាត់មិនដឹងថាអ្នកជាប់ឃុំទាំងនោះក្រោយមកត្រូវបានបញ្ជូនបន្តទៅទីណានោះទេ ។ ប៊ុន បានបញ្ជាក់ថា វត្តតាមះ គឺជាអតីតគុកខ្មែរក្រហម ។ ប៉ុន្តែបន្ទាប់ពីគុកក្រូច-គរ ត្រូវបានបង្កើតឡើង ប្រជាជនដែលត្រូវបានចាប់ខ្លួន ត្រូវបានបញ្ជូនទៅឃុំឃាំងនៅក្នុងគុកនេះវិញ ។ នៅក្នុងឆ្នាំ១៩៧៨ តាង៉ូវ បានក្លាយជាប្រធានគុកក្រូច-គរ ។ មុនការបញ្ជូនមកទទួលតួនាទីនៅខាងកំពង់ចាម តាង៉ូវ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់តាអាំ ដែលជាប្រធានគុកតំបន់៣៥ ។ ក្រោយការរំដោះឆ្នាំ១៩៧៩ តាង៉ូវ និងប្រពន្ធបានភៀសខ្លួនទៅជាយដែនប្រទេសថៃ ។ តាអាំ ប្រធានមន្ទីរតំបន់៤១ និង ហឺ ប្រធានយោធាតំបន់ ត្រូវ

កម្មាភិបាលមកពីខេត្តកំពត ចាប់នៅក្រោមផ្ទះ និងយកទៅសម្លាប់ដោយសារជាប់ខ្សែបណ្តាញជាមួយ តាចប ដែលត្រូវបានចាប់ខ្លួនមុននោះ ។

ក្នុងអំឡុងរយៈកាលនៃការគ្រប់គ្រងរបស់ តាអាន តំបន់៤១ ត្រូវបានចែកចេញជា៥ស្រុក ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈស្រុក មានរាយនាមដូចតទៅៈ

ទី១) កាន មកពីខេត្តតាកែវ ជាគណៈស្រុកកងមាស (កាន ជាអតីតមេបញ្ជាការកងទ័ពភូមិភាគនិរតី)

ទី២) យាយ យុត ជាគណៈស្រុកកំពង់សៀម តាស៊ី បានក្លាយជាគណៈស្រុក បន្ទាប់ពីយាយ យុត ត្រូវបានផ្ទេរចេញ មុនពេលចាប់ប្តីរបស់គាត់ ។ ក្រោយមក តាជា ត្រូវបានដំឡើងជាគណៈស្រុកជំនួស តាស៊ី ដែលបានផ្លាស់ទៅទឹកឆា (តាជា បានបាញ់សម្លាប់ខ្លួននៅក្នុងព្រៃ)

ទី៣) តា ស៊ីម ជាអនុប្រធានតំបន់៤១ និងគណៈស្រុកព្រៃឈរ (ក្រោយមកគាត់ត្រូវបានបញ្ជូនឲ្យធ្វើជាគណៈតំបន់៤៣)

ទី៤) តាមុន ជាគណៈស្រុកជើងព្រៃ ប៉ុន្តែក្រោយមកគាត់បានស្លាប់ដោយសារជំងឺគ្រុនចាញ់ នៅមុំស្រែរំដួលក្នុងស្រុកស្ទឹងត្រង់ ក្នុងឆ្នាំ១៩៧៩

ទី៥) តា ភីម ហៅ ផល ជាគណៈស្រុកបាធាយ ។ បន្ទាប់ពី សោ ភឹម គណៈភូមិភាគបូព៌ាត្រូវបានចាប់ខ្លួន ភីម បានប្តូរឈ្មោះរបស់ ខ្លួនទៅជា ផល ដើម្បីជៀសវាងការយល់ច្រឡំណាមួយកើតឡើង ។ ភីម បានស្លាប់នៅមុំស្រុកកំពង់សៀម នៅឆ្នាំ១៩៨១ ។ តាមការពិត ភីម ត្រូវបានបាញ់សម្លាប់ដោយនីសាររបស់ខ្លួន ។ បន្ទាប់ពីបាញ់សម្លាប់ ភីម ហើយ នីសារ និងកងការពារសេសសល់ទាំងនោះបានចូលមកសារភាពជាមួយកងទ័ពវៀតណាម និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

ក្រៅពីនេះ តាអាន ក៏បានឡើងទៅប្រជុំនៅភូមិភាគមជ្ឈិម ស្ថិតនៅទីរួមខេត្តកំពង់ចាម ។ ពេលនោះ កែ ពក ជាគណៈភូមិភាគមជ្ឈិម ហើយ តាអាន ជាអនុប្រធានភូមិភាគ ។ ភូមិភាគមជ្ឈិម បានបែងចែកជា៣តំបន់ ដែលមានគណៈគ្រប់គ្រងដូចជាៈ

ទី១) តា អាន ជាគណៈតំបន់៤១

ទី២) តា អឿន (ប្អូនថ្លៃរបស់កែ ពក) ជាគណៈតំបន់៤២

និងទី៣) តាផែន ជាគណៈតំបន់៤៣ ។ ក្រោយមក តាស៊ីម បានក្លាយជាគណៈតំបន់៤៣ជំនួស តាផែន ដែលត្រូវបានផ្ទេរចេញជាមួយយាយ យុត ។ ប្រពន្ធរបស់ តាស៊ីម ឈ្មោះ យាយ សេម ជាប្រធានមន្ទីរពេទ្យតំបន់៤១ ។

ស្របពេលជម្លោះរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម បានផ្ទុះឡើងនៅតាមព្រំដែន កងទ័ពមជ្ឈិមត្រូវបានបញ្ជូនទៅធ្វើសង្គ្រាម ។ ចំណែកកងទ័ពតំបន់៤១ក្រោមការបញ្ជារបស់ តាអាន ត្រូវបានបញ្ជូនឲ្យទៅចាប់កម្មាភិបាលនៅក្នុងស្រុកកោះសូទិន ។ នៅពេលកងទ័ពវៀតណាមបើកការវាយប្រហារចូលមកដល់ តា អាន បានបញ្ជាឲ្យ ប៉ុន ដឹកជញ្ជូនប្រជាជនពីភូមិភាគបូព៌ាទៅដាក់នៅស្រុកព្រៃឈរ ប៉ុន្តែគាត់មិនដឹងថា ប្រជាជនទាំងនោះត្រូវបានជម្លៀសបន្តទៅខាងទៀតនោះទេ ។

ក្រោយពីកងទ័ពវៀតណាមរំដោះប្រទេសកម្ពុជារួច ប៉ុន បានភៀសខ្លួនចេញពីតំបន់៤១ទៅភាគខាងលិចប្រទេស ។ ប៉ុន្តែ នៅតាមផ្លូវ កងកម្លាំងខ្មែរក្រហមនៅតែបន្តធ្វើសង្គ្រាមជាមួយកងទ័ពវៀតណាមដែលដេញតាមពីក្រោយ ។ កងទ័ពខ្មែរក្រហមបានវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម រហូតទៅដល់កំពង់ឆ្នាំង ។ នៅអំឡុងពេលនោះ ប៉ុន បានបែកផ្លូវពីអង្គភាពទ័ពរបស់ខ្លួន ហើយសម្រេចចិត្តវិលត្រឡប់មកភូមិកំណើតរបស់ខ្លួនវិញ ។ បន្ទាប់ពីមកនៅក្នុងភូមិបានមួយរយៈ អ្នកភូមិបានកើតមានការសង្ស័យទៅលើ ប៉ុន ដែលធ្លាប់ធ្វើការនៅភូមិភាគកណ្តាល ។ ដូច្នេះ ប៉ុន ក៏បានសម្រេចចិត្តចាកចេញពីភូមិទៅជួបអង្គភាពយោធារបស់ខ្លួនដោយចៃដន្យនៅអមលាំង ក្នុងខេត្តកំពង់ឆ្នាំង ។ ប៉ុន បានធ្វើជាកងទ័ពភូមិភាគកណ្តាលម្តងទៀត ហើយបានបន្តវាយនៅសមរភូមិផ្សេងៗ ។ អង្គភាពរបស់ ប៉ុន បានបើកសមរភូមិវាយប្រហារតាមផ្លូវជាតិលេខ៦ រហូត វាយបានស្ទឹងត្រង់ អូរ-២ និងស្រែរំដួល ។ ក្រោយមក ប៉ុន បានជួបជាមួយ តាអាន ដោយមិនបានរំពឹងទុក ។ ប៉ុន បានបែកពី តាអាន ចាប់តាំងពី តាអាន បានរត់ភៀសខ្លួនទៅលើភ្នំដងរែក ។

នៅឆ្នាំ១៩៨២ ប៉ុន បានរៀបការប្រពន្ធ ហើយនៅឆ្នាំ ១៩៨៧ គាត់ និងគ្រួសារបានផ្លាស់ទៅរស់នៅជំរំអូរគ្រាវ នៅក្នុងទឹកដីថៃ ។ នៅឆ្នាំ១៩៩៧ ប៉ុន និងគ្រួសារបានធ្វើមាតុភូមិនិវត្តន៍មករស់នៅភូមិខាងប្រពន្ធវិញរហូតដល់សព្វថ្ងៃ ។ **ស៊ាន ចិន្តា**

# យក់ ង៉ូវ អតីតប្រធានមន្ទីរសន្តិសុខតំបន់៤១ ភូមិភាគកណ្តាល

យក់ ង៉ូវ មានស្រុកកំណើតនៅស្រុកឈូក ខេត្តកំពត ។ ជាកូនដែលកើតក្នុងត្រកូលកសិករ ដែលមានបងប្អូនប្រុសស្រី៨នាក់ ង៉ូវ បានរៀនសូត្រត្រឹមថ្នាក់ទី២ "ចាស់" ប៉ុណ្ណោះ ។ ង៉ូវ រៀននៅវិទ្យាល័យឈូក ។ នៅអំឡុងឆ្នាំ១៩៧០ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ សង្គ្រាមក៏បានផ្ទុះឡើងស្ទើរទូទាំងប្រទេស ។ សាលារៀនមួយចំនួនត្រូវបានបិទទ្វារ ក្នុងនោះក៏មានសាលារបស់ ង៉ូវ ដែរ ។ ង៉ូវ បានត្រឡប់មកជួយធ្វើស្រែចម្ការឪពុកម្តាយវិញ ។ ដោយប្រធានភូមិដឹងថា ង៉ូវ រៀនបានច្រើន គាត់បានឲ្យ ង៉ូវ ជួយបង្រៀនក្មេងៗនៅក្នុងភូមិ ។ បន្ទាប់ពីបង្រៀនបានមួយឆ្នាំ ង៉ូវ បានសម្រេចចូលធ្វើជាកងទ័ពបដិវត្តន៍ ព្រោះភូមិស្រុកដែល ង៉ូវ រស់នៅត្រូវខ្មែរក្រហមរំដោះ តាំងពីពេលរដ្ឋប្រហារមកម្ល៉េះ ។ ង៉ូវ ចូលបដិវត្តន៍ដំបូងធ្វើជាទ័ពការពារស្រុកឈូក ដោយមាន តាចេន ជាអ្នកគ្រប់គ្រងខាងទ័ពស្រុកឈូក ។

នៅឆ្នាំ១៩៧២ ង៉ូវ បានផ្លាស់ទៅបម្រើជាកងទ័ពប្រចាំតំបន់៣៥ ដែលមាន កង ចាប ជាគណៈតំបន់ ។ ការងារជាទ័ពតំបន់មានការមមាញឹកជាងទ័ពស្រុក ព្រោះពេលខ្លះត្រូវទៅប្រយុទ្ធនៅសមរភូមិជុំវិញក្រុងកំពត និងត្រូវរក្សាសន្តិសុខឲ្យស្រុក និងខេត្តផង ។ ង៉ូវ ពេលនោះមានតួនាទីជាប្រធានអនុសេនាតូច ដែលស្ថិតក្រោមការគ្រប់គ្រងរបស់មេបញ្ជាការកងទ័ពតំបន់ឈ្មោះ រឿន ។ ង៉ូវ នៅធ្វើជាកងទ័ពតំបន់រហូតដល់ឆ្នាំ១៩៧៦ ។ ក្រោយមកគាត់ត្រូវបានអង្គការដកឲ្យមកធ្វើជាកម្មាភិបាលនៅមន្ទីរតំបន់៣៥ ដែលមាន តាអាំ ប្រធានមន្ទីរតំបន់៣៥ ។ ពេលធ្វើការនៅក្នុងមន្ទីរតំបន់នេះ ង៉ូវ បានរៀបការជាមួយនារី ឈ្មោះ វន ។ ចំណែក តាអាំ ក៏បានផ្លាស់មកបម្រើការងារនៅកំពង់ចាម និងក្រោយមក តាអាំ



យក់ ង៉ូវ នៅផ្ទះរបស់គាត់

បានមកយក ង៉ូវ និងប្រពន្ធ ពីមន្ទីរតំបន់៣៥ នៅកំពតទៅធ្វើការនៅកំពង់ចាមជាមួយ ។ ង៉ូវ និងប្រពន្ធ បានធ្វើដំណើរមកកំពង់ចាមជាមួយប្រពន្ធៗរបស់កម្មាភិបាលដែលទៅបម្រើការនៅកំពង់ចាមមុនៗ ។ ឡានរបស់ ង៉ូវ បានចេញដំណើរពីកំពតមកសម្រាកនៅភ្នំពេញ មួយយប់ទើបបន្តដំណើរទៅមន្ទីរតំបន់៤១ នៅព្រៃទទឹងក្នុងស្រុកព្រៃឈរ ។

ពេលដែលមកដល់មន្ទីរតំបន់៤១ ង៉ូវ ត្រូវចាត់ឲ្យធ្វើការងារនៅក្រោមការគ្រប់គ្រងរបស់ អាំ ដែលជាប្រធានមន្ទីរតំបន់ ចំណែក តាអាន ជាគណៈតំបន់៤១ ។ នៅឆ្នាំ១៩៧៨ ង៉ូវ ត្រូវបានចាត់តាំងឲ្យទៅគ្រប់គ្រងនៅមន្ទីរសន្តិសុខតំបន់៤១ ជំនួសឈ្មោះ សុប ជាអតីតកម្មាភិបាលភូមិភាគខត្តរ និងមនុស្សមួយចំនួនត្រូវអង្គការចោទថាក្បត់ ឬមានពាក់ពន្ធនឹងខ្សែក្បត់ ហើយត្រូវចាប់បញ្ជូន ទៅមន្ទីរសន្តិសុខស-២១ នៅភ្នំពេញ ដើម្បីសួរចម្លើយ និងសម្លាប់ចោលនៅឆ្នាំ១៩៧៧ ។ មន្ទីរមិត្ត សុប ឬមន្ទីរសន្តិសុខតំបន់៤១ មានទីតាំងស្ថិតនៅក្នុងភូមិក្រូច ឃុំគរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

ចំណែកប្រពន្ធរបស់ ង៉ូវ ត្រូវអង្គការចាត់តាំងឲ្យបម្រើការងារដាំបាយនៅមន្ទីរស្រុកកងមាស ដែលមានគណៈស្រុកឈ្មោះ តាកាន ។ ក្រោយពេលដែលខ្មែរក្រហមចាប់ខ្លួន តាអាំ យកទៅគឺឈ្មោះ អូន ត្រូវបានដំឡើងឲ្យធ្វើជាប្រធានមន្ទីរ និងជាប្រធានកងការពារតំបន់៤១ ។

ង៉ូវ បានឲ្យដឹងថា អ្នកទោសដែលចាប់យកមកដាក់នៅមន្ទីរសន្តិសុខក្រូច-គរនេះ គឺមិនមែនជាអ្នកទោសឧក្រិដ្ឋអីទេ គឺភាគច្រើនជាអ្នកដែលមិនសប្បាយចិត្តជាមួយសហករណ៍អំពីរឿងហូបមិនឆ្អែត បញ្ហាខុសសីលធម៌រវាងបុរស នារីជាដើម ។ ចំណែកកម្មាភិបាលដែលមកពីនិរតីដែលប្រព្រឹត្តខុស ក៏ត្រូវយកមកដាក់មន្ទីរសន្តិសុខនេះដែរ ។ យោធាតំបន់មានភារកិច្ចចាប់អ្នកទោសដាក់មន្ទីរសន្តិសុខ និងនាំអ្នកទោសចេញទៅវិញ ។ ទោះបីយ៉ាងណាក៏ដោយ ង៉ូវ បានបដិសេធថា ខ្លួនមិនបានដឹងអំពីការនាំអ្នកទោសចូល និងនាំអ្នកទោសយកទៅសម្លាប់ទេ ។ ង៉ូវ បានបន្តថា មន្ទីរសន្តិសុខក្រូច-គរនេះ ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់មន្ទីរតំបន់៤១ ។ អូន ប្រធានមន្ទីរតំបន់តែងតែចុះទៅត្រួតពិនិត្យមើលនៅមន្ទីរសន្តិសុខនេះ ។

នៅពេលដែលវៀតណាមចូលមកដល់ខេត្តកំពង់ចាមក្នុងឆ្នាំ១៩៧៩ ង៉ូវ បានទៅលេងប្រពន្ធនៅស្រុកកងមាស ។ នៅយប់នោះប្រធានមន្ទីរតំបន់បានរៀបចំប្រជុំ និងបានសម្រេចដកមន្ទីរតំបន់ទៅនៅស្រុកបាធាយវិញ ។ នៅព្រឹកថ្ងៃបន្ទាប់ពេល ង៉ូវ ត្រឡប់ពីស្រុកកងមាសវិញ គាត់ឆ្ងៀតចូលទៅមន្ទីរតំបន់ ស្រាប់តែបាត់មនុស្ស ទើបគាត់ដឹងថាកម្មាភិបាលនៅទីនេះបានរត់អស់ហើយ ។ ង៉ូវ បានស្រូតដំណើរទៅតាមដល់ស្តន់ស្រុកជើងព្រៃ នៅតែទៅមិនទាន់ទៀត ទើបគាត់ និងយុទ្ធជនកងការពាររបស់ខ្លួនម្នាក់បានជិះម៉ូតូបន្តដំណើររហូតដល់ទីរួមខេត្តកំពង់ធំ ។ ពេលទៅដល់កំពង់ធំ ង៉ូវ មិនឃើញមនុស្សទេ ទើបគាត់ត្រឡប់មកតាំងក្រសាំងវិញ និងបានជួបនឹងកម្មករចម្ការកៅស៊ូចម្ការ អណ្តូង ដែលមានឈ្មោះ តាកេត ជាអ្នកគ្រប់គ្រង ។ ង៉ូវ បាននៅជាមួយក្រុម តាកេត ។ រហូតដល់ឆ្នាំ១៩៨២ ទើបសម្រេចចិត្តឡើងភ្នំដងរែកតាមច្រក១០០១ បានជួបជាមួយ តាអាន ។ ង៉ូវ មិនបាននៅជំរំយូរទេ ព្រោះគិតថាជំរំចង្អៀតទើបសម្រេចចិត្តធ្វើទ័ពចុះមកធ្វើការត្រង់ព្រំប្រទល់ស្រុកកំពង់សៀម និងស្រុកស្ទឹងត្រង់ ។ មួយរយៈក្រោយមកទើបខ្មែរក្រហមបង្កើតជាកងពល ហើយ ង៉ូវ ស្ថិតនៅក្នុងកងពល៤១៧ របស់អតីតភូមិភាគកណ្តាល ។ ដោយសារតែវ័យកាន់តែចាស់ ង៉ូវ បានសម្រេចចិត្តឈប់ទៅសមរភូមិមុខ និងប្តូរមកស្នាក់នៅ និងធ្វើការនៅមន្ទីរកងពល៤១៧ជាមួយ តាប៉ូច វិញ ។ នៅឆ្នាំ១៩៨៧ ង៉ូវ បានជួបជុំជាមួយប្រពន្ធវិញនៅជំរំមួយនៅព្រំដែនថៃ ។ ពេលនោះប្រពន្ធ ង៉ូវ បានទទួលដំណឹងតាមរយៈកងទ័ពនៅតំបន់ ១០០១ និងនៅ១០០៣ ថា ង៉ូវ នៅរស់ ទើបតាមមករក ង៉ូវ និងបានជួបជុំគ្នាវិញ ។

បន្ទាប់ពីជួបជុំប្រពន្ធកូន ង៉ូវ ត្រូវបានចាត់តាំងឲ្យបង្រៀនកុមារនៅតាមអង្គភាពរហូតដល់ខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ១៩៩៩ ។ បន្ទាប់ពីរដ្ឋាភិបាលរៀបចំ បង្កើតជាសាលារៀន ង៉ូវ បានចុះឈ្មោះធ្វើជាគ្រូនៅសាលាបឋមសិក្សាមួយរហូតដល់ឆ្នាំ២០០២ និងបានក្លាយជានាយកនៅសាលាបឋមសិក្សានោះ ។ ឆ្នាំ២០០៥-២០០៦ ក៏ផ្លាស់ទៅធ្វើផ្នែករដ្ឋបាលនៅការិយាល័យអប់រំស្រុករហូតចូលនិវត្តន៍នៅឆ្នាំ២០១៣ ។ **រី លក្ខិណា**

# រី ញ៉ែរ អតីតកងការពារតំបន់៤១ ភូមិភាគកណ្តាល



រី ញ៉ែរ មានអាយុ៥៥ឆ្នាំ អតីតកងការពារតំបន់៤១ ភូមិភាគកណ្តាល មានស្រុកកំណើតនៅឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ ដោយមានឪពុកជាមេការសំណង់ គ្រួសាររបស់ ញ៉ែរ បានផ្លាស់ទីលំនៅជាច្រើនកន្លែង ។ នៅឆ្នាំ១៩៦៧ ញ៉ែរ បានទៅរស់នៅគិរីរម្យ ខេត្តកំពង់ស្ពឺ និងបានចូលរៀន នៅទីនោះរហូតដល់ថ្នាក់ទី១ ១ចាស់ ។

មួយឆ្នាំក្រោយមក ញ៉ែរ និងគ្រួសារបានត្រឡប់មករស់នៅក្នុងភូមិអ៊ីង ហើយបានបន្តការសិក្សានៅទីនោះ ។ ទោះបីជាមិនបានទទួលការអប់រំច្រើនយ៉ាងណាក៏ដោយ តែ ញ៉ែរ អាចអាន និងសរសេរបាន ពីព្រោះគាត់បានខិតខំរៀនដោយខ្លួនឯង ។ ញ៉ែរ បានបន្តរៀនរហូតដល់ឆ្នាំ១៩៧១ ។ បន្ទាប់ពីស្ថានភាពប្រទេសមានការប្រែប្រួល ញ៉ែរ បានឈប់រៀន និងវិលមករស់នៅភូមិមានខាងក្រៅក្នុងស្រុកព្រៃឈរ ។ នៅពាក់កណ្តាល ឆ្នាំ១៩៧១ ញ៉ែរ បានផ្លាស់ទៅរស់នៅភូមិមានខាងក្នុង ខណៈបងប្រុសស្រីរបស់គាត់បានចាកចេញទៅធ្វើការនៅទីក្រុងភ្នំពេញ ។

នៅឆ្នាំ១៩៧២ ភូមិរបស់ ញ៉ែរ ត្រូវបានរំដោះដោយកងទ័ពខ្មែរក្រហមដែលមានការគាំទ្រពីកងទ័ពវៀតណាមខាងជើង ។ នៅខែមករា ឆ្នាំ១៩៧២ ភ្លាមៗក្រោយពីមូលដ្ឋានរបស់គាត់ស្ថិតនៅក្នុងតំបន់រំដោះ ញ៉ែរ បានចូលបដិវត្តន៍ ពីព្រោះស្ថានភាពនៅក្នុងភូមិមានការច្របូកច្របល់ខ្លាំង ។ ញ៉ែរ បានរំឭកថា “គ្រួសារ គាត់បានរត់ភៀសខ្លួនពីកន្លែងមួយទៅកន្លែងមួយ ។ នៅគ្រានោះ គាត់បានជួបកម្មាភិបាលភូមិភាគខត្តរ ដែលមកពីវៀតណាមខាងជើង ឬហៅថា “ខ្មែរហាណូយ” ។ បន្ទាប់ពីចូលបដិវត្តន៍នៅអាយុ១៣ឆ្នាំ ញ៉ែរ ត្រូវបានចាត់តាំងឲ្យធ្វើជានីរសាររបស់ តាថុន ជាគណៈគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន ។ នៅក្នុងតំបន់រំដោះ មានគណៈគ្រប់គ្រងសំខាន់ៗមួយចំនួនដូចជា ៖ ទី១) តាស្រេង និង តាតាំង គ្រប់គ្រងមន្ទីរតំបន់ស្ថិតនៅព្រៃក្តុល ក្នុងភូមិថ្មពុន ទី២) តាខាន់ ប្អូនរបស់ តាតាំង ជាប្រធានយោធាតំបន់ ទី៣) តាសាន ប្រធានពាណិជ្ជកម្មតំបន់ ទី៤) តាថុន ប្រធាននយោបាយ និងរដ្ឋបាលគ្រប់គ្រងស្រុក និង ទី៥) តាសុង ទទួលភារៈគ្រប់គ្រងទាំងកងទ័ពរំដោះ និងកងទ័ពវៀតណាមខាងជើង ។

ជានីរសាររបស់ តាថុន ញ៉ែរ ត្រូវរត់សំបុត្រទៅភូមិឃុំចុះឡើងដោយថ្មើរជើង ។ នៅក្នុងឆ្នាំ១៩៧២ ញ៉ែរ និងមនុស្សជាច្រើននាក់ត្រូវបានជ្រើសរើស និងបញ្ជូនទៅសមរភូមិចេនឡាទី១ និងទី២ នៅតាមបណ្តោយផ្លូវជាតិលេខ៦ ។ ញ៉ែរ នៅក្នុងកងពលតូចស្រុកព្រៃឈរ ដែលមានកងទ័ព៣០នាក់ គ្រប់គ្រងដោយ តាប្អូន ។ នៅគ្រានោះ ញ៉ែរ ត្រូវបានបំពាក់អាវុធការាប៊ីន តែគាត់មិនដែលបានទទួលវគ្គបណ្តុះបណ្តាលយុទ្ធសាស្ត្រកងទ័ពអ្វីឡើយ ។ ញ៉ែរ និងអង្គភាពត្រូវបានបញ្ជូនទៅជួយកងទ័ពជួរមុខ ក្រោមការបញ្ជារបស់ តាសុង និងបានបើកការវាយប្រហារនៅតាមសមរភូមិជាច្រើន ដូចជា នៅព្រៃឈរ និងចម្ការលើជាដើម ។ បន្ទាប់ពិការប្រយុទ្ធបានបញ្ចប់ អង្គភាពរបស់ ញ៉ែរ ត្រូវបានបញ្ជូនមកមន្ទីរស្រុកព្រៃឈរស្ថិតនៅក្រូច-គរ វិញ ។

រហូតដល់រំដោះឆ្នាំ១៩៧៥ ញ៉ែរ និងអង្គភាព ត្រូវបានបញ្ជូនទៅរកាកោងស្ថិតនៅក្នុងស្រុកកងមាស ដែលមានឈ្មោះ ផាន់ ទើបតែផ្លាស់មកដល់មុននោះ ជាអនុស្រុក ។ ជាការពិតមន្ទីរស្រុកស្ថិតនៅពាមជីកង ប៉ុន្តែ ផាន់ មិនស្នាក់នៅទីនោះទេ ពីព្រោះមន្ទីររបស់គាត់នៅខាងក្បាលជ្រោយ ។ ញ៉ែរ និងកងការពារផ្សេងទៀតនៅក្នុងអង្គភាព ត្រូវការពារ ផាន់ គ្រប់ពេលដែលគាត់ចុះបំពេញភារកិច្ច ។ ប៉ុន្តែជាធម្មតា ញ៉ែរ ក៏ចុះធ្វើស្រែ ដូចប្រជាជនផ្សេងទៀតដែរ ។ នៅពេលកម្មាភិបាលនិរតីត្រូវបានផ្លាស់មកគ្រប់គ្រងនៅពាក់កណ្តាលឆ្នាំ១៩៧៧ ការចាប់ខ្លួនកម្មាភិបាលភូមិ

ភាគកណ្តាល និងគណៈគ្រប់គ្រងភូមិភាគកណ្តាល បានចាប់ផ្តើមរហូតដល់មានការចាប់ខ្លួន ផាន់ ។

បន្ទាប់ពីអនុស្រុកកងមាសត្រូវបានចាប់ខ្លួនមិត្តរបស់ ញ៉ាវ ម្នាក់ឈ្មោះ វ៉ាន់ ធ្វើការនៅមន្ទីរតំបន់ បានប្រាប់ ញ៉ាវ ឲ្យបំផ្លាញរាល់ឯកសារជាប់ទាក់ទងជាមួយ ផាន់ ចោលឲ្យអស់ ដើម្បីជៀសវាងការជាប់ពាក់ព័ន្ធណាមួយ ។ ញ៉ាវ បានដុតឯកសារទាំងអស់ចោល ដើម្បីបំបាត់ភស្តុតាង ពីព្រោះគាត់ក៏បានដឹងដែរថានរណាខ្លះត្រូវបានដាក់ការសង្ស័យ និងត្រូវយកទៅប្រជុំ ។ បន្ទាប់ពីប្រាប់ ញ៉ាវ ពីការចាប់ខ្លួន និងការបាត់ខ្លួន កម្មាភិបាលសំខាន់ៗមួយចំនួន វ៉ាន់ ត្រូវបានចាប់ខ្លួនយកទៅសម្លាប់បន្តទៀត ។ ញ៉ាវ បានរំឮកថា ក្នុងរយៈកាលនៃការគ្រប់គ្រងរបស់ ផាន់ ប្រជាជនមិនទទួលបានរបបអាហារគ្រប់គាន់ទេ តែអាចរស់បាន ។ ប៉ុន្តែក្រោយការមកដល់របស់កម្មាភិបាលភូមិភាគនិរតី ការរស់នៅកាន់តែលំបាក ។

ញ៉ាវ បានប្រាប់ពីការចាប់ និងសម្លាប់កម្មាភិបាលភូមិភាគកណ្តាលជាបន្តបន្ទាប់ថាៈ ក្រោយរំដោះឆ្នាំ១៩៧៥ ផាន់ ត្រូវបានផ្លាស់ជាអនុស្រុកកងមាស ខណៈ តាមាស ជាគណៈស្រុក ។ ប៉ុន្តែនៅពាក់កណ្តាលឆ្នាំ១៩៧៧ បន្ទាប់ពីការផ្លាស់កម្មាភិបាលនិរតីមកគ្រប់គ្រង ការចាប់ខ្លួនកម្មាភិបាលមូលដ្ឋាន (ភូមិភាគកណ្តាល) បានចាប់ផ្តើមតាមរូបភាព «ប្រជុំ» ។ តាស្រេង និង តាតាំង ជាមុខសញ្ញានៃការចាប់ខ្លួនមុនគេ ។ ស្របពេលនោះ តាអាន មកពីភូមិភាគនិរតី ក៏ត្រូវបានដំឡើងជាគណៈតំបន់៤១ ខណៈ តាសុប ឡើងគ្រប់គ្រងបន្ទាប់ពីគណៈតំបន់ (តាអាន) ។ ក្រោយមក ផាន់ ក៏ត្រូវបានចាប់ខ្លួនយកទៅបាត់ ហើយយាយ រុំ បានឡើងមកជំនួស ។ រយៈពេល៥-៦ខែក្រោយមក កាន មកពីភូមិភាគនិរតី បានផ្លាស់មកកាន់តួនាទីជាអនុស្រុកកងមាស ស្ថិតក្រោមការគ្រប់គ្រងរបស់យាយ រុំ ។ បួនខែក្រោយមក យាយ រុំ ក៏ត្រូវបានចាប់ខ្លួន ហើយ កាន បានឡើងជំនួស ។ នៅខណៈ កាន បានឡើងជាគណៈស្រុកកងមាស ហឿន មកពីភូមិភាគនិរតី បានក្លាយជាប្រធានយោធា ។ មិនយូរប៉ុន្មាន មន្ទីរសន្តិសុខអូរត្រកួនត្រូវបានបង្កើតឡើង ហើយមនុស្សជាច្រើនរួមទាំងជនជាតិចាម ត្រូវបានបញ្ជូនមកឃុំឃាំង និងសម្លាប់នៅមន្ទីរសន្តិសុខនេះ ។

បន្ទាប់ពី កាន ឡើងជាគណៈស្រុកកងមាស អគ្គភាពរបស់ ញ៉ាវ ត្រូវបានរំសាយ និងបញ្ជូនទៅតាមសហករណ៍ ។ ញ៉ាវ ត្រូវបានផ្លាស់ទៅសហករណ៍អង្គរបាន តែគាត់ក៏ដឹងខ្លួនដែរថា គាត់ និងអ្នកសេសសល់ផ្សេងទៀតត្រូវបានកត់សម្គាល់ដើម្បីយកទៅសម្លាប់ ។ នៅក្នុងសហករណ៍ ញ៉ាវ ត្រូវបានចាត់តាំងឲ្យធ្វើស្រែ និងជីកប្រឡាយ ។

ក្រោយមក ញ៉ាវ និងមនុស្សជាច្រើន ត្រូវបានបញ្ជូនទៅដាំកប្បាសនៅម្តុំអណ្តូងក្រឡឹង ស្ថិតនៅចម្ការកប្បាស ដែលមាន ឈន ជាគណៈគ្រប់គ្រង (ក្រោយមកត្រូវបានចាប់ខ្លួន) ។ នៅរដូវវស្សានៅឆ្នាំ១៩៧៧ ញ៉ាវ និងអ្នកផ្សេងទៀត (ចំនួន៣៦នាក់) ត្រូវបានផ្លាស់ទៅមន្ទីរតំបន់៤១ ។ បន្ទាប់ពីទៅដល់មន្ទីរតំបន់៤១ ញ៉ាវ ត្រូវបានចាត់តាំងជាកងការពារតំបន់ ប៉ុន្តែកិច្ចការជាក់ស្តែងរបស់គាត់គឺដាំបន្លែនិងធ្វើស្រែ ពីព្រោះតែថ្នាក់លើលែងមានទំនុកចិត្តលើគាត់ ។ នៅពេលនោះ ហឹម និង សុក ជាប្រធានកងការពារតំបន់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាអាន ។ ទោះបីក្លាយជាកងការពារតំបន់៤១ក៏ដោយ ក៏ប៉ុន្តែ ញ៉ាវ ស្គាល់តែបុគ្គលសំខាន់ៗមួយចំនួននៅក្នុងតំបន់៤១ប៉ុណ្ណោះគឺៈ ទី១) តាអានជាគណៈតំបន់៤១ គ្រប់គ្រងលើស្រុកចំនួន៥ រួមមាន ស្រុកកំពង់សៀម, ស្រុកព្រៃឈរ, ស្រុកជើងព្រៃ, ស្រុកកងមាស និងស្រុកបាធាយ ទី២) តា អាំ ជាប្រធានមន្ទីរតំបន់៤១ ទី៣) តាសុប ជាប្រធានសន្តិសុខក្រូច-គ និងទី៤) រុន ជាប្រធានមន្ទីរសន្តិសុខវត្តតាមះ ។

នៅពេលមានជម្លោះរវាងកម្ពុជា និងវៀតណាមនៅតាមបណ្តោយព្រំដែន ភឹម ហៅ ផល ដែលជាគណៈស្រុកបាធាយ និងអនុប្រធានតំបន់៤១ បានទទួលភារៈគ្រប់គ្រងទ័ពតំបន់ដែលជាកងទ័ពជំនួយរបស់កងទ័ពជួរមុខ ។ ទីបំផុត កងទ័ពវៀតណាមបានបើកការវាយប្រហាររហូតចូលដល់ប្រទេសកម្ពុជានៅដើមឆ្នាំ១៩៧៩ ។ ញ៉ាវ បានសម្រេចចិត្តមិនរត់ភៀសខ្លួនតាមកម្មាភិបាលខ្មែរក្រហមដែលនៅសេសសល់ ហើយបានវិលត្រឡប់មកកាន់ភូមិកំណើតវិញជាមួយមិត្តម្នាក់ឈ្មោះ វ៉ែន ។ បន្ទាប់ពីមកដល់ភូមិនៅក្នុងអំឡុងពេលរំដោះឆ្នាំ១៩៧៩ ញ៉ាវ បានដឹងថា មានប្រជាជនចាមជាច្រើននៅក្នុងភូមិត្រូវយកទៅសម្លាប់ ដោយគណៈឃុំឈ្មោះ ង៉ិន មកពីភូមិភាគនិរតី ។ នៅឆ្នាំ១៩៨០ ញ៉ាវ បានរៀបការ និងរស់នៅភូមិកំណើតរហូតដល់សព្វថ្ងៃ ។ **ស៊ាង ចិន្តា**

# ឌុច ចាន់ថា អតីតនីរសារគណៈតំបន់២ ភូមិភាគពាយ័ព្យ

ឌុច ចាន់ថា សព្វថ្ងៃមានអាយុ៦២ឆ្នាំ និងជាសមាជិកក្រុមប្រឹក្សាសង្កាត់បម្រើនផល ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។ ចាន់ថា មានស្រុកកំណើតនៅភូមិក្តីខ្វាវ ឃុំផ្សារលើ ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ ឪពុករបស់ចាន់ថាឈ្មោះ ឌុច អូន និងម្តាយឈ្មោះ ហ៊ួរ៉ន ។ ចាន់ថា មានបងប្អូន៦នាក់ ស្រី២-ប្រុស៤នាក់ ។ ប្រពន្ធរបស់ ចាន់ថា ឈ្មោះ កែវ ផុន និងមានកូន៥នាក់ ប្រុស៣នាក់ និងស្រី២នាក់ ។

កាលពីតូច ចាន់ថា រៀននៅវត្តលលកស ដោយមានលោកសង្ឃជាអ្នកបង្រៀន ។ នៅពេលដែលមានសង្គ្រាមរដ្ឋប្រហារទម្លាក់សម្តេចសីហនុឆ្នាំ១៩៧០ ចាន់ថា បានឈប់រៀននៅថ្នាក់ទី៧ "ចាស់" ។ បន្ទាប់មក ចាន់ថា បានត្រឡប់មកផ្ទះ និងជួយធ្វើស្រែចម្ការឪពុកម្តាយ ។ នៅឆ្នាំ១៩៧២ ចាន់ថា ត្រូវបានជ្រើសរើសចូលបដិវត្តន៍ជាមួយខ្មែរក្រហម ពីព្រោះផ្ទះរបស់ ចាន់ថា ស្ថិតនៅក្នុងតំបន់រំដោះដែលអាចឲ្យ ចាន់ថា ងាយស្រួលក្នុងការមកលេងជាមួយឪពុកម្តាយ ។ ពេលចូលដំបូងខ្មែរក្រហមឲ្យឃ្វាលគោរយៈពេលកន្លះឆ្នាំ បន្ទាប់មកដោយឃើញថា ចាន់ថា អាចអានអក្សរបារាំងបានខ្លះ ខ្មែរក្រហមក៏បញ្ជូន ចាន់ថា ឲ្យចូលរៀនពេទ្យនៅក្នុងភូមិកាសាស់ ក្នុងស្រុកបាកាន ។ ចាន់ថា រៀនពេទ្យបានរយៈពេលជាងមួយឆ្នាំ គឺនៅក្នុងឆ្នាំ១៩៧៤ ចាន់ថា អាចព្យាបាលជំងឺ និងចាក់ថ្នាំបានខ្លះ ពេលនោះគណៈស្រុកបាកានឈ្មោះ លឹម ខាន ក៏យក ចាន់ថា ទៅនៅជាមួយដើម្បីជួយព្យាបាលពេលគាត់មានជំងឺ ។

បន្ទាប់ពីខ្មែរក្រហមរំដោះបានទូទាំងប្រទេសនៅឆ្នាំ១៩៧៥ លឹម ខាន បានឡើងជាគណៈតំបន់២ ទទួលផ្នែកសេដ្ឋកិច្ច, សំអឿន ទទួលខាងនយោបាយ, តូយ ទទួលខាងយោធា ។ ចំណែក អ៊ុម, សើ និង ថន ជាសមាជិកតំបន់ទទួលជាគណៈស្រុកបាកាន, ស្រុកក្រគរ និងស្រុកមោង ។ កងនីរសាររបស់ លឹម ខាន មានបីនាក់ ។ អ្នកទី១) ចាន់ថា មានភារកិច្ចជាអ្នកបើកឡាន និងព្យាបាលជំងឺពេល ខាន មានជំងឺ អ្នកទី២) មានភារកិច្ចការពារ និងអ្នកទី៣) ទទួលខាងសេដ្ឋកិច្ច គឺដាំបាយ ឬភ្លក់បាយម្ហូបពេលណាដែលក្រុមគាត់មិនបានចម្អិនដោយខ្លួនឯង ។ ខាន បានប្រាប់ដល់នីរសារទាំងបីថា "ពេលអញទៅដល់ណា ឯងអ្នកការពារត្រូវទៅមើលសភាពការណ៍ជុំវិញហ្នឹង ខ្លាចមានប្រតិកម្មអីមួយ ត្រូវឲ្យអញដឹង ។ សេដ្ឋកិច្ចអ្នកដាំបាយទឹក បើឯងដាំខ្លួនឯងអត់អីទេ បើមានគេជួយដាំ ឯងត្រូវតែភ្លក់មុន និងហូបមុនឲ្យហើយ ជៀសវាងក្រែងមានគ្រោះថ្នាក់ដល់អញ និងភ្ញៀវផ្សេងទៀត" ។ ចំណែក ចាន់ថា មានតួនាទីបើកឡាន គឺពេលឈប់សម្រាកត្រូវពិនិត្យមើលឡាន មើលប្រេង មើលសាំង មើលកង់ឲ្យបានហ្មត់ចត់ ហើយបើ ខាន ឈឺត្រូវព្យាបាល និងចាក់ថ្នាំឲ្យគាត់ ។

ការគ្រប់គ្រងរៀបចំភូមិស្រុកពេលដែលជម្លៀសប្រជាជនមកគឺយោធាជាអ្នកទទួលខុសត្រូវ ព្រោះយោធាជាអ្នករំដោះ ។ ដូច្នេះ យោធារៀបចំបោសសម្អាតមុន ទើបអ្នកនយោបាយទៅបំពាក់គោលនយោបាយ ហើយគណៈស្រុកទៅគ្រប់គ្រងតាមក្រោយ ។ ចាន់ថា បានបើកឡានជូន ខាន ទៅប្រជុំនៅបាត់ដំបង និងបានជួបជាមួយ រស់ ញឹម ជាញឹកញាប់ ។ ប៉ុន្តែ ចាន់ថា មិនដែលបានបើកឡានជូន ខាន មកប្រជុំនៅភ្នំពេញទេ គឺមានឡានប្រភេទទេសចរណ៍មកយក ខាន និងកម្មាភិបាលផ្សេងៗទៅប្រជុំ ។ កម្មាភិបាលជាន់ខ្ពស់ដែល ចាន់ថា ឧស្សាហ៍ជួបនឹងចេញចូលផ្ទះ ខាន ញឹកញាប់មាន តាកន និងតាវ៉ាញ ។ ប្រពន្ធ តាវ៉ាញ ឈ្មោះ ឃឹម ជាពេទ្យប្រចាំនៅខេត្តពោធិ៍សាត់ ។ ទោះបីជា ចាន់ថា មាននាទីជានីរសារបស់គណៈតំបន់ក៏ដោយ ក៏ ចាន់ថា មិនដែលបានមកលេងផ្ទះដែររហូតដល់ខ្មែរក្រហមដួលរំឆ្នាំ១៩៧៩ ។ ប្រជាជនដែលជម្លៀសមកភ្នំពេញភាគច្រើនយកទៅដាក់នៅក្នុងឃុំតាលោ ចំណែកកន្លែងដែល ចាន់ថា រស់នៅគឺមានតិចតួច តែក៏ស្លាប់ច្រើនដែរ ដោយសារអត់បាយ ឈឺគ្រុនចាញ់ និងគ្មានថ្នាំព្យាបាល ។ បើអ្នកដែលមានសមាសភាពជាទាហាន និងមន្ត្រីរដ្ឋការ គឺ អង្គការយកទៅដាក់នៅទួលពោធិ៍ជ្រៃ ។ អ៊ំរបស់ ចាន់ថា ជាទាហានលន់

នល់ ក៏ត្រូវយកនៅទួលពោធិ៍ជ្រៃដែរ ។

ចាន់ថា បានរៀបការជាមួយនារីនៅខាងកងត្បាញនៅឆ្នាំ ១៩៧៧ នៅរដូវប្រូតក្នុងឆ្នាំ១៩៧៧ ចាន់ថា ត្រូវអង្គការបញ្ជូនទៅភ្នំពេញ គឺពេល ខាន ទៅប្រជុំនៅពោធិ៍សាត់ ។ ពេលនោះ អង្គការប្រជុំមួយយប់ទល់ភ្លឺ ធ្វើឲ្យ ចាន់ថា ឆ្ងល់យ៉ាងខ្លាំងព្រោះប្រជុំរហូតអត់បាយ អត់ទឹក អត់ដេក ហើយគាត់បានជជែករឿងនេះជាមួយនីរសារដូចគ្នា ។ ស្រាប់តែព្រឹកឡើង ខាន ចុះពីប្រជុំហើយប្រាប់ ចាន់ថា "ឲ្យត្រឡប់ទៅផ្ទះវិញ ហើយប្រាប់ប្រពន្ធអញផង ថាអញទៅប្រជុំនៅភ្នំពេញហើយ" ប្រាប់តែប៉ុណ្ណឹង ខាន ឡើងឡានប្រភេទទេសចរណ៍ចេញទៅបាត់ ។ គ្រាន់តែគណៈតំបន់ គណៈស្រុកចាស់ឡើងឡានចេញទៅភ្លាម ខាងគណៈស្រុក និងគណៈតំបន់ថ្មីមកពីបស្ចិមមកភ្លាម ។ កន្លះខែក្រោយមក ខ្មែរក្រហមមកហៅប្រពន្ធៗកម្មាភិបាលដែលឡើងទៅប្រជុំនៅភ្នំពេញថា ឲ្យទៅតាមប្តី ។ ខ្មែរក្រហមយកឡានពីរគ្រឿងមកទទួល ហើយប្រពន្ធរបស់ ចាន់ថា និង ចាន់ថា បានជិះឡានផ្សេងគ្នា ។ ពេលដែលឡានមកដល់មុខវាំង (ប្លុមន្ទីរក-៧) ស្រាប់តែមាននីរសារគេចេញមកប្រាប់ថា អត់ដាក់នៅទីនេះទេគឺយកទៅភូមិតាឡី រោងចក្រកែវ ។ ពេលនោះ ឡានដែលប្រពន្ធចាន់ថា ជិះក៏បើកផ្លូវផ្សេង ទើប ចាន់ថា គិតថាគាត់បែកគ្នា និងស្លាប់ចោលគ្នាហើយ ។ ក្រោយមក អ្នកបើកឡានក៏បើកទៅជួបគ្នានៅមន្ទីរតាឡី ហើយខ្មែរក្រហមមកឆែកអីវ៉ាន់យកទាំងអស់ គឺមិនឲ្យមាននៅជាប់នឹងខ្លួនទេ ។ ពេលនោះ ចាន់ថា ដាក់ថ្នាំពេទ្យមកជាមួយព្រោះប្រពន្ធរបស់គាត់ជិតឆ្លងទន្លេ និងមានមាសខ្លះ តែអង្គការដកទុកទាំងអស់ ។

ពេលល្ងាច អង្គការឲ្យគាត់ឡើងសម្រាកលើផ្ទះដែលមានបីគ្រួសារ ។ ព្រឹកឡើង ខ្មែរក្រហមមិនបានសួរនាំអ្វីទេ គឺប្រុសៗធ្វើការផ្សេង ស្រីៗធ្វើការផ្សេង ។ ខ្មែរក្រហមបែកចបកាប់ បង្គី ឲ្យទៅជីកប្រឡាយ និងលើកទំនប់ ។ ប្រុស និងស្រីធ្វើការស្មើគ្នា ចំណែកមនុស្សចាស់ៗនៅខាងដាំបន្លែ និងមើលក្មេង ។ ក្រោយពីសម្រាកពីការងារ ខ្មែរក្រហមប្រជុំណែនាំកុំឲ្យយើងខ្ជិលច្រអូស ខ្ជីខ្ជាអប់រំ យើងឲ្យធ្វើការ កុំគេចវេស ទៅនេះទៅនោះ ប្រយ័ត្នអង្គការដាក់ពិន័យ ។ ចាន់ថា ក៏ត្រូវខ្មែរក្រហមសួរប្រវត្តិរូបពីរលើក ហើយ ចាន់ថា ឆ្លើយថា ធ្វើនីរសាររហូត ។ ចំណែកមិត្តរបស់ ចាន់ថា ម្នាក់ឆ្លើយខុសគ្នា លើកទីមួយថាកងភ្នួរ លើកទីពីរថា គណៈសហករណ៍ គឺបាត់ខ្លួនរហូត ។ ចាន់ថា នៅមន្ទីរតាឡីបានកន្លះខែ ខ្មែរក្រហមក៏បញ្ជូនកម្លាំងប្រុសៗ និងស្រីៗដែលនៅលើវមកវត្តជ័យឧត្តម ចំណែកស្ត្រីដែលមានប្តី គឺនៅមន្ទីរតាឡីដដែល ។

នៅវត្តជ័យឧត្តម គឺកម្លាំងនៅលើវត្រូវជីកប្រឡាយ លើកទំនប់ដដែលតែធ្វើការសកម្មជាងមុន ។ នៅពេលហូបបាយ គឺចុងភៅដាំបាយដាក់សឹងហើយពុះចែកគ្នា បើយើងមិនចេះរកម្ហូបមកផ្សំគឺហូបមិនឆ្អែតទេ តែបើមេកងឃើញប្រាកដជាបាត់ខ្លួនមិនខាន ។ ពេលនោះ ចាន់ថា សុំមេកងទៅបត់ជើង តែតាមពិតគាត់ទៅសម្ងំដេកនៅក្នុងព្រៃព្រោះគាត់អស់កម្លាំងខ្លាំង ។

ចាន់ថា នៅធ្វើការនៅវត្តជ័យឧត្តមកន្លះឆ្នាំ ទើបខ្មែរក្រហមបញ្ជូនទៅវាយថ្ម នៅត្រពាំងក្រឡឹង ។ គាត់ជិះរទេះភ្លើងទៅដល់ត្រពាំងក្រឡឹងនៅពេលយប់ ។ ពេលព្រឹកឡើងខ្មែរក្រហមឲ្យគាត់សម្រាកនៅកន្លែងដែលសុទ្ធតែភ្នំព័ទ្ធជុំវិញ ។ គាត់ចង់រត់គេចខ្លួនក៏រត់មិនរួចដែរ ព្រោះមិនស្គាល់តំបន់ ។

ពេលដែលទៅដល់ដំបូង ចាន់ថា មិនចេះវាយថ្មទេ ហើយបើវ៉ៃតាមកម្លាំង គឺប្រាកដជាខ្ទាត់ត្រូវដៃជើងមិនខាន ។ ក្រោយមក មានចាស់ៗ ដែលធ្វើការនៅទីនោះមុនប្រាប់ពីបច្ចេកទេសវាយថ្ម ព្រោះថ្មមានថ្នេរ មានលំដាប់លំដោយ ហើយបើយើងចេះមើលថ្នេរថ្មនោះមិនលំបាកទេ ។ ចាន់ថា នៅត្រពាំងក្រឡឹងរហូតដល់ពេលដែលវៀតណាមចូលមក ទើបត្រឡប់ទៅស្រុកកំណើតវិញ ។ ចាន់ថា មិនហ៊ានរត់តាមថ្នល់ជាតិទេ រត់កាត់តាមព្រៃ ពេលខ្លះគាត់បានសុំឡានគេជិះ និងដើរបន្តរហូតដល់ពោធិ៍សាត់ ។ ចាន់ថា បានជួបប្រពន្ធ ហើយគាត់ក៏សួររកកូន តែកូនគាត់ស្លាប់តាំងពីនៅសហករណ៍តាឡី ។ ចាន់ថា បានរត់បន្តទៅដល់មោង ក៏ត្រូវវៀតណាមព័ទ្ធកាត់ផ្លូវ ធ្វើឲ្យគាត់ភ័យខ្លាចយ៉ាងខ្លាំងព្រោះឮថាវៀតណាមវះពោះញាត់ស្មៅ តែសំណាងល្អក្នុងក្រុមរបស់គាត់ មានអ្នកចេះនិយាយភាសាវៀតណាម ហើយប្រាប់កងទ័ពវៀតណាមថាក្រុមគាត់មិនមែន ប៉ុល ពត ទេ គឺជាកម្មកររទេះភ្លើង ។ វៀតណាមក៏ឃាត់ហើយឲ្យត្រឡប់មកផ្ទះវិញ ទើប ចាន់ថា ត្រឡប់មកជួបប្រពន្ធ និងម្តាយក្មេក ហើយបានមករស់នៅទីរួមខេត្តពោធិ៍សាត់រហូតដល់សព្វថ្ងៃ ។ **រី លក្ខិណា**

# វេទិកាថ្នាក់រៀន ស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## សេចក្តីផ្តើម

វិទ្យាស្ថានស្លឹករឹតដែលជាមជ្ឈមណ្ឌលឯកសារកម្ពុជា អចិន្ត្រៃយ៍ សហការជាមួយក្រសួងអប់រំ យុវជន និង កីឡា បានបង្កើតវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅវិទ្យាល័យចំនួន១៥ ក្នុងរាជធានីភ្នំពេញ ។ គម្រោងនេះ គឺជាផ្នែកមួយរបស់កម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងការចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ (១៩៧៥-៧៩) ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដល់សិស្សានុសិស្សនៅទូទាំងប្រទេស ។ វេទិកាថ្នាក់រៀនលើកដំបូងនេះ មានការចូលរួមពីសិស្សានុសិស្សចំនួន៩៥០នាក់ មកពី១៥ វិទ្យាល័យ ដែលអ្នកចូលរួមភាគច្រើនជាសិស្សថ្នាក់ទី១១ និង១២ ។ គោលបំណងនៃការធ្វើវេទិកានេះ គឺជួយបំពេញបន្ថែមដល់សិស្សានុសិស្សនូវចំណេះដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងរឿងរ៉ាវផ្សេងទៀតក្នុងអតីតកាលរបស់កម្ពុជា ។

ខាងក្រោមនេះ គឺជាបញ្ជីឈ្មោះវិទ្យាល័យ និងកាលបរិច្ឆេទ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើវេទិកាថ្នាក់រៀន៖

| ល.រ | វិទ្យាល័យ | ខណ្ឌ | កាលបរិច្ឆេទ | ចំនួនសិស្ស |
|---|---|---|---|---|
| ១ | បឹងកេងកង | ចម្ការមន | ៨ មករា ២០១៦ | ៩៦ |
| ២ | ទួលស្វាយព្រៃ | ចម្ការមន | ១៥ មករា ២០១៦ | ៦០ |
| ៣ | ទួលទំពូង | ចម្ការមន | ២៩ មករា ២០១៦ | ៤២ |
| ៤ | ជា ស៊ីម ឈូកវ៉ា | ព្រែកព្នៅ | ១២ កុម្ភៈ ២០១៦ | ៣៤ |
| ៥ | ជម្ពូវ័ន្ត | ពោធិ៍សែនជ័យ | ១៩ កុម្ភៈ ២០១៦ | ១០០ |
| ៦ | ប៊ុន រ៉ានី ហ៊ុន សែន អរុណវត្តី | ពោធិ៍សែនជ័យ | ៤ មីនា ២០១៦ | ៥៤ |
| ៧ | ទួលអំពិល | ដង្កោ | ១៨ មីនា ២០១៦ | ១០១ |
| ៨ | ព្រះស៊ីសុវត្ថិ | ដូនពេញ | ១៨ មីនា ២០១៦ | ៣៥ |
| ៩ | ពងទឹក | ដង្កោ | ១៨ មីនា ២០១៦ | ៣០ |
| ១០ | ប៊ុន រ៉ានី ហ៊ុន សែន វត្តភ្នំ | ដូនពេញ | ៦ ឧសភា ២០១៦ | ៣៩ |
| ១១ | ចាក់អង្រែ | មានជ័យ | ២០ ឧសភា ២០១៦ | ៧០ |
| ១២ | ច្បារអំពៅ | ច្បារអំពៅ | ៣ មិថុនា ២០១៦ | ១៥៧ |
| ១៣ | ព្រែកឯង | ច្បារអំពៅ | ១៧ មិថុនា ២០១៦ | ៥៣ |
| ១៤ | ឫស្សីកែវ | ឫស្សីកែវ | ២៤ មិថុនា ២០១៦ | ៥៤ |
| ១៥ | បាក់ទូក | ៧ មករា | ៨ កក្កដា ២០១៦ | ២៥ |
| **សរុប** | **១៥វិទ្យាល័យ** | **១០ខណ្ឌ** | **១៥វេទិកា** | **៩៥០** |

វេទិកាថ្នាក់រៀននីមួយៗ មានរយៈពេល២ម៉ោង និងធ្វើឡើងតាមកម្មវិធីតែមួយដូចៗគ្នាគឺ៖

១) តារាងស្ទាប់ស្ទង់មតិមុនការធ្វើវេទិកា ។

២) តារាង K-W-L (K = អ្វីដែលខ្ញុំបានដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ W = អ្វីដែលខ្ញុំចង់ដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ L = អ្វីដែលខ្ញុំបានរៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ) ។

៣) បទបង្ហាញពីព្រឹត្តិការណ៍សំខាន់ៗនៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

៤) បញ្ចាំងខ្សែភាពយន្តឯកសារខ្លី ៖ គុកទួលស្លែង តំបន់រំដោះក្នុងឆ្នាំ១៩៧៣ និងកុមារកម្ពុជា ។

៥) បទបង្ហាញខ្លីស្តីពីសារសំខាន់ក្នុងការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

៦) តារាងស្ទាប់ស្ទង់មតិក្រោយការធ្វើវេទិកា ។

៧) ចែកសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)» ។

តារាងស្ទាបស្ទង់មតិមុន និងក្រោយការធ្វើវេទិកា គឺជាមធ្យោបាយមួយដែលអាចប្រមូលទិន្នន័យជាក់លាក់ពីសិស្សានុសិស្សនូវអ្វីដែលខ្លួនចង់ប្រាប់ ហើយទិន្នន័យនេះ នឹងត្រូវលើកយកមកវិភាគដើម្បីវាស់ស្ទង់ពីលទ្ធផលនៃការធ្វើវេទិកាថ្នាក់រៀននៅវិទ្យាល័យទាំង១៥ ក្នុងផ្នែកខាងក្រោមនៃរបាយការណ៍នេះ ។ ការសន្និដ្ឋានលើភាពជោគជ័យនៃការធ្វើវេទិកាថ្នាក់រៀន នឹងត្រូវសរសេរដោយយោងទៅលើលទ្ធផលដែលបានមកពីការស្ទាបស្ទង់មតិនៅចុងបញ្ចប់នៃរបាយការណ៍នេះដែរ ។

## គោលបំណងនៃវេទិកាថ្នាក់រៀន

ដោយយល់ឃើញថា អនាគតរបស់ប្រទេសកម្ពុជាចាំបាច់ត្រូវមានការទាក់ទងដោយផ្ទាល់ទៅនឹងការយល់ដឹងពីអតីតកាល គម្រោងធ្វើវេទិកាថ្នាក់រៀនត្រូវបានធ្វើឡើងដើម្បីផ្តល់ដល់សិស្សានុសិស្សថ្នាក់វិទ្យាល័យ និងយុវជនកម្ពុជាទូទៅ នូវការវិភាគដែលមានគុណភាព និងលម្អិតនៃរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីធានាថា ប្រវត្តិសាស្ត្រនេះមិនត្រូវបានបាត់បង់ មុនពេលដែលប្រវត្តិសាស្ត្រនេះត្រូវបានផ្សះផ្សា និងរៀនសូត្រ ។

ក្រៅពីការផ្តល់ឲ្យសិស្សានុសិស្សនូវការយល់ដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ វេទិកានេះក៏មានគោលបំណងបង្ហាញពីសារសំខាន់នៃការសិក្សាអំពីអតីតកាលដ៏ជូរចត់របស់កម្ពុជាដែរ ដើម្បីកសាងសន្តិភាព ការផ្សះផ្សា ការព្យាបាលរបួសផ្លូវចិត្ត និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នាថ្ងៃអនាគត ។

ដូច្នេះវេទិកានេះ មានគោលបំណងបង្ហាញឲ្យឃើញពីតម្លៃនៃការសិក្សាប្រវត្តិសាស្ត្រថាជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយសម្រាប់ការផ្លាស់ប្តូរនាពេលអនាគត ។ ដោយផ្អែកលើការផ្លាស់ប្តូរឥរិយាបថរបស់សិស្សចំពោះរឿងរ៉ាវដែលបានកើតឡើងក្នុងអតីតកាលរបស់ប្រទេសកម្ពុជា វេទិកាថ្នាក់រៀននឹងជំរុញទឹកចិត្តសិស្សានុសិស្ស និងក្មេងជំនាន់ក្រោយឲ្យខិតខំបន្ថែមទៀតក្នុងការរៀនសូត្រ និងសហការគ្នាដើម្បីសន្តិភាព ។ រចនាសម្ព័ន្ធនៃវេទិកានេះ គឺដើម្បីលើកទឹកចិត្តសិស្សានុសិស្សទាំងអស់ឲ្យធ្វើជាម្ចាស់លើប្រវត្តិសាស្ត្រខ្លួនឯង និងទទួលស្គាល់ការពិតរបស់ខ្លួន ។ ក្នុងន័យនេះ ការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ សង្ឃឹម



សិស្សវិទ្យាល័យវត្តភ្នំឡើងសួរសំណួរទាក់ទងនឹងរបបខ្មែរក្រហម

ជាទីផបង្កើតការសន្ទនាមួយ ដែលអាចឈានដល់លទ្ធផលជាផ្លែផ្កា ក្នុងការកសាងសន្តិភាព ការព្យាបាលរបួសផ្លូវចិត្ត និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគតសម្រាប់ក្មេងៗជំនាន់ក្រោយ ។

ជារួម កម្មវិធីអប់រំអំពើប្រល័យពូជសាសន៍ មានគោលបំណងជួយអភិវឌ្ឍកម្មវិធីសិក្សា សម្រាប់ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅតាមវិទ្យាល័យក្នុងទូទាំងប្រទេសកម្ពុជា ដែលជាសកម្មភាពបន្ថែមសម្រាប់កម្មវិធីបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាផ្លូវការ ។

## ការអនុវត្តវិធីសាស្ត្រ

វេទិកាថ្នាក់រៀន ត្រូវបានធ្វើឡើងសម្រាប់រយៈពេល២ម៉ោង និងបានប្រើប្រាស់កម្មវិធីចម្បងៗចំនួន៦គឺ ៖ ការស្ទាបស្ទង់មតិចំនួនពីរដង (ការស្ទាបស្ទង់មតិមុន និងក្រោយវេទិកា) ការប្រើប្រាសតារាង *K-W-L* (ដឹង–ចង់ដឹង–បានរៀន) ការបញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញលើមាតិកាប្រវត្តិសាស្ត្រ និងសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងការចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ជួនកាល ការធ្វើវេទិកាថ្នាក់រៀននេះ មិនបានអនុវត្តគ្រប់ជំហានដែលបានគ្រោងទុកឡើយ ដោយសារពេលវេលាមិនគ្រប់គ្រាន់ បញ្ហាបច្ចេកទេស វាគ្មិន និងតម្រូវការរបស់នាយកវិទ្យាល័យដែលចង់ឲ្យសិស្សរបស់គាត់មានឱកាសបានសួរសំណួរច្រើនជាង ។ ឧទាហរណ៍ ៖ តារាង *K-W-L* មិនត្រូវបានប្រើប្រាស់ជាមួយសិស្សានុសិស្សនៅវិទ្យាល័យចាក់អង្រែ ហើយត្រូវជំនួសវិញដោយការឆ្លើយសំណួររបស់សិស្សក្នុងរយៈពេល១៥នាទីបន្ថែមទៀត តាមសំណើរបស់នាយកវិទ្យាល័យ ដែលចង់ឲ្យសិស្សមានឱកាសច្រើនក្នុងការសួរដេញដោលពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

ខាងក្រោម គឺជាកម្មវិធីជាបន្តបន្ទាប់សម្រាប់វេទិកាថ្នាក់រៀននៅតាមវិទ្យាល័យទាំង១៥ ៖

*ក) ការស្ទាបស្ទង់មតិ មុនពេលធ្វើវេទិកាថ្នាក់រៀន*

ក្នុងអំឡុងពេលចាប់ផ្តើមការធ្វើវេទិកា តារាងសំណួរស្ទាប



*សិស្សវិទ្យាល័យព្រែកឯងឆ្លើយសំណួរស្ទាបស្ទង់ទាក់ទងនឹងសម័យខ្មែរក្រហម មុននឹងចាប់ផ្តើមសិក្សាពីមេរៀនសម័យខ្មែរក្រហម ដែលរៀបចំឡើងដោយគម្រោងវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥–៧៩) របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។*

ស្ទង់មតិត្រូវបានចែកឲ្យសិស្សានុសិស្សបំពេញដើម្បីវាស់ស្ទង់ពីកម្រិតនៃចំណេះដឹងទៅលើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យមុនពេលចាប់ផ្តើមធ្វើវេទិកា ។ សិស្សមានរយៈពេល១៥នាទីក្នុងការបំពេញតារាងស្ទាបស្ទង់មតិនេះ ។ សំណួរដែលមាននៅក្នុងតារាងស្ទាបស្ទង់មតិបានផ្តោតសំខាន់ទៅលើថា តើសិស្សានុសិស្សទាំងអស់ធ្លាប់បានសន្ទនាជាមួយឪពុកម្តាយ ឬបងប្អូនពីរបបខ្មែរក្រហមដែរឬទេ? តើសិស្សានុសិស្សទាំងនោះ ជឿថាការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យមានសារសំខាន់ដែរឬទេ? តើប្រវត្តិសាស្ត្រនេះ គួរតែបង្រៀននៅតាមសាលារៀននៅកម្ពុជា និងអាស៊ានដែរឬទេ? និងតើសិស្សានុសិស្សទាំងនោះរើសអើងចំពោះមិត្តភក្តិរបស់ខ្លួនដែលជាកូនរបស់អតីតកម្មាភិបាលខ្មែរក្រហមដែរឬទេ?

*ខ) តារាងK-W-L និងការធ្វើបទបង្ហាញ*

គោលបំណងរបស់តារាង K-W-L គឺដើម្បីបង្ហាញឲ្យឃើញពី «អ្វីដែលសិស្សបានដឹងរួចហើយ» «អ្វីដែលសិស្សចង់រៀន» និង «អ្វីដែលសិស្សបានរៀនបន្ទាប់ពីវេទិកា» អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ តារាងនេះធ្វើឲ្យសិស្សមានការត្រិះរិះពិចារណាកាន់តែស៊ីជម្រៅថែមទៀតពីប្រធានបទ និងផ្សារភ្ជាប់ពីអ្វីដែលខ្លួនបានដឹងរួចហើយ និងអ្វីដែលខ្លួនចង់រៀនជាមួយនឹងមេរៀនដែលខ្លួននឹងទទួលបានពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយក៏ជាការបង្ហាញពីទំនាក់ទំនងនៃចំណេះដឹងមុន និងក្រោយវេទិកាដែរ ។ ដំណើរការនៃការធ្វើតារាងK-W-L មានដូចខាងក្រោម ៖

១) បន្ទាប់ពីការប្រមូលតារាងស្ទាបស្ទង់មតិមុនពេលធ្វើវេទិការួច សិស្សត្រូវបានប្រាប់ឲ្យនិយាយប្រាប់សិស្សឯទៀតពី «អ្វីដែលខ្លួនបានដឹង» អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ រួចបំពេញចូលតារាង K ។ សកម្មភាពនេះ អាចបញ្ជាក់បានពីចំណេះដឹងពីមុនរបស់សិស្ស និងអាចធ្វើឲ្យវេទិកាថ្នាក់រៀនទាំងមូលបានដឹងពីព្រឹត្តិការណ៍ដទៃទៀតនៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលសិស្សមិនទាន់បានដឹង ។

២) បន្ទាប់មក សិស្សត្រូវបានលើកទឹកចិត្តឲ្យសួរសំណួរពី «អ្វីដែលខ្លួនចង់រៀនឬចង់ដឹង» រួចបំពេញចូលក្នុងតារាង W ។ ក្នុងផ្នែកនេះ សិស្សត្រូវបានផ្តល់ឱកាសឲ្យកំណត់គោលដៅសិក្សារបស់ខ្លួន និងណែនាំឲ្យមានការពិភាក្សាពីអ្វីដែលខ្លួនចង់ដឹង ។ នេះជាកិច្ចការសំខាន់មួយដែលចង្អុលបង្ហាញពីចំណុចសំខាន់ៗដែលសិស្សចង់ដឹង និងប្រធានបទអ្វីដែលគ្រូត្រូវជ្រើសរើសមកធ្វើបទបង្ហាញសម្រាប់ថ្ងៃនេះ ។

៣) បន្ទាប់ពីបញ្ចប់ផ្នែកនៃតារាង L រួចមក បទបង្ហាញដោយសង្ខេបពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យត្រូវបានធ្វើឡើង ។ រូបភាព គំនូរ និងប្រវត្តិរឿងរ៉ាវផ្ទាល់របស់ជនរងគ្រោះ ត្រូវបានលើកឡើងក្នុងពេលធ្វើបទបង្ហាញនេះ ។ ដោយផ្អែកទៅលើតារាងW ដែលមាននៅលើក្តារខៀន បទបង្ហាញពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បានឆ្លើយតបទៅនឹងវត្ថុបំណងរបស់សិស្ស ដែលចង់ដឹងព័ត៌មានពិស្តារសម្រាប់សំណួររបស់ខ្លួន ។

៤) បន្ទាប់ពីការធ្វើបទបង្ហាញរួច សិស្សត្រូវបានអនុញ្ញាតឲ្យបង្ហាញពី «អ្វីដែលខ្លួនបានរៀន» ពីវេទិកានេះ រួចសរសេរនៅលើក្តារខៀនក្នុងតារាង L ។ ធ្វើដូច្នេះ គឺដើម្បីពង្រីកចំណេះដឹងបន្ថែមទៀតដែលបានមកពីការធ្វើវេទិកាថ្នាក់រៀន និងដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាផ្សេងទៀត ។

*គ) បញ្ចាំងខ្សែភាពយន្តឯកសារ ៖ គុកទួលស្លែង, តំបន់រំដោះឆ្នាំ១៩៧៣ និងកុមារកម្ពុជា*

បន្ទាប់ពីតារាង K-W-L និងការធ្វើបទបង្ហាញពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់ ខ្សែភាពយន្តឯកសារខ្លីមួយត្រូវបានបញ្ចាំងឲ្យសិស្សមើល ។ ខ្សែភាពយន្តនេះ បង្ហាញឲ្យឃើញពីទិដ្ឋភាពដ៏រន្ធត់ក្នុងមន្ទីរស-២១ ហៅ គុកទួលស្លែង អំពើឃោរឃៅដែលគ្មានលក្ខណៈជាមនុស្ស ដែលប្រព្រឹត្តចំពោះអ្នកទោសនៅក្នុងគុក វិធីក្នុងការធ្វើទារុណកម្មទៅលើបុរស ស្ត្រី និងកុមារ និងការសម្លាប់យ៉ាងសាហាវ ។ ការប្រើប្រាស់រូបភាពផ្សេងៗជួយដល់សិស្សឲ្យមានការគិតយ៉ាងស៊ីជម្រៅពីវិនាសកម្មក្នុងរបបខ្មែរក្រហម ។ ការបង្ហាញសាកសពមនុស្សដែលស្លាប់ ដោយកង្វះអាហារូបត្ថម្ភ និងការស្រែកឃ្លានរបស់កុមារ បានរំឭកប្រាប់សិស្សពីការឆ្លើយតបរបស់កម្មាភិបាលខ្មែរក្រហមយ៉ាងលំបាក និងអមនុស្សធម៌ចំពោះជនរងគ្រោះ ។ ការមើលឃើញនេះ អាចពញ្ញាក់អារម្មណ៍សិស្សឲ្យផ្សារភ្ជាប់ការសិក្សារបស់ខ្លួនទៅនឹងព្រឹត្តិការណ៍នានាដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។

*ឃ) សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*

បទបង្ហាញពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បានធ្វើឡើងបន្ទាប់ពីការធ្វើបទបង្ហាញពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដោយសង្ខេបរួច ។ គោលបំណងសំខាន់របស់គម្រោងនេះ គឺចង់បង្ហាញពីចំណុចសំខាន់ៗមួយចំនួនដែលសិស្សត្រូវដឹង បន្ទាប់ពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរួច ។ សិស្សត្រូវតែដឹងពីសារសំខាន់នៃការចងចាំប្រវត្តិសាស្ត្រសម្រាប់អនាគតកម្ពុជា ។ ខាងក្រោមនេះគឺជាចំណុចសំខាន់ៗពីរ ដែលសិស្សត្រូវស្វែងយល់ ៖

១) យល់ដឹងឲ្យស៊ីជម្រៅពីបញ្ហាសិទ្ធិមនុស្ស ដែលសិទ្ធិទាំងនោះត្រូវបានរំលោភបំពាន ។

២) ចាំបាច់ត្រូវទប់ស្កាត់ការកើតឡើងវិញ នូវអំពើប្រល័យពូជសាសន៍នាពេលអនាគត តាមរយៈការលើកកម្ពស់ឲ្យមានការផ្សះផ្សា ព្យាបាលរបួសផ្លូវចិត្ត និងការកសាងសន្តិភាព ។

៣) ចាំបាច់ត្រូវសិក្សា និងស្វែងយល់ពីកំហុសឆ្គងពីអតីតកាលសម្រាប់ការកសាងប្រទេសកម្ពុជានាពេលអនាគត ។

*ង) ការស្ទាបស្ទង់មតិក្រោយពេលធ្វើវេទិកា*

ការស្ទាបស្ទង់មតិនេះ គឺជាការវាស់ស្ទង់កម្រិតយល់ដឹងរបស់សិស្សបន្ទាប់ពីបានសិក្សាតាមរយៈការធ្វើវេទិកាថ្នាក់រៀន ។ សំណួរដែលមាននៅក្នុងតារាងស្ទាបស្ទង់មតិមានដូចជា ៖ តើអ្នកជឿថាមានអំពើឃោរឃៅកើតឡើងដែរឬទេ? តើការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ មានសារសំខាន់ដែរឬទេ? និងតើមានការរើសអើងចំពោះមិត្តភក្តិ ដែលជាកូនរបស់អតីតកម្មាភិបាលខ្មែរក្រហមដែរឬទេ? សំណួរទាំងនេះ គឺដូចគ្នាទៅនឹងសំណួរដែលមាននៅក្នុងតារាងស្ទាបស្ទង់មតិមុនពេលធ្វើវេទិកា ហើយក៏ជាសំណួរដែលអាចឲ្យមានការស្វែងយល់ពីលទ្ធផលនៃការធ្វើវេទិកាថ្នាក់រៀននេះដែរ ។ លើសពីនេះទៀត ការស្ទាបស្ទង់មតិក្រោយការធ្វើវេទិកា ក៏មានបន្ថែមសំណួរមួយចំនួនទៀតដូចជា ៖ តើការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ អាចនាំឲ្យមានការកសាងសន្តិភាព ការព្យាបាលរបួសផ្លូវចិត្ត ការផ្សះផ្សា និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្នុងពេលអនាគតដែរឬទេ? ម្យ៉ាងវិញទៀត ការស្ទាបស្ទង់មតិក្រោយពេលធ្វើវេទិកាថ្នាក់រៀន ក៏អាចធ្វើឲ្យដឹងពីអារម្មណ៍របស់សិស្សចំពោះការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែរ ។ ក្នុងន័យនេះ ការស្ទាបស្ទង់មតិក្រោយការធ្វើវេទិកា អាចប្រាប់ពីការផ្លាស់ប្តូរឥរិយាបថរបស់សិស្ស តាមរយៈលទ្ធផលនៃមេរៀនប្រវត្តិសាស្ត្រនេះ ។

*ង) ការចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*

នៅចុងបញ្ចប់នៃវេទិកាថ្នាក់រៀន សិស្សានុសិស្សទាំងអស់ដែលបានចូលរួមក្នុងវេទិកាថ្នាក់រៀន បានទទួលសៀវភៅ “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)” ម្នាក់មួយក្បាល ដើម្បីទុកជាឯកសារសម្រាប់ការស្រាវជ្រាវ និងការអានដើម្បីយល់ដឹងឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ។ សិស្សានុសិស្សទាំងអស់ ត្រូវបានលើកទឹកចិត្តឲ្យអាន និងគិតឲ្យស៊ីជម្រៅពីមាតិកាមួយៗនៃសៀវភៅនេះ ។ ការលើកទឹកចិត្តនេះ មិនត្រឹមតែជាស់តឿនឲ្យសិស្សានុសិស្សទាំងអស់ត្រៀមលក្ខណៈសម្រាប់ការប្រឡងបញ្ចប់ឆ្នាំសិក្សាប៉ុណ្ណោះទេ ថែមទាំងក្លាយជាអ្នកដែលមានចំណេះដឹងជ្រៅជ្រះខាងប្រវត្តិសាស្ត្រផង ។

## ការសង្កេត

ចំណុចសំខាន់ៗចំនួន៦ ត្រូវបានសង្កេតឃើញពីការធ្វើវេទិកាថ្នាក់រៀន ដោយអនុលោមទៅតាមការពិនិត្យមើលលើមាតិការបស់វេទិកាថ្នាក់រៀន ការវិភាគពីចម្លើយ កាយវិការ ការសម្ភាសរបស់សិស្ស និងការរៀបចំថ្នាក់រៀន ៖

១) វេទិកាថ្នាក់រៀន បានផ្តល់ឱកាសឲ្យសិស្សានុសិស្សដែលជាជនជាតិភាគតិច មានឱកាសក្នុងការបញ្ចេញយោបល់ និងនិយាយពីប្រវត្តិរឿងរ៉ាវនៃក្រុមគ្រួសារខ្លួនទៅកាន់មិត្តរួមថ្នាក់ ដោយមានការគូសបញ្ជាក់ពីការតស៊ូរបស់ក្រុមជនជាតិភាគតិចដូចជា ចាមមូស្លីម ដែលទទួលរងនូវអំពើប្រល័យពូជសាសន៍ ។ វេទិកានេះបានដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់បទពិសោធន៍ សិក្សារបស់សិស្សជាជនជាតិភាគតិច ដែលប្រវត្តិសាស្ត្រពីមុនរបស់អ្នកទាំងនោះមិនត្រូវបានអើពើ ឬរងផលប៉ះពាល់នៅក្នុងថ្នាក់រៀន ។

២) វេទិកាថ្នាក់រៀន បានលើកទឹកចិត្តឲ្យមានការសន្ទនារវាងសិស្សានុសិស្សជាមួយឪពុកម្តាយខ្លួនឯង និងជាមួយអ្នកដទៃអំពីប្រវត្តិសាស្ត្រនេះ ។ សិស្សានុសិស្សជាច្រើនបានប្រាប់ថា ខ្លួនពិតជាធ្លាប់បានជជែកពីរបបខ្មែរក្រហមជាមួយក្រុមគ្រួសារ ហើយ

ព្រមទាំងបានសម្តែងនូវការដឹងគុណចំពោះឪពុកម្តាយ ដែលបានផ្តល់ឱកាសឲ្យខ្លួនបានយល់ដឹងកាន់តែច្រើនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ជាពិសេសប្រវត្តិរឿងរ៉ាវផ្ទាល់ខ្លួនរបស់គ្រួសារ ។

៣) រយៈពេលនៃការធ្វើវេទិកាថ្នាក់រៀនមានកំណត់ ដែលធ្វើឲ្យសិស្សមួយចំនួនពុំមានឱកាសគ្រប់គ្រាន់ក្នុងការសួរសំណួរ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏សិស្សានុសិស្សទាំងអស់មានអារម្មណ៍ថាខ្លួនមានភាពក្លាហាន និងត្រូវបានផ្តល់កម្លាំងចិត្តដោយវេទិកាថ្នាក់រៀននេះ ។

៤) សិស្សស្រ្តីមួយចំនួនមកពីវិទ្យាល័យទាំង១៥ បានបង្ហាញថា ខ្លួនមានការជឿជាក់ និងមិនពិបាកក្នុងការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឡើយ ។ ជាការពិតណាស់ នៅគ្រប់កម្មវិធីទាំង១៥ នៃការធ្វើវេទិកាថ្នាក់រៀន សិស្សស្រ្តីពិតជាបានសួរសំណួរច្រើនជាងសិស្សប្រុស ។ ចំណុចនេះ បានបង្ហាញឲ្យឃើញពីសមភាពយេនឌ័រយ៉ាងខ្លាំង ។

៥) សិស្សានុសិស្ស បានសម្តែងឲ្យដឹងកាន់តែច្បាស់តាមរយៈការសម្ភាស និងការបំពេញតារាងស្ទាបស្ទង់មតិថា វេទិកាថ្នាក់រៀននេះ បានធ្វើឲ្យខ្លួនកាន់តែមានការចាប់អារម្មណ៍ខ្លាំងឡើងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ លើសពីនេះទៀត ចំណាប់អារម្មណ៍របស់សិស្ស ពិតជាបានផ្តល់នូវការលើកទឹកចិត្តឲ្យមានការស្រាវជ្រាវផ្ទាល់ខ្លួនពីប្រវត្តិសាស្ត្រនេះដែរ ។

៦) ជាចុងក្រោយ វេទិកាថ្នាក់រៀននេះត្រូវបានទទួលស្គាល់ដោយអ្នកជំនាញអន្តរជាតិល្បីៗ និងអ្នកអប់រំជាច្រើននាក់ ។ នេះអាចសរបញ្ជាក់ឲ្យឃើញថា វេទិកាថ្នាក់រៀនបានទទួលកម្រិតនៃភាពស្របច្បាប់ជាសកល ដែលជាការផ្សារសំខាន់នៅក្នុងគោលបំណងដើម្បីទាក់ទាញ និងធនធានទេពកោសល្យល្អបំផុតដើម្បីអភិវឌ្ឍកម្មវិធីអប់រំមួយដែលលេចធ្លោនៅក្នុងប្រទេសកម្ពុជា ។

ការសង្កេតទាំងនេះ បានគូសបញ្ជាក់ពីលទ្ធផលជាវិជ្ជមានដែលលើសពីគោលបំណងរបស់កម្មវិធីនេះទៀត ។ ការអនុវត្តវេទិកាថ្នាក់រៀន និងសកម្មភាពផ្ទាល់ក្នុងការធ្វើវេទិកា គឺមានផលប្រយោជន៍សម្រាប់សិស្សានុសិស្សទាំងអស់ ដោយមិនរើសអើងជាតិសាសន៍ និងបានជួយបង្ហាញពីការកើតឡើងនៃអំពើប្រល័យពូជសាសន៍ ដែលបានប៉ះពាល់ដល់ប្រជាជនកម្ពុជាទាំងអស់ ។ លើសពី


ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩) ដល់សិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ

នេះទៀត របៀបក្នុងការបង្រៀន ក៏បានលើកទឹកចិត្តសិស្សឲ្យព្យាយាមរៀនសូត្រទៅលើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឲ្យកាន់តែស៊ីជម្រៅ និងបន្តធ្វើកិច្ចការស្រាវជ្រាវផ្ទាល់ខ្លួនបន្ថែមទៀតតាមរយៈវិទ្យាល័យដែលខ្លួនសិក្សា ។ ដូច្នេះ ការសង្កេតខាងលើនេះបានបង្ហាញពីអ្វីដែលវេទិកាថ្នាក់រៀននេះបានទទួលប្រយោជន៍បទពិសោធន៍ការសិក្សា និងសេចក្តីប្រាថ្នារបស់សិស្សានុសិស្សដើម្បីបន្ថែមទៅលើមាតិកាប្រវត្តិសាស្ត្រដែលត្រូវបានបង្រៀន ។

**ការពិភាក្សាពីលទ្ធផលនៃការធ្វើវេទិកាថ្នាក់រៀន**

ទិន្នន័យទាំងអស់ដែលបានមកពីការស្ទាបស្ទង់មតិមុន និងក្រោយការធ្វើវេទិកាថ្នាក់រៀន គឺត្រូវបានចងក្រងជាក្រាហ្វិក **(graphs and pie chart)** និងវិភាគ ដោយប្រើប្រាស់ មីក្រូសូហ្វ អ៊ិចសែល **(Microsoft Excel)** ។ ក្រោយពីការវិភាគទៅទិន្នន័យដែលទទួលបានពីការស្ទាបស្ទង់មតិមុនពេល និងក្រោយពេលធ្វើវេទិកាថ្នាក់រៀន នៅវិទ្យាល័យទាំង១៥ លទ្ធផលបានបង្ហាញដូចខាងក្រោម៖

◆ សិស្សចូលរួមមានចំនួន៩៥០នាក់ (ស្រី៥២២នាក់ ស្មើនឹង ៥៥ភាគរយនៃចំនួនសិស្សសរុប)

◆ សិស្សចំនួន៩៤១នាក់ ស្មើនឹង ៩៩ភាគរយ ជឿថាការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺពិតជាមានសារសំខាន់ ។

◆ សិស្សចំនួន៩២២នាក់ ស្មើនឹង៩៧ភាគរយ ចង់ឲ្យមានការបង្រៀនប្រវត្តិសាស្ត្រនេះនៅក្នុងទូទាំងប្រទេសកម្ពុជា និងអាស៊ាន ។

◆ សិស្សចំនួន៨៩៣នាក់ ស្មើនឹង ៩៤ភាគរយ ជឿជាក់ថាការចងចាំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺមានសារសំខាន់ណាស់ ។

◆ សិស្សចំនួន ៨៧៤នាក់ ស្មើនឹង៩២ភាគរយ ចង់ឲ្យមានការផ្សព្វផ្សាយពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ តាមរយៈបណ្តាញសង្គមផ្សេងៗ ។

តួលេខទាំងនេះបានបង្ហាញថា សិស្សភាគច្រើនលើសលុបចង់ឲ្យមានការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា និងប្រទេសដទៃទៀត ។ សិស្សវិទ្យាល័យទាំង ៩៥០នាក់មកពីវិទ្យាល័យ ចំនួន១៥ក្នុងរាជធានីភ្នំពេញ គឺជាឧទាហរណ៍មួយដែលបញ្ជាក់យ៉ាងច្បាស់ពីតម្រូវការរបស់ខ្លួនចំពោះការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ តួលេខនេះ ស៊ីគ្នាទៅនឹងការចង់ដឹងចង់ឃើញរបស់សិស្ស ដែលមិនត្រឹមតែផ្តល់តម្លៃចំពោះការអប់រំដ៏មានសារសំខាន់ពីប្រវត្តិសាស្ត្រនេះ និងអ្វីដែលជាគោលបំណងសម្រាប់ការកសាងសន្តិភាព ការផ្សះផ្សា និងការទប់ស្កាត់អំពោះប្រល័យពូជសាសន៍នាពេលអនាគតប៉ុណ្ណោះទេ ថែមទាំងចង់សិក្សាច្រើនថែមទៀតពីវេទិកាថ្នាក់រៀននេះ តាមរយៈបណ្តាញសង្គម និងប្រភពធនធានតាមប្រព័ន្ធ អ៊ិនធឺណែតផ្សេងៗទៀត ។ ទាំងអស់នេះ គឺជាការបង្ហាញឲ្យឃើញថា ការអប់រំពីអំពើប្រល័យពូជសាសន៍គឺជាតម្រូវការចាំបាច់ និងមានសារសំខាន់បំផុត ។

◆ សិស្សចំនួន៦៧នាក់ ស្មើនឹង ៧ភាគរយ បាននិយាយថាខ្លួនមានចំណេះដឹងច្រើនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅមុនពេលធ្វើវេទិកាថ្នាក់រៀន ។ ប៉ុន្តែចំនួននេះបានកើនឡើងរហូតដល់៧៧៩នាក់ ស្មើនឹង៨២ភាគរយ បន្ទាប់ពីការធ្វើវេទិកាត្រូវបានបញ្ចប់ ។

◆ សិស្សចំនួន៨៨៤នាក់ ស្មើនឹង៩៣ភាគរយ គិតថាការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺលើកកម្ពស់ឲ្យមានការកសាងសន្តិភាពនៅកម្ពុជា ។

◆ សិស្សចំនួន៨៩៣នាក់ ស្មើនឹង៩៤ភាគរយ គិតថាការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺលើកកម្ពស់ឲ្យមានការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា ។

◆ សិស្សចំនួន៧៨៩នាក់ ស្មើនឹង៨៣ភាគរយ គិតថាការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺលើកកម្ពស់ឲ្យមានការផ្សះផ្សាជាតិនៅកម្ពុជា ។

ចំណុចទាំងអស់ខាងលើ បានបង្ហាញពីប្រសិទ្ធភាពរបស់វេទិកាថ្នាក់រៀននេះ ក្នុងការសម្រេចបាននូវគោលបំណងដែលបានគ្រោងទុក ។ នៅពេលដែលសិស្សម្នាក់ៗចាកចេញពីទីតាំងធ្វើវេទិកាថ្នាក់រៀនក្រោយពេលបញ្ចប់ អ្នកទាំងនោះបានពាំនាំទៅជាមួយនូវការយល់ដឹងច្រើនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងយល់ច្បាស់ពីគោលបំណងនៃការសិក្សាប្រវត្តិសាស្ត្រនេះ គឺ

ដើម្បីកសាងសន្តិភាព និងការផ្សះផ្សាជាតិ ដែលជាស្ពានឆ្ពោះទៅរកការទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្នុងពេលអនាគត ។ យោងតាមលទ្ធផលដែលបានមកពីការស្ទាបស្ទង់មតិបានបង្ហាញថា កម្មវិធីសម្រាប់វេទិកាថ្នាក់រៀននេះ នៅតែមានប្រសិទ្ធភាពសម្រាប់ការអនុវត្តនៅតាមបណ្តាវិទ្យាល័យនានាក្នុងប្រទេសកម្ពុជា ។

ជារួម ស្ថិតិតួលេខដែលបានបង្ហាញ និងរៀបរាប់ខាងលើ ឆ្លុះបញ្ចាំងឲ្យឃើញតម្រូវការធំៗចំនួនពីរគឺ៖

១) ការអប់រំពីអំពើប្រល័យពូជសាសន៍ ឬការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) គឺជាកម្មវិធីសិក្សាដែលសិស្សានុសិស្សចង់ឲ្យមាននៅក្នុងកម្មវិធីសិក្សានៅតាមវិទ្យាល័យនៅកម្ពុជា ។

២) ការអប់រំពីអំពើប្រល័យពូជសាសន៍ ឬការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) គឺនៅតែជាកម្មវិធីដែលកំពុងដំណើរការនៅក្នុងកម្រិតវិទ្យាល័យ ។

**សេចក្តីសន្និដ្ឋាន**

ទិន្នន័យ និងការសង្កេតទៅលើការអនុវត្តវេទិកាថ្នាក់រៀននាពេលកន្លងមក បានបង្ហាញថា គម្រោងនេះបានទទួលជោគជ័យក្នុងការសម្រេចបាននូវគោលបំណងរបស់ខ្លួន ។ ភ័ស្តុតាងរៀបរាប់ខាងលើបានបង្ហាញថា ការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺមានសារសំខាន់បំផុតសម្រាប់ភាពថ្កុំថ្កើងយូរអង្វែងរបស់ប្រទេសកម្ពុជា ។ ដូចបានរៀបរាប់នៅក្នុងគោលបំណងរបស់គម្រោងនេះ វេទិកាថ្នាក់រៀនបង្ហាញថា ការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតសម្រាប់ផ្លាស់ប្តូរឥរិយាបថរបស់ក្មេងជំនាន់ក្រោយ ឲ្យគិតពីការកសាងសន្តិភាព ការផ្សះផ្សា ការព្យាបាលរបួសផ្លូវចិត្ត និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។ ខណៈដែលផលប៉ះពាល់ពេញលេញនៃការផ្លាស់ប្តូរជាវិជ្ជមានទាំងនេះ នៅមិនទាន់ដឹងក្នុងពេលនេះក៏ដោយ ក៏ហេតុការណ៍នៅចំពោះមុខមួយបានបង្ហាញថា សិស្សច្រើនជាង៨៨០នាក់បានគិតគូរដល់ការកសាងសន្តិភាព និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត ដែលចេញមកពីការធ្វើវេទិកានេះ ។ លើសពីនេះទៀត ស្ថិតិក៏បានគូសបញ្ជាក់ដែរពីតម្រូវការសម្រាប់ការអប់រំអំពើប្រល័យពូជសាសន៍ និងការទទួលស្គាល់របស់សិស្សពីសារសំខាន់ក្នុងការសិក្សាប្រវត្តិសាស្ត្ររបស់ខ្លួន ។ ផលប្រយោជន៍នៃការសិក្សាជាសកលដែលត្រូវបានបង្កើតឡើងដោយវេទិកានេះ គឺជាភ័ស្តុតាងបន្ថែមមួយដែលបញ្ជាក់ថា ការអប់រំស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅតែជាតម្រូវការចាំបាច់ និងស្របច្បាប់នៅក្នុងសង្គមកម្ពុជា ។

ការសន្និដ្ឋានមួយផ្សេងទៀត គឺភាពជោគជ័យរបស់គម្រោងនេះក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ជាមួយសិស្សានុសិស្សទាំង៩៥០នាក់ នៃវិទ្យាល័យទាំង១៥ ។ ការធ្វើបទបង្ហាញ ការប្រើប្រាស់តារាង *K-W-L* ការស្ទាបស្ទង់មតិ ការបញ្ចាំងភាពយន្តឯកសារ ការឆ្លើយសំណួរទៅកាន់សិស្ស និងការផ្តល់ឱកាសដល់សិស្សឲ្យឆ្លើយសំណួររបស់សិស្សឯទៀត គឺបានអភិវឌ្ឍឲ្យមានការសិក្សាបែបបើកទូលាយ ដែលរួមផ្សំនឹងសកម្មភាពរបស់សិស្សក្នុងការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ទម្រង់នេះ គឺមានភាពងាយស្រួលក្នុងការអនុវត្តសម្រាប់ការពង្រីកវេទិកាថ្នាក់រៀននេះនៅទូទាំងប្រទេសកម្ពុជានាពេលអនាគត ។

ការអប់រំអំពើប្រល័យពូជសាសន៍នៅកម្ពុជា មានសក្តានុពលគ្រប់គ្រាន់ក្នុងការបើកទូលាយឲ្យពិភពលោកបានដឹង និងមិនត្រឹមតែបានផ្តល់ឱកាសសម្រាប់ការចង់បានសន្តិភាព និងស្ថេរភាពនៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ឱកាសសម្រាប់តំណភ្ជាប់ទៅកាន់បរិបទអន្តរជាតិទៀត តាមរយៈការអនុវត្តគោលការណ៍សិទ្ធិមនុស្សជាសកល ការស្រាវជ្រាវបែបសហការ និងការបង្កើនទំនាក់ទំនងខាងក្រៅពីទស្សនវិស័យរបស់សិស្ស ។ កម្ពុជានៅតែរស់នៅក្រោមស្រមោលនៃអតីតកាលរបស់ខ្លួន ដែលវិស័យអប់រំនៅតែទទួលរងផលប៉ះពាល់យ៉ាងខ្លាំងដោយខ្មែរក្រហម ។ ដើម្បីធ្វើឲ្យប្រទេសមួយនេះងើបចេញពីស្រមោលនេះបាន ប្រព័ន្ធអប់រំដ៏សម្បូរបែបមួយគួរតែត្រូវបានផ្តល់ឲ្យ ដើម្បីបង្កើតឲ្យមានការគិតគូរដ៏ទូលំទូលាយពេញលេញជាច្រើនទៀត ។ ប្រសិនបើគ្មានបរិបទនៃប្រវត្តិសាស្ត្រទេ ការកសាងសម្រាប់អនាគតកាលគឺមិនអាចកើតមានឡើយ ។ ការយល់ដឹងអំពីអំពើប្រល័យពូជសាសន៍គឺជាជំហានសំខាន់មួយក្នុងការកសាងអនាគតរបស់កម្ពុជា ។

**ផេង ពង្សរ៉ាស៊ី និង អាណាម៉េ ខឹសខ៉ាណាថាន**

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី : អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

### ៣) អត្តសញ្ញាណជាយ និងការប្រកួតប្រជែង

*អត្តសញ្ញាណជាយរបស់ជនជាតិចាម ស្របយ៉ាងប្រសើរទៅតាមទ្រឹស្តីអត្តសញ្ញាណរបស់លោក ហល (**Hall**) ដែលយល់ថា អត្តសញ្ញាណជាដំណើរកាលកំពុងតែបន្ត ឬស្ថិតថេរយូរអង្វែង ។ នៅក្នុងសៀវភៅនេះ អ្នកនិពន្ធបានពិនិត្យប្រភេទផ្សេងនៃអត្តសញ្ញាណរបស់ជនជាតិចាម ដែលជាអត្តសញ្ញាណជាយប្រៀបធៀបទៅនឹងអត្តសញ្ញាណស្នូល ។ អត្តសញ្ញាណជាយទាំងអស់នេះស្ថិតនៅក្នុងផ្នែកខាងមុខនៃការតស៊ូរបស់ជនជាតិចាម ដើម្បីបង្កើតខ្លួនឯងឡើងវិញដោយផ្អែកលើការផ្លាស់ប្តូរនៃបរិយាកាសសង្គមកម្ពុជា និងតាមរយៈព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនានា ដូចដែលបានពិនិត្យនៅក្នុងសៀវភៅនេះ ។ ទោះបីជាអត្តសញ្ញាណជាយកំពុងតែប្តូរ និងកែប្រែរូបរាង ការផ្លាស់ប្តូរនេះប្រព្រឹត្តឡើង ទៅតាមគោលការណ៍កំណត់ដោយអត្តសញ្ញាណស្នូលទាំងពីរ ។ ជនជាតិចាមត្រឡប់ទៅប្រើប្រាស់អត្តសញ្ញាណស្នូល នៅពេលមានវិបត្តិដោយយកវាធ្វើជាមូលដ្ឋាន ដើម្បីស្តាបនាឡើងវិញនូវអត្តសញ្ញាណជាយ ដែលមានស្រាប់រួមទាំងបង្កើតអត្តសញ្ញាណថ្មីផងដែរ ។*

*លើសពីនេះទៀត ការប្រកួតប្រជែងក្នុងដំណើរការស្តាបនាឡើងវិញនូវអត្តសញ្ញាណជាយ បណ្តាលឲ្យអត្តសញ្ញាណស្នូលមួយចំនួនមានអាទិភាព ជាងអត្តសញ្ញាណស្នូលផ្សេងទៀតជាបណ្តោះអាសន្ន ។ អ្វីទាំងអស់នេះបានបង្ហាញយ៉ាងច្បាស់នៅក្នុងសៀវភៅនេះតាមរយៈព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពីរដ៏សំខាន់ ។ ក្នុងរបប លន់ នល់ ដោយសារតែបរិយាកាសសង្គម និងនយោបាយថ្មី ជាពិសេសសង្គ្រាមរវាងកងទ័ព លន់ នល់ គាំទ្រដោយសហរដ្ឋអាមេរិក និងអ្នកកាន់លទ្ធិកុម្មុយនីស្ត គាំទ្រដោយវៀតណាម ជនជាតិចាមបាន*



*ជនជាតិចាមសំពះយ៉ាំងនៅវិហារ*

ផ្តល់អាទិភាពទៅលើអត្តសញ្ញាណសាសនាជាងអត្តសញ្ញាណជាតិពន្ធុតាមរយៈការបង្កើតស្ថានប័ននយោបាយ ដើម្បីរំដោះស្រុកកំណើតរបស់ខ្លួនពីប្រទេសវៀតណាម ។ ប៉ុន្តែចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ ជនជាតិចាមផ្តល់អាទិភាពទៅលើអត្តសញ្ញាណសាសនាជាងអត្តសញ្ញាណជាតិពន្ធុ ពីព្រោះនិន្នាការសកលលោកនាពេលបច្ចុប្បន្នមានទំនោរទៅលើអ៊ីស្លាមជាងជាតិនិយម ។ យ៉ាងណាមិញ ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងកម្ពុជា និងវៀតណាម មិនសូវអំណោយផលចំពោះស្មារតីប្រឆាំងវៀតណាមនោះទេ ។

សៀវភៅនេះ បានសិក្សាអត្តសញ្ញាណជាយផ្សេងៗគ្នាជាច្រើន ដែលអត្តសញ្ញាណទាំងនោះកំពុងស្ថិតក្នុងដំណើរការផ្លាស់ប្តូរចរចា និងអះអាង ។ ទាំងអត្តសញ្ញាណស្នូល និងអត្តសញ្ញាណជាយក៏ត្រូវបានសិក្សាក្នុងរយៈពេលវេលាខុសៗគ្នានៅក្នុងសៀវភៅ ដើម្បីស្វែងយល់ពីមូលហេតុដែលនាំឲ្យជនជាតិមានសភាពដូចនាពេលបច្ចុប្បន្ន ។

## អត្តសញ្ញាណនិកាយ

សៀវភៅនេះ បានកំណត់អត្តសញ្ញាណនិកាយខុសប្លែកពីអត្តសញ្ញាណសាសនាស្នូល ដែលជាសាសនាអ៊ីស្លាម ដោយផ្អែកលើហេតុផលពីរសំខាន់ ។ ទីមួយ អត្តសញ្ញាណសាសនាអ៊ីស្លាមមានឋានៈខ្ពស់ជាងអត្តសញ្ញាណនិកាយអ៊ីស្លាម ។ អត្តសញ្ញាណអ៊ីស្លាមត្រូវបានប្រៀបធៀបជាមួយព្រះពុទ្ធសាសនា និងសាសនាដទៃទៀត ដើម្បីបង្ហាញភាពខុសគ្នា គ្រាដែលអត្តសញ្ញាណនិកាយត្រូវបានប្រៀបធៀបជាមួយក្រុមនិកាយផ្សេងៗក្នុងសាសនាអ៊ីស្លាម ។ ទោះបីជា ជនជាតិចាមត្រូវបានហាមឃាត់មិនឲ្យប្តូរទៅគោរពសាសនាផ្សេង ពួកគេអាចផ្លាស់ប្តូរទៅគោរពប្រតិបត្តិនិកាយអ៊ីស្លាមផ្សេងទៀត ដូចជាការផ្លាស់ប្តូរនិកាយក្នុងចំណោម ក្រុមអ៊ីម៉ាមសាន់ តាប្លីហ្គ ចាម៉ាត និង សាវ៉ាហ៊ិន ។ ជាការពិតទៅ ការស្រាចស្រង់សាសនាសំដៅទៅលើការកែប្រែនិកាយមិនមែនការផ្លាស់ប្តូរសាសនាអ៊ីស្លាមទាំងមូលនោះទេ ពីព្រោះសាសនាអ៊ីស្លាមរាប់បញ្ចូលនិកាយនោះទេ ។

ទីពីរ មូស្លីមនៅទូទាំងពិភពលោក ដែលមានជាតិពន្ធុ និងប្រវត្តិខុសប្លែកពីគ្នា ក៏ចាត់ទុកខ្លួនឯងជាក្រុមតែមួយ ទោះបីជាពួកគេគោរពនិកាយស៊ុននី សាហ៊ុអ៊ី ដាក់វ៉ះ ឬសាវ៉ាហ៊ី ។ ជនជាតិចាម អាចទទួលបានបទពិសោធន៍អត្តសញ្ញាណសាសនារួមគ្នានេះ នៅពេលពួកគេធ្វើធម្មយាត្រា ទៅកាន់ទីក្រុងម៉ាកាស់ ដោយសារនៅទីនោះពួកគេនឹងជួបជាមួយមូស្លីមដទៃទៀតមកពីប្រទេសផ្សេងៗគ្នា និងឋានៈខុសគ្នា ។ ការធ្វើធម្មយាត្រាទៅកាន់ទីក្រុងម៉ាកាស់ធ្វើឲ្យជនជាតិចាមដឹងថា ពួកគេមិនត្រឹមតែមានទំនាក់ទំនងជាមួយមូស្លីមទាំងឡាយនៅប្រទេសកម្ពុជា ពួកគេទាក់ទងជាមួយសហគមន៍មូស្លីមនៅទូទាំងពិភពលោក ដើម្បីទទួលជំនួយជាកម្លាំងចិត្ត និងការអភិវឌ្ឍ ។ ថ្វីបើជនជាតិចាម គោរពប្រតិបត្តិនិកាយសាសនាអ៊ីស្លាមផ្សេងៗពីគ្នាក៏ដោយ ពួកគេនៅតែមានអត្តសញ្ញាណសាសនាដូចគ្នា តែអត្តសញ្ញាណសាសនារបស់ពួកគេខុសពីក្រុមដទៃទៀតនៅក្នុងប្រទេសកម្ពុជា ។

អត្តសញ្ញាណនិកាយ សំដៅទៅលើការប្រតិបត្តិសាសនាអ៊ីស្លាម ដាច់ដោយឡែក និងច្បាស់លាស់មួយក្នុងចំណោមជនជាតិចាម ។ អត្តសញ្ញាណប្រភេទនេះមានសារសំខាន់ណាស់សម្រាប់ជនជាតិចាម ពីព្រោះអត្តសញ្ញាណនិកាយអាចកំណត់ថា តើជំនួយប្រភេទណាដែលជនជាតិចាមនឹងទទួលបានពីក្រុមអ៊ីស្លាមនៅជុំវិញពិភពលោក និងម្ចាស់ជំនួយណានឹងផ្តល់ការឧបត្ថម្ភទាំងអស់នោះ ទៅជនជាតិចាម ។ អត្តសញ្ញាណនិកាយក៏កំណត់ពីសតិអារម្មណ៍ ការអភិវឌ្ឍខាងផ្នែកសេដ្ឋកិច្ច និងសង្គមរបស់សហគមន៍ជនជាតិចាម រួមទាំងទស្សនវិជ្ជារបស់បុគ្គលចាមម្នាក់ៗ ពីព្រោះតែសារសំខាន់ទាំងអស់នេះ និងស្ថានភាពសាសនាអ៊ីស្លាមជាសកល ជនជាតិចាមបានព្យាយាមកសាងអត្តសញ្ញាណនិកាយរបស់ខ្លួនឡើងវិញចាប់តាំងពីការចាប់ផ្តើមនៃប្រវត្តិសាស្ត្ររបស់ខ្លួន ។ ជួនកាល ការគោរពប្រណិប័តន៍និកាយផ្សេងៗពីគ្នាបែបនេះបណ្តាលឲ្យមានអំពើហិង្សា និងការបែងចែកបក្សពួកនៅក្នុងសហគមន៍ចាម ។ អត្តសញ្ញាណនិកាយតែងតែផ្លាស់ប្តូរ និងពិបាកក្នុងការធ្វើឲ្យទៅជាដាក់លាក់ ពីព្រោះវាត្រូវកំណត់ ដោយលក្ខខណ្ឌនៅតាមមូលដ្ឋាន ក្នុងតំបន់ និងសកល ។ ជនជាតិចាមអាចត្រឹមតែទទួលយកលក្ខខណ្ឌទាំងអស់នោះ និងកែសម្រួលការប្រតិបត្តិសាសនារបស់ខ្លួនបានតែប៉ុណ្ណោះ ។

ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០រហូតដល់ឆ្នាំ១៩៧៥ ក្រុមអ៊ីស្លាមពីរ ដែលត្រូវបានស្គាល់ថា ជាក្រុមចាស់ និងក្រុមថ្មីមានជម្លោះជាមួយគ្នា ។ មុនរយៈពេលនោះ អត្តសញ្ញាណនិកាយមួយ

ផ្សេងទៀត ដែលត្រូវបានស្គាល់ថា ជំនឿចម្រុះសាសនាបានកើតឡើង ។ ជនជាតិចាមបានរៀបចំអត្តសញ្ញាណនិកាយរបស់ខ្លួនដោយបង្កើតប្រព័ន្ធជំនឿសាសនាចម្រុះ និងបានដកយកផ្នែកខ្លះនៃការប្រតិបត្តិរបស់សាសនាហិណ្ឌូ និងព្រះពុទ្ធសាសនា មកប្រតិបត្តិក្នុងសាសនារបស់ខ្លួន ។ ជនជាតិចាមមានជំនឿលើធម្មជាតិ ដូច្នេះពួកគេធ្វើការបន់ស្រន់អារក្សអ្នកតារក្សាដែនដីបន្ថែមលើការធ្វើសំយ៉ាំង ទៅកាន់ព្រះតែមួយក្នុងសាសនាអ៊ីស្លាម ។ អត្ថប្រយោជន៍នៃការជឿបែបនេះអនុញ្ញាតឲ្យជនជាតិចាមរស់យ៉ាងមានសេចក្តីសុខជាមួយជនជាតិខ្មែរ ដែលជាអ្នកគ្រប់គ្រងរាជរដ្ឋាភិបាល និងគ្រាមួយ រាជរដ្ឋាភិបាលខ្មែរបានពិភាក្សាថាតើគួរចាត់ទុកជនជាតិចាមជាជនបរទេសដែរឬទេ ។ អត្តសញ្ញាណនិកាយរបស់ពួកគេមិនអាចកកើតឡើងតែឯងបាននោះទេ ។ សូម្បីតែនៅក្នុងអំឡុងដើមសតវត្សទី២០ ជនជាតិចាមមួយចំនួនអាចធ្វើដំណើរពីប្រទេសកម្ពុជាទៅប្រទេសម៉ាឡេស៊ី និងជនជាតិចាមមួយចំនួនតូចទៀតមានលទ្ធភាពអាចធ្វើដំណើរឆ្ងាយពីអាស៊ីអាគ្នេយ៍ដូចជា លោក អ៊ីម៉ាម អាលី មូសា និងសហសេវិករបស់គាត់ ។ ពួកគាត់បានព្យាយាមថែរក្សាការពារកុំឲ្យអត្តសញ្ញាណនិកាយរបស់ជនជាតិចាមមានគម្លាតឃ្លាតឆ្ងាយពេកពីអត្តសញ្ញាណនិកាយរបស់មូស្លីមដទៃទៀតនៅម៉ាឡេស៊ី និងប្រទេសគោរពប្រតិបត្តិសាសនាអ៊ីស្លាមនានា ។ ទន្ទឹមនឹងគ្នានេះដែរ មូស្លីមម៉ាឡេបានបញ្ចូលការប្រតិបត្តិសាសនាអ៊ីស្លាមរបស់ខ្លួនជាមួយសាសនានៅតាមតំបន់ ។

ចាប់ផ្តើមពីទសវត្សរ៍ឆ្នាំ១៩៥០ ជនជាតិចាមបានចាប់ផ្តើមចោទសួរពីអត្តសញ្ញាណនិកាយរបស់ខ្លួន ដែលការប្រតិបត្តិសាសនាអ៊ីស្លាមត្រូវបានផ្សារភ្ជាប់ជាមួយសាសនាហិណ្ឌូ និងជំនឿលើធម្មជាតិ ។ ការផ្លាស់ប្តូរនេះបាននាំចូលមកប្រទេសកម្ពុជាដោយអ្នកប្រាជ្ញត្រាច់ចរដូចជា អ៊ីម៉ាម អាលី ម៉ូសា, អ៊ីម៉ាម អាមេដ ឥណ្ឌូ និងសហសេវិកម៉ាឡេជាច្រើនរបស់ពួកគេ ។ បញ្ញវន្តទាំងនេះ ទទួលបានចំណេះដឹងថ្មីៗពីសាសនាអ៊ីស្លាមតាមរយៈការផ្លាស់ប្តូរ ដែលកើតមានឡើងនៅក្នុងប្រទេសម៉ាឡេស៊ី ក្នុងការចាប់ផ្តើមបន្សុទ្ធសាសនាអ៊ីស្លាមស្របពេលជាមួយគ្នា ។ ការចោទសួរនេះនាំឲ្យមានការបែកចែកជនជាតិចាមជាក្រុមចាស់ និងក្រុមថ្មី ។ ដូចដែលបានបង្ហាញនៅក្នុងសៀវភៅនេះ ភាពខុសគ្នាយ៉ាងសំខាន់រវាងក្រុមទាំងពីរគឺទំនៀមទម្លាប់ និងការធ្វើបន្សុទ្ធកម្ម ។ អាលី ម៉ូសា ព្យាយាមបន្សុទ្ធ ការប្រតិបត្តិសាសនាអ៊ីស្លាមក្នុងចំណោមជនជាតិចាមដោយវិធីជាច្រើន រួមមានដូចជាការតម្រូវឲ្យបុរសទុកពុកចង្កា និងសក់ ការហាមឃាត់មិនឲ្យស្លៀកសម្លៀកបំពាក់ទាន់សម័យ ប៉ុន្តែមេដឹកនាំ ក្រុមថ្មី ហាជ្ជី វិសឡោះ បានព្យាយាមរក្សាទម្លាប់គោរពុកចង្កា និងសក់សម្រាប់បុរស ។

ក្រុមថ្មីក៏បានគាំទ្រការអប់រំបែបវិទ្យាសាស្ត្រ និងសាសនា ។ ពួកគេបើកចំហចំពោះការសិក្សាបែបវិទ្យាសាស្ត្រ និងប្រើប្រាស់ភាសាខ្មែរ ជាភាសាទីពីរ ដើម្បីឲ្យជនជាតិអាចរីកចម្រើនបានក្នុងសង្គម ។ ក្រុមចាស់មិនយល់ស្របនោះទេ និងថែមទាំងបានប៉ុនប៉ងថែរក្សាអត្តសញ្ញាណវប្បធម៌ចាម ដោយបានហាមឃាត់មិនឲ្យរៀនភាសាខ្មែរ និងមុខវិជ្ជាវិទ្យាសាស្ត្រឲ្យបានជ្រៅជ្រះ ។ ជម្លោះរវាងក្រុមចាស់ និងក្រុមថ្មីនាំមកនូវការបែកបាក់នៅក្នុងសហគមន៍ចាមប្រហែលជាលើកទីមួយ ចាប់តាំងពីពួកគេមកដល់កម្ពុជា ។ ការកត់សម្គាល់មួយដែលគួរឲ្យចាប់អារម្មណ៍ គឺការមិនមានជម្លោះសាសនារវាងជនជាតិចាម និងពុទ្ធសាសនិកខ្មែរ ទោះបីជាជនជាតិចាមធ្លាប់មានជម្លោះជាមួយគ្នាឯងក៏ដោយ ។ អ៊ីម៉ាម អាលី មូសា និងសហសេវិករបស់គាត់ត្រូវបាននិរទេសទៅព្រំដែនថៃ ។ គាត់ធ្លាប់ជាជនរងគ្រោះនៃការប៉ុនប៉ងធ្វើឃាត ប៉ុន្តែក្រោយមកគាត់បានស្លាប់នៅក្នុងសម័យខ្មែរក្រហម ។

ថ្វីបើក្រុមថ្មីហាក់ដូចជាមិនទទួលបានជ័យជម្នះក្នុងការប្រកួតប្រជែងនិកាយក្នុងចំណោមជនជាតិចាមក៏ដោយឥទ្ធិពលរបស់ពួកគេនៅតែមានទៅលើជនជាតិចាមក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។ ឥឡូវនេះ ជនជាតិចាមបានបោះបង់ចោលជំនឿចម្រុះសាសនា និងបន្សុទ្ធការប្រតិបត្តិសាសនាអ៊ីស្លាមរបស់ពួកគេ ។ សព្វថ្ងៃជនជាតិចាមជាច្រើនបានទទួលការអប់រំ និងស្ទើរតែគ្រប់គ្នាអាចនិយាយភាសាខ្មែរយ៉ាងស្ទាត់ជំនាញ លើកលែងតែស្ត្រី និងក្មេងនៅសហគមន៍ចាមដាច់ស្រយាល ។ ទោះបីជាក្រុមថ្មីបានចូលរួមចំណែកយ៉ាងច្រើនក្នុងការផ្លាស់ប្តូរអត្តសញ្ញាណនិកាយរបស់ជនជាតិចាម ការចូលរួមចំណែកនេះមិនត្រូវបានទទួលស្គាល់ ពីព្រោះការបកស្រាយសាសនាអ៊ីស្លាមរបស់ក្រុមថ្មី ត្រូវបានប្រើប្រាស់ជាមូលដ្ឋានគ្រឹះនៃការប្រតិបត្តិសាសនាអ៊ីស្លាមក្នុងចំណោមចាមសាឡាហ្វីនាពេលបច្ចុប្បន្ន ។

ដោយសារតែប្រទេសកម្ពុជាបើកចំហទៅកាន់ពិភពលោកខាងក្រៅ បន្ទាប់ពីសង្គ្រាមត្រជាក់បានបញ្ចប់ អត្តសញ្ញាណនិកាយរបស់ជនជាតិចាមត្រូវបានផ្លាស់ប្តូរដោយគ្មានការរំពឹងទុកជាមុនម្តងទៀត ។ អំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ភាពខុសគ្នានៃអត្តសញ្ញាណនិកាយមិនត្រូវបានចោទសួរដោយហេតុថាជម្លោះនយោបាយ និងមនោគមវិជ្ជាបានបំបែកទាំងប្រជាជនខ្មែរ និងចាម ។ ប៉ុន្តែ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ បន្ទាប់ពីព្រំដែនខណ្ឌចែកនយោបាយត្រូវបានលុបបំបាត់អត្តសញ្ញាណនិកាយបានប្តូរទម្រង់ថ្មីជាច្រើនលើក ។ វាហាក់បីដូចជាជនជាតិចាមយល់ស្របទាំងស្រុងទៅលើការបន្សុទ្ធនៃការប្រតិបត្តិសាសនាអ៊ីស្លាម ដែលជាការបង្រៀននាំចូលមកកម្ពុជាដោយ អាលី មូសា ។ តែការប្រកួតប្រជែងនៅតែបន្ត ជាពិសេសក្នុងចំណោមក្រុមតាប្លីហ្គី ចាម៉ាត និងក្រុមសាលាហ្វី ។ ចំនុចខុសគ្នាសំខាន់រវាងក្រុមទាំងពីរ គឺថាតើមូស្លីមគួរដើរផ្សព្វផ្សាយសាសនាទៅដល់មូស្លីមដទៃទៀតដែរឬទេ? សមាជិកក្រុមដាក់វ៉ះយល់ស្របតាមគំនិតនេះ និងជឿជាក់ថាការដើរផ្សព្វផ្សាយសាសនាអាចជួយផ្លាស់ប្តូរជីវិតជនជាតិចាមជាច្រើននាក់ ជាពិសេស យុវជនចាមដែលពុំមានការងារ និងប្រើប្រាស់ថ្នាំញៀន ។ សម្រាប់ក្រុមសាលាហ្វីវិញ ការដើរផ្សព្វផ្សាយសាសនាមិនគួរធ្វើឡើងទៅកាន់មូស្លីមឡើយ តែគួរធ្វើឡើងទៅកាន់ជនទាំងឡាយដែលមិនមែនជាមូស្លីម ។ ពួកគេយល់ថា ការដើរផ្សព្វផ្សាយសាសនា ខ្ជះខ្ជាយពេលវេលា និងធនធាន ពីព្រោះជនជាតិចាមត្រូវផ្គត់ផ្គង់ខ្លួនឯង ក្នុងអំឡុងពេលដើរផ្សព្វផ្សាយ និងមិនបានរកចរិកាដើម្បីជួយសេដ្ឋកិច្ចក្នុងគ្រួសារ ។

សមាជិកនៃក្រុមដាក់វ៉ះមានជីវភាពក្រីក្រ មិនបានទទួលការអប់រំខ្ពស់ និងជាជនជាតិចាមរស់នៅតាមជនបទ ដែលយល់ថាការដើរផ្សព្វផ្សាយសាសនាមានសារសំខាន់សម្រាប់សហគមន៍របស់ពួកគេ គំនិតបែបនេះបានផ្តល់ឲ្យពួកគេនូវអត្តសញ្ញាណនិកាយភ្ជាប់មកជាមួយអំណាច និងឋានៈ ដែលពុំធ្លាប់មានពីមុនមក ។ សមាជិកនៃក្រុមសាលាហ្វីនៅក្មេងមានចំណេះដឹង ជាជនជាតិចាមនៅទីក្រុងមានទ្រព្យសម្បត្តិច្រើន និងមានមធ្យោបាយអាចទទួលបានការបង្រៀនពីសាសនាអ៊ីស្លាមជាសកល ជាពិសេសអាហារូបករណ៍អ៊ីស្លាមពីប្រទេសឈូងសមុទ្រ ដែលជាដើមកំណើតនៃក្រុមសាលាហ្វី ។ ប្រភពដើមនៃការបកស្រាយសាសនាអ៊ីស្លាមរបស់ក្រុមដាក់វ៉ះ គឺប្រទេសឥណ្ឌា ប៉ាគីស្ថាន និងម៉ាឡេស៊ី ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ភាពខុសគ្នានៃក្រុមទាំងពីរបណ្តាលឲ្យមានអំពើហិង្សា



ជនជាតិចាមនៅឃុំស្វាយឃ្លាំង អានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ - ៧៩)

និងការបែងចែកនៅក្នុងសហគមន៍ចាម ។ មិត្តភក្តិ និងអ្នកជិតខាងក្លាយទៅជាសត្រូវ និងមិននិយាយរកគ្នា ។ វិហារចាមក៏ត្រូវបានបែងចែក ។ នៅពេលដែលមានវិហារតែមួយ នៅក្នុងភូមិក្រុមទាំងពីរមិនសំយ៉ាំងជាមួយគ្នានោះទេ ។ វិហារថ្មីជាច្រើនបានសាងសង់នៅក្នុងភូមិតែមួយទង្វើនេះបាន បំពានទំនៀមទម្លាប់នៃការកសាងវិហារ ។ សព្វថ្ងៃភាពតានតឹងបានកាត់បន្ថយ ទោះបីជាភាពខុសគ្នានៅតែមាន និងអត្តសញ្ញាណនិកាយចាមនៅកំពុងតែប្រកួតប្រជែង និងចរចាក៏ដោយ ។ ជម្លោះនិកាយនេះនាំឲ្យមានជម្លោះនយោបាយជាច្រើនក្នុងចំណោមជនជាតិចាម ជម្លោះទាំងនេះនឹងសង្ខេបនៅខាងក្រោម ។

ក្រុមនិកាយចាមមួយ ដែលដាច់ដោយឡែកពីគេ គឺក្រុមអ៊ីម៉ាមសាន់ សមាជិកនៃក្រុមនេះ ភាគច្រើនរស់នៅក្នុងខេត្តកំពង់ចាម ។ ភាពខុសគ្នាយ៉ាងសំខាន់នៃក្រុមនេះពីសាសនាអ៊ីស្លាមនៅក្នុងប្រទេសកម្ពុជា គឺកាលវិភាគសំយ៉ាំង និងរបៀបសំយ៉ាំង ។ ពួកគេសំយ៉ាំងតែម្តងប៉ុណ្ណោះក្នុងមួយសប្តាហ៍ ជារៀងរាល់រសៀលថ្ងៃសុក្រ ។ម្យ៉ាងទៀត ក្រុមអ៊ីម៉ាមសាន់ប្រារព្ធពិធីបុណ្យម៉ាឡូតពីរដងក្នុងមួយឆ្នាំ ពិធីបុណ្យលើកទីមួយប្រារព្ធឡើងដើម្បីរម្លឹកដល់ការស្លាប់របស់អ៊ីម៉ាមសាន់ និងលើកទីពីរធ្វើឡើង ដើម្បីរម្លឹកទៅដល់កំណើតមូហាម៉ាត់ ។ ក្រុមអ៊ីម៉ាមសាន់ខុសពីក្រុមដាក់វ៉ះ និងក្រុមសាលាហ៊ី ប៉ុន្តែក្រុមអ៊ីម៉ាមសាន់តែងតែចាត់ទុកថាខ្លួនឯងមានភាពស្និទ្ធស្នាលជាមួយពុទ្ធសាសនិកខ្មែរជាងទៅវិញ ពីព្រោះពួកគេបានបញ្ចូលលក្ខណៈពិសេសវប្បធម៌សំខាន់របស់ជនជាតិខ្មែរមួយចំនួនដូច ជាការហូបអាហារ និងការស្លៀកពាក់ស្រដៀងគ្នាទៅនឹងខ្មែរ ។ ពួកគេកំណត់អត្តសញ្ញាណខ្លួនឯងជាមួយប្រទេសចម្ប៉ាច្រើនជាងជាមួយសាសនាអ៊ីស្លាម ហើយក្រុមនេះរឹងទទឹង មិនធ្វើការផ្លាស់ប្តូរ ទោះបីជា ជនជាតិចាមដទៃទៀតបង្ខំឲ្យពួកគេប្រតិបត្តិតាម មានដូចជាសំយ៉ាំងមួយថ្ងៃប្រាំដង ។ ក្រុមនេះអភិរក្ស ដំណែលវប្បធម៌ និងប្រវត្តិនៃប្រទេសចម្ប៉ា តាមរយៈការថែរក្សាអត្ថបទ ភាសា និងប្រវត្តិសាស្ត្រ ។ផ្ទុយទៅវិញជម្លោះនៅតែមានក្នុងក្រុមនិកាយចាមដ៏តូចមួយនេះ ។ នៅក្នុងខេត្តកំពង់ឆ្នាំង សមាជិកនៃក្រុមអ៊ីម៉ាមសាន់ បានព្យាយាមកសាងវិហារពីរក្នុងភូមិតែមួយ ។ ក្រុមនេះរងការគាបសង្កត់យ៉ាងខ្លាំងដើម្បីផ្លាស់ប្តូរ ដែលជាលទ្ធផលនៃដំណើរការជាសកល ។ ជំនួយអ៊ីស្លាមនៅទូទាំងពិភពលោក ដែលក្រុមអ៊ីម៉ាមសាន់ ទទួលបានតែងតែភ្ជាប់មកជាមួយលក្ខខណ្ឌ ហើយលក្ខខណ្ឌនោះ ពួកគេត្រូវប្តូរអត្តសញ្ញាណនិកាយរបស់ពួកគេ ។ ជាលទ្ធផល ភូមិមួយចំនួនបានប្តូរទៅសំយ៉ាំងប្រាំដងក្នុងមួយថ្ងៃ ។

## អត្តសញ្ញាណនយោបាយ

ដោយសារតែបរិបទនយោបាយរបស់ប្រទេសកម្ពុជាកំពុងតែផ្លាស់ប្តូរ អត្តសញ្ញាណនយោបាយចាមក៏កំពុងតែកែប្រែដែរ ។ ប៉ុន្តែប្រវត្តិសាស្ត្ររបស់ជនជាតិចាមក្នុងប្រទេសកម្ពុជាបានបង្ហាញថា ជាទូទៅជនជាតិចាមតែងតែគាំទ្រការស្នងរាជ្យដោយស្របច្បាប់ ឬក្រុមនយោបាយណា ដែលពួកគេយល់ថា អ្នកស្នងរាជ្យ និងក្រុមនយោបាយនោះអាចមានឱកាសទទួលបានជោគជ័យ ។ នៅពេលដែលគូភាគីនៃជម្លោះមានសមត្ថភាពប្រហាក់ប្រហែលគ្នា ជនជាតិចាមតែងតែជ្រើសរើសភាគីមួយក្នុងចំណោមភាគីទាំងពីរ ។ ការជ្រើសរើសភាគីម្ខាងក្នុងជម្លោះរបស់ជនជាតិចាមបានបង្ហាញយ៉ាងច្បាស់ពីអត្តសញ្ញាណនយោបាយរបស់ជនជាតិចាម ដោយជាក្រុមជនជាតិភាគតិចមួយនៅក្នុងប្រទេសកម្ពុជា ពួកគេមិនចង់ប្រឆាំងជាមួយជនជាតិខ្មែរ តែចង់បានការទុកចិត្តពីខ្មែរទៅវិញ ។ សូម្បីតែក្នុងសម័យ លន់ នល់ ជនជាតិចាមចង់រំដោះប្រទេសចម្ប៉ាចេញពីប្រទេសវៀតណាម ប៉ុន្តែ ពួកគេមិនដែលចង់បានស្វ័យភាពពីប្រទេសកម្ពុជានោះឡើយ ។ អត្តសញ្ញាណនយោបាយរបស់ជនជាតិចាមបង្ហាញថាពួកគេចង់ឲ្យគ្រប់គ្នាចាត់ទុកខ្លួនជាប្រជាជនកម្ពុជា ដែលមានអត្តសញ្ញាណជាតិពន្ធុ និងសាសនាដាច់ដោយឡែក ហើយមិនអាចផ្លាស់ប្តូរ ។

ដូចដែលបានបកស្រាយនៅក្នុងសៀវភៅនេះ ជនជាតិចាមបានចូលរួមក្នុងជម្លោះរាជវង្សពីឆ្នាំ១៥៩៧ ដល់ឆ្នាំ១៥៩៩ និងឆ្នាំ១៧៨២ ក៏ដូចជាជម្លោះក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៨៦០ដែរ ។ ការអន្តរាគមន៍របស់ជនជាតិចាមទាំងអស់នេះធ្វើឡើងក្នុងនាមជាជំនួយទៅដល់ស្តេចខ្មែរដ៏មានអំណាច ។ នៅដើមសតវត្សរ៍ទី២០ជនជាតិចាមនៅតែរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយរាជវង្សខ្មែរ ។

ក្នុងសម័យ លន់ នល់ នៅពេលមានការប្រយុទ្ធប្រឆាំងយ៉ាងខ្លាំងក្លារវាងលទ្ធិកុម្មុយនីស្ត និងមូលធននិយមជនជាតិចាមជ្រើសរើសទាំងសងខាង ។ ទោះបីជាលទ្ធិកុម្មុយនីស្តប្រឆាំងនឹងការគោរពប្រតិបត្តិសាសនាជនជាតិចាមមួយចំនួននៅតែគាំទ្រលទ្ធិកុម្មុយ

នីស្ត ដែលជាភាគីម្ខាងនៃជម្លោះ ពីព្រោះ សម្តេច សីហនុ ទ្រង់នៅខាងលទ្ធិកុម្មុយនីស្ត ។ ជាលទ្ធផល អត្តសញ្ញាណនយោបាយរបស់ជនជាតិចាមក្នុងគ្រានោះ នៅតែគាំទ្រគ្រួសាររាជវង្សជាជាងលទ្ធិកុម្មុយនីស្តដែលប្រឆាំងនឹងអត្តសញ្ញាណស្នូលជាមូស្លីមរបស់ពួកគេ ។ ជនជាតិចាមដែលចូលខាងសាធារណរដ្ឋខ្មែរ មិនគាំទ្រលទ្ធិកុម្មុយនីស្ត ពីព្រោះពួកគេជឿថាខ្មែរក្រហមនឹងប្រព្រឹត្តអំពើឃោរឃៅមកលើពួកគេ ដោយសារគោលនយោបាយហាមឃាត់មិនឲ្យគោរពសាសនាអ៊ីស្លាមរបស់លទ្ធិកុម្មុយនីស្ត ។

ក្នុងរបបខ្មែរក្រហម ចាមបានក្លាយទៅជាអ្នកទោសនយោបាយ ។ ពួកគេមិនអាចកសាងអត្តសញ្ញាណនយោបាយក្នុងរបៀបមួយ ដែលពួកគេអាចធ្វើទៅបានដូចរបបមុនៗនោះទេ ។ ដូចជាជនជាតិខ្មែរ និងក្រុមជាតិពន្ធុដទៃទៀត ពួកគេពុំមានជម្រើសឡើយ ។ ជាលើកទីមួយនៃប្រវត្តិសាស្ត្រចាមក្នុងប្រទេសកម្ពុជា អត្តសញ្ញាណស្នូលជាជនជាតិចាម និងមូស្លីមរបស់ពួកគេ ត្រូវបានគំរាមកំហែង និងហាមឃាត់ដោយអ្នកដឹកនាំខ្មែរ ។ ពួកគេមិនមែនជាមូស្លីម ឬចាមតែជាកម្មករនៃវិស័យកសិកម្មរបស់ខ្មែរក្រហម ដូចជាជនជាតិខ្មែរដែរ ។ បទពិសោធន៍ពីសម័យខ្មែរក្រហមមានឥទ្ធិពលទៅលើការពង្រឹង និងបង្កើតអត្តសញ្ញាណនយោបាយចាមជាមួយជនជាតិខ្មែរនៅរបបក្រោយៗមកទៀត ។

ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ ជនជាតិចាមមានជម្រើសពីរម្តងទៀតសម្រាប់ការជ្រើសរើសអត្តសញ្ញាណនយោបាយ ។ ចាមមួយចំនួននៅតែរស់នៅក្នុងប្រទេសកម្ពុជាក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងគាំទ្រមនោគមវិជ្ជានយោបាយរបស់របបនេះ គ្រាដែលចាមមួយចំនួនទៀតបានរត់គេចខ្លួនទៅរស់នៅក្នុងជំរំជនភៀសខ្លួននៅតាមបណ្តោយព្រំដែនថៃ និងគាំទ្រសង្គ្រាមទ័ពព្រៃប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ជនជាតិចាមទាំងនេះ បានក្លាយទៅជាអ្នកបះបោរ និងសមាជិកនៃបក្សនយោបាយ ដែលបង្កើតឡើងនៅជំរំ ។ ក្រោយការគ្រប់គ្រងរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា អត្តសញ្ញាណនិកាយរបស់ជនជាតិចាមពុំបានបង្កើតឡើងវិញនោះទេ ។ ដោយសារតែសង្គ្រាម អត្តសញ្ញាណនយោបាយចាមមានអាទិភាពជាងអត្តសញ្ញាណនិកាយ តែអត្តសញ្ញាណស្នូលទាំងពីររបស់ជនជាតិចាមបានចាប់ផ្តើមអនុវត្តសាជាថ្មី ហើយពួកគេអាចកសាងឡើងវិញនូវអ្វីដែលសេសសល់ពីអត្តសញ្ញាណទាំងពីរ បន្ទាប់ពីឆ្លងកាត់អំពើប្រល័យពូជសាសន៍ក្នុងសម័យខ្មែរក្រហម ។

ក្រោយការបញ្ចប់នៃសង្គ្រាមត្រជាក់ អត្តសញ្ញាណនិកាយត្រូវបានពិនិត្យឡើងវិញ ហើយអត្តសញ្ញាណនយោបាយក៏ត្រូវបានចរចា និងប្រឈមមុខជាមួយនឹងបញ្ហាសាជាថ្មី ។ យោងទៅតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩១ បក្សនយោបាយដែលបង្កើតឡើងនៅជំរំតាមបណ្តោយព្រំដែនបានទទួលការអនុញ្ញាតឲ្យចូលរួមក្នុងការបោះឆ្នោតប្រជាធិបតេយ្យជាលើកដំបូងក្នុងប្រទេសកម្ពុជានាឆ្នាំ១៩៩៣ ។ ការធ្វើមាតុភូមិនិវត្តរបស់ជនជាតិចាមបណ្តាលឲ្យមានការបង្កើតនូវវេទិកានយោបាយថ្មី ដើម្បីប្រកួតប្រជែងជាមួយក្រុមនយោបាយចាមមួយទៀត ដែលមានវត្តមានចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០ ។ ម៉ាត់ លី ជាអ្នកដឹកនាំក្រុមនយោបាយនេះ ។ ជនជាតិចាមមកពីជំរំគាំទ្រគណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច និងគណបក្សប្រឆាំង សម រង្ស៊ី ។ សមាជិកចាមនៃគណបក្សទាំងពីរប្រឆាំងនឹងចាមដទៃទៀត ដែលជាសមាជិកនៃគណបក្សប្រជាជនកម្ពុជា ។ អ្នកគាំទ្រនៅតាមជនបទសម្រាប់អត្តសញ្ញាណនយោបាយរបស់គណបក្សប្រជាជនមានទំហំធំជាងទីស្នាក់ការគណបក្សទាំងពីរ ។ ពីព្រោះតែការបរាជ័យរបស់គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច និងគណបក្ស សម រង្ស៊ី ក្នុងការបោះឆ្នោតប្រជាធិបតេយ្យក្នុងអាណត្តិទីពីរ និងបី (១៩៩៨ និង ២០០៣) អត្តសញ្ញាណនយោបាយរបស់ជនជាតិចាមរួមបញ្ចូលគ្នាបន្តិចម្តងៗ រហូតដល់មានតែមួយគត់គឺ គណបក្សប្រជាជនកម្ពុជា ។

លើសពីនេះទៀត អ្នកនយោបាយចាមបានព្យាយាមយកជំនួយពីក្រុមនិកាយផ្សេងៗ ដើម្បីផ្គត់ផ្គង់សកម្មភាពសាសនារបស់ពួកគេ ។ ឧទាហរណ៍ អ៊ីដធីម៉ាស ជាពិធីជួបជុំប្រចាំឆ្នាំរបស់ក្រុមដាក់វ៉ះ ដែលចូលរួមជារៀងរាល់ឆ្នាំដោយអ្នកនយោបាយចាមជាច្រើន អ្នកនយោបាយទាំងនោះពីដើមឡើយ ជំទាស់ការបង្រៀនរបស់ក្រុមដាក់វ៉ះ ពីព្រោះមូលដ្ឋាននៅតាមជនបទរបស់ក្រុមដាក់វ៉ះបានពង្រីកយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។

***(តទៅលេខក្រោយ)***

**អេង កុកថាយ**

# អាជីពកំបាំងរបស់ ប៉ុល ពត

**(តចប់)**

**៨) អតីតបងប្រុសរបស់ ប៉ុល ពត**

ឡុង ស្លួង និងប្រពន្ធគាត់បានរស់នៅជាន់ទី២ នៃអគារមួយ ដែលគេទុកសម្រាប់ឲ្យអ្នកធ្វើការខាងវិស័យវប្បធម៌ស្នាក់នៅ ស្ថិតនៅក្រោយសាលមហោស្រពទន្លេបាសាក់ ។ កៀនកោះដ៏ស្ងាត់ជ្រងំនេះនៃទីក្រុងមួយដែលគ្របដណ្តប់ទៅដោយរុក្ខជាតិតាមបណ្តោយមាត់ទន្លេមិនឆ្ងាយប៉ុន្មានពីព្រះបរមរាជវាំងដែលមានកំពូលស្រួចៗពណ៌មាសភ្លឺផ្លេកនោះឡើយ ។ គឺនៅទីនោះហើយ ដែលស្វាមីភរិយា ឡុត ស្លួង ធ្លាប់បម្រើជារាជបរិពាររបស់ស្តេច មុនីវង្ស បន្ទាប់មករបស់សម្តេច សីហនុ ទៀត គាត់ធ្វើការខាងផ្នែកពិធីការ ចំណែកប្រពន្ធគាត់ឈ្មោះ ជា សាមី ជានាងការិនីដ៏ល្បីល្បាញនៅក្នុងក្រុមរបាំព្រះរាជទ្រព្យ ។

ក្រោយពីរបប ប៉ុល ពត បានរលំរលាយទៅ ឡុត ស្លួង បានចាប់ផ្តើមធ្វើការជាប្រធានឃ្លាំងសម្ភាររបាំបុរាណនៅក្នុងនាយកដ្ឋានសិល្បៈក្រុងភ្នំពេញ ។ រីឯប្រពន្ធគាត់ជាអ្នកបង្រៀនរបាំខ្មែរបុរាណនៅទីនោះដែរ ។

ឡុត ស្លួង មានអាយុ៧០ឆ្នាំ (បច្ចុប្បន្នអាយុ៨៤ហើយ) គាត់ហាក់ដូចជាមានសុខភាពបរិបូរនៅឡើយ ។ ក្រឡេកមើលមួយភ្លែតដំបូង គាត់មានរូបរាងដូចគ្នាពន់ពេកទៅនឹងមេពជ្ឈឃាដរបស់ពួកខ្មែរក្រហម ប៉ុល ពត ដែលគេអាចមើលឃើញនៅលើទំព័រ



សៀវភៅបោះពុម្ពផ្សាយផ្សេងៗនាជំនាន់ "កម្ពុជាប្រជាធិបតេយ្យ" ។ គាត់បានដំណាលប្រាប់យើងថា ៖ ទាល់តែដល់ចុងឆ្នាំ ១៩៧៨ នៅលើរូបថតដែលចុះក្នុងសៀវភៅស្តើងមួយ ទើបខ្ញុំបានស្គាល់ ប៉ុល ពត ជាប្អូនប្រុសរបស់ខ្ញុំ គឺ សាឡុត ស ។ បន្ទាប់ពីត្រូវបានបណ្តេញចេញពីភ្នំពេញ ខ្ញុំ និងប្រពន្ធបានទៅរស់នៅទីចុងកាត់មាត់ញកមួយឆ្ងាយដាច់សង្វែងក្នុងខេត្តកំពង់ធំ ។ ខ្ញុំគិតថា វាបានប្រកាន់យកនាមក្លែងនេះនៅពាក់កណ្តាលទសវត្សឆ្នាំ១៩៥០ ក្រោយពីវាត្រឡប់មកពីប្រទេសបារាំងវិញ ជាទីដែលវាបានចូលរៀននៅវិទ្យាល័យឯកជនមួយនាទីក្រុង ប៉ារីស និងបានរួមចំណែកក្នុងការតស៊ូនយោបាយដោយលួចលាក់ទៀតផង ។

ឈ្មោះពិតរបស់ ប៉ុល ពត គឺ សាឡុត ស បានចាប់លេចចេញជាញឹកញាប់នៅលើទំព័រសារព័ត៌មានបារាំង តាំងពីមុនមានការកាត់ទោសដែលតុលាការប្រជាជនបដិវត្តន៍បានប្រកាសនៅភ្នំពេញនាខែសីហា ១៩៧៩ ម្ល៉េះ ។ ឡុត សួង បានទទួលស្គាល់ដោយឥតភ័យបារម្ភនូវក្រសែលោហិតរបស់ខ្លួន ដែលជាជនកាន់អំណាចផ្តាច់ការយ៉ាងឃោរឃៅយង់ឃ្នងជាទីបំផុត នៅក្នុងប្រវត្តិសាស្ត្រប្រទេសខ្មែរ ។ តាមពិត គួរឲ្យឆ្ងល់ដែរ ជនជាតិខ្មែរគ្មាននាមត្រកូលទេ ជាញឹកញយបំផុត ដើម្បីបញ្ជាក់ក្រសែរបស់ជនណាម្នាក់ គេដាក់ឈ្មោះឪពុកនៅពីមុខឈ្មោះនោះ ។ សាឡុត ស មានន័យថា ស ជាកូនរបស់ សាឡុត ។

សួង បានបកស្រាយពីការខុសនាមត្រកូលថា យើងកើតពីឪពុកតែមួយឈ្មោះ ភេម ឡុត នៅភូមិព្រែស្បូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ មេភូមិគ្រាន់តែបានធ្វើកំហុសមួយនៅក្នុងសៀវភៅចុះសំបុត្រកំណើត ។ ក្នុងចំណោមកូន៨នាក់, ៦នាក់ដំបូងបានទទួលឈ្មោះឪពុក រីឯ២នាក់ចុងក្រោយ គឺ សាឡុត ទៅវិញ ។ គាត់បាននិយាយថែមទៀតថា ដូចជាឈ្មោះកូនប្រុសខ្ញុំ ប៉ាន់ ថុល ដែលថាគ្មាន ឈ្មោះឪពុកនៅពីមុខឈ្មោះវានោះ គឺគ្មានអ្វីជាចម្លែកទេ ជាទូទៅ ឈ្មោះឪពុកវាមិនជាចាំបាច់ឡើយ ។

អ្នកនិពន្ធអត្ថបទនេះ បានចោទសួរ សួង ថា៖

ខ្ញុំស្មានថា គ្រួសារអ្នកប្រហែលជាគ្រួសារដែលមានឥទ្ធិពល ដោយហេតុថា នាមត្រកូលអ្នកមាននៅក្នុងព្រះរាជពិធីការ ដែលបានហុចលទ្ធភាពឲ្យ សាឡុត ស អាចបន្តការសិក្សានៅប្រទេសបារាំង ។ គេថែមទាំងនិយាយទៀតថា បងស្រីអ្នកបានរៀបការជាមួយស្តេចទៀតផង ។

ឡុត សួង បានរៀបរាប់ថា គ្រួសារយើងស្ថិតនៅក្នុងចំណោមគ្រួសារកសិករមធ្យម ។ យើងបានធ្វើពលកម្មនៅលើស្រែ យើងមិនដែលស្គាល់ការអត់ឃ្លាន និងជំពាក់បំណុលគេទេ ។ បងស្រីជីទូតមួយខ្ញុំ ឈ្មោះ ឡុត សារួន បានធ្វើជាស្នំឯករបស់ស្តេចមុនីវង្សរហូតដល់ព្រះអង្គសោយទិវង្គត ។ ក្រោយមក គាត់បានវិលមកកាន់ភូមិកំណើតវិញ ហើយបានរៀបការជាមួយកសិករសាមញ្ញម្នាក់ ។ ក៏ប៉ុន្តែខ្ញុំ និងសាច់ញាតិខ្ញុំ បានចម្រុងចម្រើនមិនមែនដោយសាររូបគាត់ទេ តែដោយសារបងស្រីជីដូនមួយចិត្តល្អរបស់យើងឈ្មោះ យុន មាយ ជាតារានៃក្រុមរបាំព្រះរាជទ្រព្យទៅវិញ ។ គាត់ក៏បានធ្វើជាស្នំឯករបស់ស្តេចមុនីវង្សដែរ និងមានឥទ្ធិពលខ្លះៗទៅលើបរិពាររបស់ទ្រង់ផង ។ គឺគាត់ហ្នឹងហើយដែលហៅរកខ្ញុំឲ្យចូលធ្វើការនៅក្នុងរាជវាំង ។ គឺគាត់នេះដដែល ដែលបានទទួលភារៈយកចិត្តទុកដាក់ក្នុងការអប់រំកុមារ ស ដែលទើបតែមានអាយុ៦ឆ្នាំ រហូតដល់ពេលដែលខ្ញុំអាចធ្វើការនេះ ដោយខ្លួនឯងបាន ។ ទោះជាយ៉ាងណាក្តី យើងគ្មានប្រាក់កាសដើម្បីបញ្ជូន ស ឲ្យទៅរៀនសូត្រនៅប្រទេសបារាំងទេ ។ អាស្រ័យដោយសារការជួយទំនុកបម្រុងរបស់គាត់នេះហើយ ទើបគេផ្តល់អាហារូបករណ៍ឲ្យវាបានទៅរៀននៅប្រទេសបារាំងនោះ ។

សួង បាននិយាយពីការរស់នៅរបស់គាត់ក្រោមរបប ប៉ុល ពត ថា៖ ២ដង ខ្ញុំរិះតែបាត់បង់ជីវិត ដោយការអត់ឃ្លាន និងការនឿយហត់ ។ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានរំដោះខ្ញុំឲ្យផុតពីសេចក្តីស្លាប់ដែលច្បាស់ជាជៀសមិនរួច ។ គេបានធ្វើឲ្យខ្ញុំមានសេចក្តីសង្ឃឹមឡើងវិញ ពីព្រោះរស់ ឬស្លាប់សម្រាប់ខ្ញុំ គឺដូចតែគ្នាទេ ។ ពួកយើងរហូតដល់ទៅជ្រើសរើសសេចក្តីស្លាប់ជាងការរស់នៅក្នុងឋាន នរកលោកិយ៍នេះផង ។

ហេតុអ្វីបានជាអ្នកមិនសាកល្បងអំពាវនាវឲ្យ ប៉ុល ពត ជួយបន្ទាប់ពីបានធ្លាក់ខ្លួនក្នុងគ្រាមានអាសន្ននេះ? ព្រោះបើទោះបីជាយ៉ាងណាក៏ដោយ ក៏អ្នកជាបងប្អូនបង្កើតនឹងគ្នាដែរ?

សូមអ្នកសញ្ជឹងគិតខ្លួនឯងមើល បើសិនជាវាយកចិត្តទុកដាក់ចំពោះជោគវាសនារបស់សាច់ញាតិវា នោះពិតជាវាបញ្ជូនគ្នាវាឲ្យ

មកស្វែងរកសាច់ញាតិទៅហើយ ។ សាឡុត ស៊ីហៃ ជាប្អូនប្រុសរបស់វា ស្លាប់ដោយការអត់ឃ្លាន ក្រោយបន្តិចបន្ទាប់ពីការបណ្តេញចេញពីភ្នំពេញ ។

ទោះជាយ៉ាងណា ឡុត សួង បានចាប់នឹកឃើញដល់រឿងនេះ បន្ទាប់ពីគាត់បានឆ្លងកាត់រាល់អ្វីៗរួចហើយ ។ គាត់បានបន្ថែមទៀតថា៖

ដូចដែលខ្ញុំបាននិយាយប្រាប់អ្នករួចមកហើយ មិនយូរប៉ុន្មានមុនការរំដោះ ទើបចៃដន្យបាននាំឲ្យខ្ញុំដឹងការពិតក៏ដូចតអំពីប្អូនប្រុសរបស់ខ្ញុំឈ្មោះ សាឡុត ស ។ តើនរណាប្រហែលជាអាចនឹងគិតឃើញ? វាស្លូតបូតទេ កាលនៅពីក្មេង ។ សូម្បីតែបន្ទាប់ពីបានរងគ្រោះដោយអំពើឃោរឃៅព្រៃផ្សៃហួសហេតុរបស់ ប៉ុល ពត ក៏ដោយ ក៏រាល់ដងខ្ញុំមានសេចក្តីខ្មាសអៀនណាស់នៅក្នុងសម្បជញ្ញៈ ដោយនឹកគិតទៅដល់ចំណងខ្សែលោហិត ដែលចងភ្ជាប់យើងទាំងពីរ ។ ប៉ុន្តែ ជាញឹកញាយបំផុត ខ្ញុំមិនដែលគិតពីរឿងនេះសោះឡើយ ។ ខ្ញុំរស់នៅក្នុងសង្គមថ្មីរបស់យើងដូចជាជនទាំងអស់គ្នាដែរ ។ ខ្ញុំមិនអាចត្អូញត្អែរ ចំពោះករណីណាមួយនៃការរើសអើងពីសំណាក់អ្នកកាន់រដ្ឋអំណាចពីសម្តីរអេចរអូចរបស់អ្នកធ្វើការជាមួយគ្នា ឬពីអ្នកជិតខាងខ្ញុំឡើយ ។ គ្មាននរណាម្នាក់សម្លឹងមើលមកយើងដោយការថ្កោលទោសទេ ទោះ ជាសម្លឹងមើលមកខ្ញុំក្តី មកប្រពន្ធខ្ញុំក្តី ។

ក្រោយពីការសម្រាកដ៏យូរមក អ្នកនិពន្ធម្នាក់បានចោទសំណួរមួយជាចុងក្រោយថា៖ ប្រហែលជាអ្នកចង់និយាយអ្វីមួយទៅកាន់ប្អូនប្រុសរបស់អ្នកជាដំបូន្មានខ្លះៗដែរ ហើយ មើលទៅ?

សាឡុត ស ប្អូនប្រុសខ្ញុំ ដែលខ្ញុំស្រឡាញ់បំផុត និងដែលបានស្រឡាញ់ខ្ញុំវិញដែរនោះ សម្រាប់ខ្ញុំ គឺគ្មានពាក្យអ្វីនិយាយតទៅទៀតទេ ។ ដំបូន្មានសម្រាប់វា គ្មានបានការអ្វីឡើយ ។ ប៉ុន្តែ ប្រសិនបើអ្នកចង់ឲ្យខ្ញុំនិយាយស្តីប៉ុន្មានម៉ាត់ទៅរកវា មិនជាអ្វីទេ៖ «ឯងល្បីឈ្មោះតែដោយសារបទឧក្រិដ្ឋរបស់ឯង ប៉ុណ្ណោះ ល្មមឈប់ហើយ» ។

### ៩) សាឡុត ស ស្លាប់ ប៉ុល ពត នៅរស់

ទីភ្នាក់ងារព័ត៌មានបារាំង អា-អេហ្វ-ប៉េ បានរាយការណ៍នៅថ្ងៃទី៦ មិថុនា ១៩៩៦ ថា ប៉ុល ពត ដែលមានអាយុ៦៨ឆ្នាំ បានរងនូវជំងឺគ្រុនចាញ់ដ៏ធ្ងន់ ហើយគ្មានសង្ឃឹមថាអាចរស់បានឡើយ ។ បើតាមរបាយការណ៍ផ្សេងៗ ដែលបានទៅដល់ដៃមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលមួយចំនួនបានបញ្ជាក់ថា ប៉ុល ពត បានស្លាប់ដោយសារជំងឺនៅក្នុងជំរុំក្នុងព្រៃមួយនៃប្រទេសកម្ពុជាកាលពីថ្ងៃ៣ មិថុនា ១៩៩៦ នេះ ។ មន្ត្រីជាន់ខ្ពស់ទាំងនោះបានអះអាងថា ព័ត៌មានខាងលើនេះ បានមកពីចារបុរសក្នុងជួរខ្មែរក្រហម និងបានមកពីប្រជាជនដែលកំពុងរស់នៅក្រោមការគ្រប់គ្រងរបស់របបនេះ ។ ទោះបីជាយ៉ាងដូច្នេះក្តី ព័ត៌មាននេះ ពុំទទួលបាននូវការអះអាងពីប្រភពឯករាជ្យណាផ្សេងទៀតឡើយ ។ អ្នកផងគិតថា ប្រសិន បើប៉ុល ពត ស្លាប់មែន គេអាចទទួលព័ត៌មានច្បាស់ពីប៉េកាំង ព្រោះ ប៉ុល ពត ឧស្សាហ៍ទៅទីនោះដើម្បីព្យាបាលរោគ ។

ក្នុងឱកាសដែលព័ត៌មាននេះ ពុំទាន់បានអះអាងជាក់លាក់នៅឡើយនោះ ពួកអ្នកវិភាគខ្លះនិយាយថា ព័ត៌មាននេះទំនងជាទាក់ទិនទៅនឹងឧបាយកលនយោបាយមួយរបស់ពួកខ្មែរក្រហម ក្នុងនោះប្រការដែលគេចាប់អារម្មណ៍ គឺ «និន្នាការចង់ចរចាជាមួយពួកខ្មែរក្រហម» ដែលកំពុងលេចឡើង ។ ការស្លាប់នេះអាចជាហេតុផលមួយឲ្យគេនិយាយថា «ប៉ុល ពត ស្លាប់ទៅ ហើយគ្មានអ្វីគួរឲ្យខ្លាចទៀតទេ» ។

ប៉ុន្តែ ចាងហ្វាងកាសែតជាយដែនមួយរបស់ថៃ នៅស្រុកអារញ្ញ ខេត្តស្រះកែវ បានអះអាងបញ្ជាក់ប្រាប់មន្ត្រីយោធាជាន់ខ្ពស់កម្ពុជានៅថ្ងៃ៨ មិថុនា ១៩៩៦ ថា «ប៉ុល ពត មិនទាន់ស្លាប់ទេ ហើយគេជឿថា មេដឹកនាំខ្មែរក្រហមរូបនេះ កំពុងស្ថិតនៅតំបន់ទល់ដែនខេត្តស៊ីសាកេតនៅទល់មុខនឹងខេត្តព្រះវិហាររបស់ប្រទេសកម្ពុជា ។

កាសែតដឺណេសិនរបស់ថៃ ច្បាប់ចេញផ្សាយថ្ងៃ៨-៦-១៩៩៦ ដែលចុះផ្សាយព័ត៌មានរបស់ទីភ្នាក់ងាររ៉យទ័រសម្ភាសជាមួយកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម ក៏បានបញ្ជាក់ថា «ប៉ុល ពត នៅរស់» ដែរ ។ ជាធម្មតា គេដឹងថា ប៉ុល ពត មានផ្ទះស្ថិតនៅលើកូនភ្នំមួយ ស្ថិតក្នុងភូមិសាផានហ៊ិន ក្នុងខេត្តស្រះកែវ ។ គេគ្មានព័ត៌មានអ្វីដែលកើតឡើងនៅស៊ីសាកេត ទាក់ទិននឹងសកម្មភាពរបស់ ប៉ុល ពត ឡើយ ។

មិត្ត ឈាង ត្រូវបានគេស្គាល់ថា ជាអនុសេនាធិការកងទ័ពខ្មែរក្រហមបាននិយាយប្រាប់អ្នកកាសែតនៅទល់ដែនកម្ពុជា-ថៃ ថា៖ «សេចក្តីរាយការណ៍អំពីមរណភាពរបស់ ប៉ុល ពត គឺមិនពិតទេ

ហើយ យើងក៏គ្មានយោបល់អ្វីចំពោះការពង្រីកពាក្យចចាមអារ៉ាម នេះដែរ» ។ ប្រការដែលគេអាចសង្ស័យអំពីសម្តីរបស់មិត្ត ឈាង គឺស្ថិតនៅត្រង់ថា ការនិយាយថា ប៉ុល ពត ស្លាប់ គឺដើម្បីកុំឲ្យកូនទាហានខ្មែរក្រហមបាក់ទឹកចិត្ត និងជ្រួលច្របល់តែប៉ុណ្ណោះ ។

ទោះជាយ៉ាងណាក្តី មន្ត្រីចារកម្មថៃមួយរូបបានបញ្ជាក់បន្ថែមឲ្យកាសែតដឺណេសិន ថា«រហូត មកទល់នឹងពេលនេះ ខ្ញុំអាចត្រឹមតែនិយាយថា ប៉ុល ពត នៅរស់នៅឡើយទេ» ។ ប្រភពព័ត៌មានថៃ បានវិភាគថា «ពាក្យចចាមអារ៉ាមនេះ ត្រូវបានគេផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដោយភាគីមួយនៅក្នុងរដ្ឋាភិបាលកម្ពុជា សំដៅលើកទឹកចិត្តប្រជាជនថា ខ្មែរក្រហមប្រហែលជានឹងស្លាប់ ។

ផ្ទុយពីការវិភាគខាងលើនេះ របស់មន្ត្រីចារកម្មថៃ ពួកអ្នកវិភាគនៅភ្នំពេញគិតថា ប្រភពចចាមអារ៉ាមនេះ គឺចេញពីមជ្ឈដ្ឋានអ្នកដែលគាំទ្រនយោបាយចរចាជាមួយខ្មែរក្រហម ។ គេនិយាយថា ប៉ុល ពត ស្លាប់ គឺដើម្បីបន្ថយជំនឿថា ខ្មែរក្រហម គឺជាគ្រោះថ្នាក់ក្នុងគោលបំណងជំរុញការទាមទារចរចាជាមួយខ្មែរក្រហម និងផ្តល់កៅអីខ្លះៗនៅក្នុងរដ្ឋាភិបាលទៅឲ្យខ្មែរក្រហមថែមទៀត ។

អ្នកវិភាគ និងអ្នកឯកទេសខាងបញ្ហាខ្មែរក្រហមជាច្រើនបានព្រមព្រៀងគ្នាថា ប៉ុល ពត ស្លាប់ ពុំមែនបានន័យថា អស់ខ្មែរក្រហមនោះទេ ទោះបីជាកម្រិតណាមួយនោះ ការស្លាប់មេដឹកនាំក៏សាហាវនេះ អាចជះឥទ្ធិពលដល់ពួកខ្មែរក្រហមតូចតាចក៏ដោយចុះ ព្រោះនៅក្បែរនោះ មិនខ្វះទេមេក្បាលរឹង ដែលនៅមានជីវិតដូចប្រសាសន៍របស់សម្តេច ហ៊ុន សែន ដែលថ្លែងកាលពីថ្ងៃទី១០ មិថុនា ថា «ប្រហែលនៅពេលខាងមុខនេះ គេអាចនឹងលើកយកនូវសំណើឲ្យមានការចរចារវាងរដ្ឋាភិបាលកម្ពុជា ស្របច្បាប់ជាមួយពួកខុទ្ទាមខ្មែរក្រហម ព្រោះគេអាងហេតុផលថា ប៉ុល ពត ងាប់បាត់ហើយ ។ បើងាប់ ប៉ុល ពត មួយ ក៏វាមិនទាន់អស់ ប៉ុល ពត ដែរ ។ ហេតុអ្វី? ព្រោះអង្គការចាត់តាំងនយោបាយ និងយោធារបស់ ប៉ុល ពត គឺនិយាយដល់របប ប៉ុល ពត ទាំងមូល វាមិនរលំរលាយទេដូច្នេះទោះបីជាងាប់ទាំង ប៉ុល ពត, ខៀវ សំផន, អៀង សារី ក៏អង្គការចាត់តាំងនយោបាយរបស់ ប៉ុល ពត មិនទាន់អស់ដែរ ។ ហេតុនេះហើយ យើងកុំស្រស្រមើស្រមៃអំពីឥទ្ធិពលនៃការវិលត្រឡប់របស់ ប៉ុល ពត មកវិញឲ្យសោះ ពីព្រោះថា ទាំង ប៉ុល ពត ក្នុង និង ប៉ុល ពត ក្រៅកំពុងតែសហការគ្នា ។ នេះជាល្បែងនយោបាយដែលនឹងត្រូវលេចចេញជាបញ្ហាអ្វីមួយនាពេលខាងមុខមិនខាន ។

ការពិភាក្សាគ្នាអំពីការស្លាប់របស់ ប៉ុល ពត ដែលធ្វើឡើងដោយខ្មែរក្រហមគ្រប់មជ្ឈដ្ឋាននេះ បានលេចចេញនូវទស្សនៈ ៣ ៖

ទស្សនៈទី១ គឺប្រសិនបើ ប៉ុល ពត ស្លាប់មែន គេមានជំនឿថា ពួកទ័ពព្រៃនៃខុទ្ទាមខ្មែរក្រហមនឹងរលំរលាយសាបសូន្យ ដោយក្រុមនេះ បាត់មេកើយ បាត់មនោគមន៍វិជ្ជា បាត់ឧត្តមគតិ ហើយនឹងក្លាយទៅជាក្រុមចោរតូចៗ ដែលយូរៗទៅនឹងរលាយខ្លួនដោយខ្លួនឯង ព្រោះគ្មានការផ្គត់ផ្គង់ទាំងសម្ភារ ទាំងស្បៀងអាហារ ។ ម៉្យាងទៀត ភាពមានះរឹងរូសរបស់ក្រុមខុទ្ទាមចោរព្រៃខ្មែរក្រហមដែលមិនព្រមចូលរួមក្នុងការបង្រួបបង្រួមជាតិ ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ និងការមិនព្រមបន្ទន់ឥរិយាបថក្នុងការចរចាជាបន្តបន្ទាប់ជាមួយរដ្ឋាភិបាលក្រោយការបោះឆ្នោតនោះ គឺជាគំនិតរបស់ ប៉ុល ពត ។ ដូចនេះ បើសិនជា ប៉ុល ពត ស្លាប់មែន ទោះជាពួកខុទ្ទាមមិនរលំរលាយ ក៏ប្រហែលជាពួកនេះ អាចមានការផ្លាស់ប្តូរឥរិយាបថខ្លះជាពុំខាន ។

ទស្សនៈទី២ គឺថាខ្មែរក្រហម នៅតែជាខ្មែរក្រហមមិនមានអ្វីផ្លាស់ប្តូរទេ ។ ទស្សនៈនេះ បានលើកយកការដឹកនាំជាសមូហភាពរបស់ចលនាកុម្មុយនីស្តមកបញ្ជាក់ថា តួនាទីដឹកនាំមិនមែនមានតែ ប៉ុល ពត ម្នាក់ឯងទេ នៅមានមនុស្សជាច្រើនទៀត ដែលមានចិត្តគំនិត និងសកម្មភាពដូច ប៉ុល ពត ដូចជា នួន ជា, តាម៉ុក, សុន សេន, ខៀវ សំផន, អៀង សារី ដែលទោះជាអត់ពី ប៉ុល ពត ទៅ ក៏អ្នកទាំងនោះអាចដឹកនាំចលនាខុទ្ទាមបានដែរ ។ ហេតុផលមួយក្នុងទស្សនៈទី២នេះ យល់ឃើញថាចលនាខុទ្ទាមខ្មែរក្រហម នៅតែមានអត្ថិភាព បើទោះបីជា ប៉ុល ពត ស្លាប់មែនក៏ដោយចុះ គឺនៅត្រង់ថា មាននិន្នាការគាំទ្រ និងប្រើប្រាស់ខ្មែរក្រហមជាសន្លឹកបៀសម្រាប់លេងជាមួយរាជរដ្ឋាភិបាលស្របច្បាប់ ដែលយ៉ាងហោចណាស់ គេក៏អាចលេងសន្លឹកបៀរនេះរហូតដល់ឆ្នាំ១៩៩៨ដែរ ដែលជាកាលបរិច្ឆេទនៃការបោះឆ្នោតសម្រាប់អាណត្តិទី២ ឬអាចលេងសន្លឹកបៀនេះយូរជាងនេះទៀត ក្នុងករណីដែល«ពួកគេ» មិនបានទទួលលទ្ធផលល្អក្នុងការបោះឆ្នោតនាឆ្នាំ១៩៩៨នោះ ។

ទស្សនៈទី៣ គឺបើសិនជាខ្មែរក្រហមប្រើប្រាស់ការស្លាប់

របស់ ប៉ុល ពត សម្រាប់ "ល្បិចកល" អ្វីមួយនោះ មានន័យថា ជីវិតនយោបាយផ្ទាល់របស់ ប៉ុល ពត ក៏ត្រូវចប់ត្រឹមប៉ុណ្ណឹងដែរ ។ ម៉្យាងទៀត ការឃោសនាដូច្នេះ វាអាចធ្វើឲ្យឈ្មោះរបស់ ប៉ុល ពត នៅតែមានឥទ្ធិពលគ្របដណ្តប់លើសតិអារម្មណ៍ស្រពេចស្រពិល របស់ប្រជាជនថា តើ ប៉ុល ពត ស្លាប់មែន ឬក៏អត់ ។

ខ្មែរគ្រប់រូបដែលនឿយណាយនឹងសង្គ្រាមហើយចង់បាន សន្តិភាព និងត្រេកអររីករាយ ប្រសិនបើខ្មែរក្រហមរលំរលាយ ទៅទាំងរចនាសម្ព័ន្ធនយោបាយ និងយោធា ក៏ប៉ុន្តែ ប្រជាពលរដ្ឋ ខ្មែរនឹងមិនសង្ឃឹមច្រើនណាស់ណាទេ បើគ្រាន់តែ ប៉ុល ពត ស្លាប់ ហើយរចនាសម្ព័ន្ធនយោបាយ និងយោធា ខ្មែរក្រហមនៅតែមាន អត្ថិភាព ដោយមេដឹកនាំខ្មែរក្រហមឯទៀតៗ នៅតែបន្តអនុវត្តយុទ្ធសាស្ត្រ និង យុទ្ធវិធីដូច ប៉ុល ពត ហើយពួកដែលមាននិន្នាការគាំទ្រ និងប្រើប្រាស់សន្ទឹកបៀរខ្មែរក្រហម នៅតែបន្តសកម្មភាពដូចសព្វថ្ងៃនេះទៀតនោះ ។

សម្រាប់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ឈ្មោះ ប៉ុល ពត តែងតែផ្សារភ្ជាប់ជាមួយនឹងការសម្លាប់រង្គាល ដែលធ្វើឲ្យពលរដ្ឋខ្មែររាប់លាននាក់ត្រូវស្លាប់ក្នុងរបបដែលគាត់ដឹកនាំនោះជានិច្ច ។ មរណភាពរបស់ ប៉ុល ពត បានធ្វើឲ្យមានការជជែកពិភាក្សាគ្នាគ្រប់កន្លែង តែហាក់មិនបានធ្វើឲ្យពលរដ្ឋខ្មែរដែលធ្លាប់រស់រងទុក្ខវេទនានិរាសព្រាត់ប្រាសក្នុងរបបនេះ សប្បាយរីករាយ ឬមានទុកកង្វល់អ្វីឡើយ ។

**ឆេព ម៉េងយាន**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

"ក្បង់ទឹកទន្លេ" គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងវិនិយោគពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត "ក្បង់ទឹកទន្លេ" ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ "ក្បង់ទឹកទន្លេ" បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញក ព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើបសហរដ្ឋអាមេរិក ប្រទេសអូទ្រីស ប៊ែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង អ៊ូច មករា តាមរយៈទូរស័ព្ទលេខ: ០១៧ ៦៦៥ ៦៧៥ ។ អ៊ីម៉ែល: *truthmakara@dccam.org*

គេហទំព័រ: *www.ariverchangescourse.com*





# «សាក្សី! ទីនេះមិនមែនជាមន្ទីរស-២១ទេ!»

*សហមេធាវីការពារក្ដីរបស់ ខៀវ សំផន អានតា ហ្គីស្សេ ធ្វើការបំភ្លឺតាមរយៈប្រធានបទចាំបាច់មួយចំនួនចោទសួរទៅកាន់សាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលកំពុងផ្ដល់សក្ខីកម្មនៅក្នុងដំណាក់កាលទីពីរនៃសំណុំរឿង០០២ ។ ថ្វីបើអតីតប្រធានគុកស-២១រូបនេះបានផ្ដល់នូវចម្លើយជាច្រើនដល់តុលាការកាលពីមុន លោកស្រី ហ្គីស្សេ បានរកឃើញនូវជ្រុងថ្មីទៀត ដោយផ្អែកលើសក្ខីកម្មរបស់សាក្សីក៏ដូចជាចម្លើយមួយចំនួនរបស់ ឌុច ផ្ទាល់ ។ នេះបានបញ្ជាក់នូវគោលគំនិតដ៏មានប្រសិទ្ធភាពមួយយ៉ាងហោចណាស់សម្រាប់ផ្នែកទីមួយនៃការស្ដាប់សក្ខីកម្មក្នុងថ្ងៃនេះ ។*

*ចាប់តាំងពីការចាប់ផ្ដើមសក្ខីកម្មរបស់សាក្សី សាក្សីមិនដែលឆ្លើយសំណួរក្នុងទម្រង់បដិសេធទេ ។ ទោះបីជាយ៉ាងណា លោកស្រី ហ្គីស្សេ ទទួលចម្លើយពីសាក្សីថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់មិនដែលចូលរួមនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាល កងវរៈរបស់ស្រុក ឬតំបន់ ឬចូលរួមនៅក្នុងការប្រជុំណាមួយទាក់ទងនឹងរចនាសម្ព័ន្ធទាំងនេះទេ ។ តួនាទីរបស់គាត់ត្រូវបានកំណត់ឲ្យនៅត្រឹមអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស-២១ ។ ដប់នាទីបន្ទាប់ពីការសួរសំណួរមេធាវីការពារក្ដីបានធ្វើសេចក្ដីសន្និដ្ឋានរួមសម្រាប់ថ្ងៃនេះ ។*

## *បរិវេណមន្ទីរស-២១ និងគោលនយោបាយសម្ងាត់*

*ដំបូង លោកស្រី ហ្គីស្សេ បានបញ្ជាក់ជាមួយសាក្សីថា អ្នកទោសមន្ទីរស-២១ បានចាកចេញពីទីតាំងប៉ូលីសទៅកាន់វិទ្យាល័យពញាយ៉ាត នៅចន្លោះថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៧៦ និងថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៦ ។ ឌុច បានបន្ថែមថា គាត់គឺជាអ្នកជ្រើសរើសទីតាំងនៃគុកនេះដោយសារមូលហេតុសន្តិសុខ ។ ការសួរចម្លើយអ្នកទោសត្រូវបានធ្វើឡើងនៅក្រៅបរិវេណនៃមន្ទីរស-២១ ។ សក្ខីកម្មមួយចំនួន ក្នុងនោះមានសក្ខីកម្មរបស់ ឡាច មាន ផងនោះបានលើកឡើងអំពីរបស់ស័ង្កសីហ៊ុមព័ទ្ធជុំវិញគុក ហើយ ឌុច មានប្រតិកម្មចំពោះការលើកឡើងនេះថា៖*

*“របងនេះបម្រើគោលបំណងពីរៈ ទីមួយ គឺដើម្បីរារាំងអ្នកទោសកុំឲ្យគេចខ្លួន ។ ទីពីរ គឺដើម្បីបញ្ឈប់អ្នកដទៃពីការឈ្លានពានមកក្នុងទីតាំងនេះ ។ មិនមានការពាក់ព័ន្ធនឹងខាងក្រៅទេ” ។*

*ឌុច បាននិយាយថាក្នុងនាមជាប្រធានមន្ទីរស-២១ គាត់ត្រូវធានាថា គាត់ព្រមទាំងអ្នកក្រោមបញ្ជាអនុវត្តតាមគោលនយោបាយ សម្ងាត់ ឬគាត់“ត្រូវគេកាត់ក្បាលកាលពីយូរណាស់មកហើយ” នេះជាសម្ដីដកស្រង់ពីឃ្លាមួយនៃបក្សកុម្មុយនីស្តកម្ពុជា ។*

*ភាពភ័យខ្លាចហាក់ដូចជាមានការកើនឡើងជារៀងរាល់ឆ្នាំ ខណៈដែលបក្សកាន់អំណាច ។ ឌុច ពន្យល់ថា នៅពេលដែលមានការចាប់ខ្លួនទ្រង់ទ្រាយធំចាប់ផ្ដើម ដោយរួមមានការចាប់ខ្លួន ហ៊ុយ ដែរ ។ គាត់មានការ “ភ័យខ្លាច” និង “ហត់នឿយយ៉ាងខ្លាំង” ។ គាត់ចំណាយពេលសមស្របមួយសម្រាកនៅផ្ទះ ទោះបីជាគាត់បានសន្និដ្ឋានថាប្រហែលជា៩០ភាគរយនៃការងាររបស់គាត់ទាក់ទងនឹងការអានចម្លើយសារភាពនៅផ្ទះ ហើយសូម្បីតែមានឋានៈជាប្រធានមន្ទីរស-២១ គាត់នៅតែមិនអាចចាកចេញពីបរិវេណគុកដោយមិនមានការអនុញ្ញាតពីអ្នកចាត់ការរបស់គាត់គឺ ប៉ង់ ដែលមាន លីន ជាអ្នកបន្តដំណែងបន្ទាប់ពី ប៉ង់ ត្រូវបានឃាត់ខ្លួនក្នុងឆ្នាំ១៩៧៧ ។*

## *អតីតអ្នកកាន់បញ្ជីមន្ទីរស-២១ សួស ធី*

*លោកស្រី ហ្គីស្សេ បានលើកឡើងនូវចម្លើយកាលពីមុនដែលផ្ដល់ឲ្យដោយសាក្សី សួស ធី ហើយ ឌុច បានបញ្ជាក់ថា សួស ធី ជាអ្នកទទួលបន្ទុកលើបញ្ជីអ្នកទោសធម្មតា មិនមែនលើបញ្ជីអ្នកទោសសំខាន់ៗទេ ។ ការពិពណ៌នារបស់ ឌុច អំពីតួនាទីរបស់អតីតអ្នកកាន់បញ្ជីមន្ទីរស-២១ បង្ហាញថា គាត់បានសួរអ្នកទោសដែលបាននាំខ្លួនមកនូវសំណួរសាមញ្ញ រួមមាន ឈ្មោះ មុខរបរ និងឆ្នាំកំណើតជាដើម ។*

*បន្ទាប់ពីសម្រាក ឌុច បានបញ្ជាក់ថា សួស ធី បានឆ្លើយតបទៅកាន់ ហ៊ារ ។ សហមេធាវីការពារក្ដី លោកស្រី ហ្គីស្សេ បានសួរ*

គាត់ថាតើគាត់អាចចាំបាននូវ "ការណែនាំពិសេសណាមួយដែល ហ៊ីរ ប្រាប់ដល់ សួស ធី ទាក់ទងនឹងព័ត៌មានរបស់អ្នកទោសជនជាតិវៀតណាមដែលចូលមកមន្ទីរស-២១ ដែលត្រូវកត់ត្រាទុក ដោយយោងទៅលើចម្លើយរបស់ សួស ធី ដើម្បីពន្យល់អំពីមូលដ្ឋាននៃសំណួររបស់លោកស្រី៖

"ដោយសារតែខ្ញុំមិនអាចសួរសំណួរទាក់ទងនឹងមុខតំណែងរបស់ជនជាតិវៀតណាម នៅពេលដែលឈ្មោះរបស់គេត្រូវបានកត់ត្រា (សួស ធី មិនចេះភាសាវៀតណាម) ហ៊ីរ បានប្រាប់ឲ្យខ្ញុំសរសេរថា "ជនបន្កប់" ហើយនៅពេលដែលគេមកពីកំពង់ធំ ខ្ញុំត្រូវដាក់ថា "អ្នកនេសាទ" ។

ឌុច បដិសេធលើចម្លើយនេះ ហើយបែរជាចាំថា ភាពខុសប្លែកគ្នាធ្វើឡើងរវាងជនជាតិវៀតណាមដែលចូលមកក្នុងប្រទេសអមជាមួយនឹងអាវុធ និងអ្នកដែលមិនមានអ្វីសោះ ប្រភេទទីមួយត្រូវបានដាក់ឆ្លារថាជាទាហាន និងប្រភេទទីពីរ ត្រូវបានហៅថាភ្នាក់ងារ ។ លោកស្រី ហ្គីស្សេ បានសួរថាតើគាត់មានបានពិភាក្សាបញ្ហានេះជាមួយ ហ៊ីរ ឬយ៉ាងណា ក៏ប៉ុន្តែសាក្សីបាននិយាយថា អ្នករាល់គ្នាបានដឹងអំពីគោលការណ៍នេះ ។

ឯកសារប្រឌិតត្រូវបានបង្ហាញដល់អ្នកទោសដើម្បីបង្ខំឲ្យផ្តល់នូវចម្លើយសារភាព ឯកសារប្រឌិតដើម្បីជំរុញឲ្យអ្នកទោសសារភាព គឺជាការអនុវត្តមួយដែលតែងតែត្រូវបានធ្វើឡើងលើអ្នកទោស "សំខាន់" នេះបើតាមសាក្សី ឌុច បានបញ្ជាក់ ។ វិធីសាស្រ្តនេះត្រូវបានប្រើប្រាស់លើអតីតមេបញ្ជាការភូមិភាគឧត្តរ កុយ ធួន ហៅ ឃួន ហើយក្នុងករណីនេះ សុន សេន ដែលជាថ្នាក់លើរបស់ឌុច ជាអ្នកបញ្ជា ។

ការអនុវត្តដទៃទៀតដែលបានលើកឡើងនៅក្នុងការសាកសួររបស់លោកស្រី ហ្គីស្សេ ទៅកាន់ ឌុច គឺការចុះកាលបរិច្ឆេទមុន និងការចុះកាលបរិច្ឆេទក្រោយ លើឯកសារនៃអ្នកទោសសំខាន់ៗមួយចំនួន ។ សាក្សីមិនដឹងច្បាស់ថាការងារទាំងនេះធ្វើឡើងញឹកញាប់ប៉ុណ្ណាទេ ។

ឌុច និង ហ៊ីរៈ អ្នកដែលគ្មានការភ័យខ្លាច និងអ្នកដែលពោរពេញដោយការភិតភ័យ "លោកសាក្សី តើលោកមានតួនាទីណាមួយក្នុងការដកតំណែង ណាត ពីមុខងារជាប្រធានមន្ទីរស-២១ ទេ?"

"អត់ទេ" នៅពេលដែលគាត់ត្រូវឃាត់ខ្លួន ខ្ញុំអង្វរ សុន សេន ឲ្យ ហុក ជំនួសដំណែងរបស់គាត់ "សុន សេន បានជេរខ្ញុំដោយសារបញ្ហានេះ"

"ក៏ប៉ុន្តែខ្ញុំរិះគន់ ណាត រាល់ថ្ងៃ នៅពេលដែលមានហេតុការណ៍កើតឡើង ។ វាគឺជាផ្នែកមួយនៃតួនាទីរបស់ខ្ញុំ ព្រោះខ្ញុំបានឃើញគាត់ប្រព្រឹត្តនូវកំហុស" ។

សាក្សីមិនអាចផ្តល់ចម្លើយជាក់លាក់ដល់លោកស្រី ហ្គីស្សេ ទាក់ទងនឹងទំនាក់ទំនងរវាង ហ៊ីរ និង ណាត ទេ ។ គាត់អាចត្រឹមតែបញ្ជាក់ថា ហ៊ីរ គឺជាប្រធានកងកម្លាំងពិសេស ក្រោមបញ្ជារបស់ណាត ។ សហមេធាវីការពារក្តីសម្រេចប្តូរទៅកាន់ចម្លើយពីមុនៗវិញដែលផ្តល់ដោយសាក្សី ដើម្បីបើកកកាយអំពីទំនាក់ទំនងរវាងគាត់ជាមួយនឹង ហ៊ីរ និង ណាត ។

សាក្សីបានលើកឡើងថា បន្ទាប់ពី ហ៊ីរ លេចនូវព័ត៌មានចោទប្រកាន់មួយចំនួនចេញពីចម្លើយសារភាព សុន សេន បានបញ្ជាឲ្យ ឌុច រារាំង ហ៊ីរ ពីការអានចម្លើយសារភាព ។ បន្ទាប់មក លោកស្រី ហ្គីស្សេ ព្យាយាមបញ្ជាក់ជាមួយសាក្សីថា ទង្វើនេះអាចនឹងធ្វើឲ្យមានការផ្លាស់ប្តូរលើទំនាក់ទំនងរបស់គេ ក៏ប៉ុន្តែ ឌុច បាននិយាយថានេះមិនបានធ្វើឲ្យទំនាក់ទំនងរបស់គេក្លាយជាអាក្រក់ឡើយ ។

ដើម្បីរំឭកការចងចាំរបស់ ឌុច សហមេធាវីការពារក្តីបានផ្អែកលើចម្លើយចំនួនពីររបស់ សួស ធីៈ

"លោកសាក្សី តើ តាណាត ខ្លាច ឌុច ឬទេ?"

"បាទ ថ្វីបើ តាណាត ជាអ្នកគ្រប់គ្រងកងពល ក៏ប៉ុន្តែគាត់ខ្លាច ឌុច ហើយ ហ៊ីរ ខ្លាច តាណាត យ៉ាងខ្លាំង" ។

និង "បាទ ជាថ្មីម្តងទៀត ខ្ញុំមិនបានដឹងអំពីទំនាក់ទំនងរវាង ណាត និង ឌុច ទេ ក៏ប៉ុន្តែខ្ញុំអាចប្រាប់អ្នកបានថា ហ៊ីរ ខ្លាច ឌុច ខ្លាំងណាស់" ។

នៅពេលប្រឈមនឹងចម្លើយទាំងនេះ ឌុច ញញឹម និងហាក់ដូចជាចំអក ។

"លោកសាក្សី នៅក្នុងទំនាក់ទនងរបស់លោកជាមួយនឹង ណាត និង ហ៊ីរ តើលោកមានចាប់អារម្មណ៍ថាគេទាំងពីរខ្លាចលោកទេ?"

"បាទ" ណាត ពិតជាខ្លាចខ្ញុំ ក៏ប៉ុន្តែពេលខ្លះគាត់ក៏ហ៊ានធ្វើអ្វី

ដោយខ្លួនឯងដែរ ។ គាត់ហ៊ាន ហើយនរណាៗក៏ដឹងដែរ ។

សាក្សីបានបន្ថែមទៀត ដោយតតាំងជាមួយភាគីម្ខាងទៀត តាមរយៈការបញ្ជាក់ថា គាត់គឺជាអ្នកកាន់អំណាចទាំងស្រុងចំពោះកម្មាភិបាលរបស់គាត់:

"ក្នុងនាមជាអ្នកដឹកនាំ ខ្ញុំមានគោលការណ៍បីចំពោះអ្នកក្រោមបង្គាប់របស់ខ្ញុំ: យល់ពីគេ អត់ឱនឲ្យគេ និងសប្បុរសចំពោះគេ ។ នៅពេលដែល ណាត ត្រូវបានឃាត់ខ្លួន ហ៊ីរ បានមកជួបខ្ញុំ គាត់ខ្លាចខ្ញុំណាស់" ។

### ការសួរចម្លើយ និងការចោទប្រកាន់នៅមន្ទីរស-២១

ឌុចបញ្ជាក់ថាគាត់បានត្រឹមតែឃើញចំណាររបស់ សុន សេន លើឯកសារមន្ទីរស-២១នៅក្នុងអំឡុងពេលសវនាការប៉ុណ្ណោះ ខណៈដែល"ឯកសារមន្ទីរស-២១ដែលត្រូវបានផ្ញើទៅកាន់ថ្នាក់លើរបស់ខ្ញុំគឺមានតែចំណាររបស់ខ្ញុំប៉ុណ្ណោះ ហើយឯកសារទាំងនោះមិនដែលត្រូវបានបញ្ជូនត្រឡប់មកខ្ញុំវិញទេ" ។

លោកស្រី ហ៊ុីស្សេ បានប្តូរទៅកាន់ប្រធានបទផ្សេងនៅមុនពេលសម្រាក ។ នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៦ សាក្សីបាននិយាយអំពី ស៊ឹម មុន ដែលជាជនជាតិចាមវ័យក្មេងម្នាក់បម្រើតួនាទីជាឆ្មាំមន្ទីរស-២១ ។ ឌុច បានបញ្ជាក់ថា បន្ទាប់ពីសារភាពអំពីទោសកំហុស ស៊ឹម មុន ត្រូវបានបញ្ជូនទៅព្រៃស ហើយបន្ទាប់ពីមានកំហុសបន្ថែម គាត់ត្រូវបានសួរចម្លើយរួចកម្ទេចចោល ។

សហមេធាវីការពារក្តី ហ៊ុីស្សេ ព្យាយាមកំណត់នូវឧទាហរណ៍ទាក់ទងនឹងការចោទប្រកាន់ដែលអាចជឿជាក់បានស្តីពីវិធីសាស្ត្រសួរចម្លើយ ។

ឌុច បញ្ជាក់ថានៅពេលអ្នកសួរចម្លើយចោទសួរទៅកាន់អ្នកទោស គេសួរអំពីព័ត៌មានលម្អិតអំពីអ្នកទោសនោះដើម្បីរកចំណុចខ្សោយ និងបង្កើតសំណួរតាមនោះ ។ ទោះបីជាយ៉ាងណាអ្នកសួរចម្លើយធ្វើការសង្ខេប និងកំណត់ទិន្នន័យជីវប្រវត្តិនៅដើមដំបូងនៃការសួរចម្លើយ ។ បន្ទាប់មក ឌុច បញ្ជាក់ថាគាត់ជាអ្នកបង្រៀនអ្នកសួរចម្លើយអំពីរបៀបសួរចម្លើយអ្នកទោស ក៏ប៉ុន្តែគាត់បានបដិសេធចំពោះការលើកឡើងថាមានច្បាប់ជាក់លាក់មួយតាមអ្វីដែលការចោទប្រកាន់មួយចំនួនបញ្ជាក់អំពីភាពអាចទៅរួចដែលនរណាមួយត្រូវបានឃាត់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

"ច្បាប់បីដងរាប់មួយមានតែនៅក្នុងទ្រឹស្តីប៉ុណ្ណោះ គាត់បានបន្ថែមទៀតថា បងម៉ុក ត្រូវបានទាញឲ្យពាក់ព័ន្ធនៅក្នុងចម្លើយសារភាពចំនួន១៥របស់មន្ទីរស-២១ ក៏ប៉ុន្តែគាត់នៅតែជាអនុប្រធាននៃកងយោធា

### ជម្លោះប្រដាប់អាវុធជាមួយវៀតណាម

កាលពីម្សិលមិញ ឌុច បានប្រាប់សហមេធាវីការពារក្តីរបស់ នួនជា វិកទ័រ កូប៉េ ថាសង្គ្រាមរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមត្រូវបានបង្កឡើងនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ។ ថ្ងៃនេះ ឌុច បានធ្វើការកែតម្រូវថា ថ្ងៃពិតប្រាកដគឺនៅក្នុងឆ្នាំ១៩៧៨ ។ ដោយត្រូវបានសួរបន្តទៀតដើម្បីទទួលបានព័ត៌មានបន្ថែមអំពីពេលដែលគាត់ដឹងអំពីជម្លោះនេះ សាក្សីបាននិយាយថាគាត់ដឹងថាមានការប៉ះទង្គិចនានារវាងកងកម្លាំងទាំងពីរនៅក្នុងខែវិច្ឆិកា និងខែធ្នូឆ្នាំ១៩៧៧ រហូតដល់ពេលដែលបក្សកុម្មុយនីស្តកម្ពុជាផ្ទុះសង្គ្រាមឡើង ។

ទោះបីជាសុទ្ធរកថារបស់ ប៉ុល ពត បានលើកឡើងអំពីជម្លោះកាលពីដើមឆ្នាំ១៩៧៨ ក្តី សាក្សីបញ្ជាក់ថា គាត់បានដឹងអំពីជម្លោះនៅមុនពេលនេះទៅទៀត ។ គាត់ចងចាំយ៉ាងច្បាស់ពីការប្រជុំមួយនៅក្នុងខែមករា ឆ្នាំ១៩៧៨ ក្នុងអំឡុងពេលដែល ប៉ុល ពត បានថ្លែងអំពីស្ថានភាពយោធា ហើយបានបន្ថែមទៀតថា "កសិករ និងកម្មករគឺជាគ្រឹះនៃកងទ័ព"

### ទំនាក់ទំនងរវាងមន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខដទៃទៀត

លោកស្រី ហ៊ុីស្សេ បានបន្តទៅមន្ទីរសន្តិសុខដែលមាននៅគ្រប់ទីតាំងក្នុងប្រទេសនាអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងបានសួរអំពីការយល់ដឹងរបស់ ឌុច ស្តីពីចំនួននៃមន្ទីរទាំងនោះ ។ សាក្សីបានឆ្លើយថា គាត់បានដឹងត្រឹមចំនួនជាក់លាក់នៃមន្ទីរសន្តិសុខទាំងនេះប៉ុណ្ណោះ (ពីរនៅពេលនោះ) នេះដោយសារតែកន្លះខាតនៃការទាក់ទងរវាងមន្ទីរសន្តិសុខទាំងឡាយ នៅក្នុងកម្រិតស្មើគ្នា ។ មន្ទីរស-២១ មិនគ្រប់គ្រងលើមន្ទីរសន្តិសុខដទៃទៀតទេ ទំនាក់ទំនងធ្វើឡើងតែមួយប៉ុណ្ណោះ គឺធ្វើការរាយការណ៍ទៅកាន់គណៈកម្មាធិការ៨៧០ ។ ទោះបីជាយ៉ាងណា មកទល់ពេលនេះ គាត់ដឹង

ថាមានមន្ទីរសន្តិសុខចំនួន១៩៦ ។

សាក្សីបានធ្វើការលើកឡើងអំពីអ្នកគ្រប់គ្រងផ្ទាល់របស់គាត់ ប៉ន់ នៅក្នុងបរិវេណមន្ទីរស-២១ ជារៀងរាល់ថ្ងៃដើម្បីប្រមូលចម្លើយសារភាព នៅពេលដែល នួន ជា ជាថ្នាក់លើរបស់គាត់ផងនោះ ទាក់ទងជាមួយគាត់ពីរបីដងប៉ុណ្ណោះក្នុងមួយសប្ដាហ៍ ។ ប៉ន់ ត្រូវបានអនុញ្ញាតឲ្យទៅកាន់បរិវេណមន្ទីរស-២១ជាមួយ ឌុច តែមិនអាចចូលរួមការសួរចម្លើយទេ ។ គាត់នឹងយកចម្លើយសារភាពនានាទៅកាន់គណៈកម្មាធិការ៨៧០ ពោលគឺគណៈកម្មាធិការមជ្ឈិម ដោយដាក់វានៅក្នុងស្រោមសំបុត្របិទជិត ។

«លោកសាក្សី តើ ប៉ន់ បានដឹងអំពីគោលនយោបាយដែលលោកពិពណ៌នាទេ នោះគឺការលើកឡើងថា នៅពេលដែលអ្នកទោសត្រូវបានឃាត់ខ្លួន គេនឹងត្រូវកម្ទេច» ។

«ខ្ញុំជឿថាគាត់បានដឹង ព្រោះវាជាគោលនយោបាយទូទៅមួយរបស់បក្សកុម្មុយនីស្ដកម្ពុជា ។ ច្បាប់របស់បក្សគឺមិនមែនជាអ្វីដែលអាចពិភាក្សាបានថាតើវាសមស្របឬអត់ទេ ។ អ្វីដែលបានកំណត់ដោយបក្ស វាត្រូវតែអនុវត្ត» ។

ឌុច បានសារភាពថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់មិនបានដឹងអ្វីទាំងអស់ដែលបានកើតឡើងនៅមន្ទីរសន្តិសុខដទៃទេ បើទោះជាគាត់បានសន្និដ្ឋានថាគោលនយោបាយរបស់បក្សត្រូវបានធ្វើឡើងនៅគ្រប់ទីកន្លែងយ៉ាងណាក្ដី ។ សំណួរបន្តបន្ទាប់របស់សហមេធាវីការពារក្ដី អានតា ហ្គីសេ្ស បង្ហាញអំពីការវាយតម្លៃបែបយុទ្ធសាស្ត្ររបស់គាត់លើការយល់ដឹងមានកម្រិតរបស់សាក្សីចំពោះបញ្ហានេះ ដោយឈានហួសពីមន្ទីរស-២១ ដោយស្ថិតនៅក្នុងភាពមិនផ្លាស់ប្ដូរចាប់តាំងពីសំណួរដំបូងរបស់គាត់នៅក្នុងថ្ងៃនេះ ។

## អ្នកគ្រប់គ្រងផ្ទាល់របស់ ឌុច, ប៉ន់ ដែលត្រូវចោទប្រកាន់

ចម្លើយសារភាពរបស់ប្រធានសន្តិសុខនៅមន្ទីរស-២១ ឈឹម សំអោក ហៅ ប៉ន់ មានលក្ខណៈ «ភ័ន្តច្រឡំ» ឌុច បាននិយាយព្រមទាំងគ្រវីក្បាល «ដូច្នេះគាត់ក៏ត្រូវកម្ទេច» ។ សាក្សីមិនអាចចាំបានទេថានៅពេលជាក់លាក់ណាដែលគាត់ត្រូវបានគេសម្លាប់ ក៏ប៉ុន្តែគាត់ត្រូវបានឃុំខ្លួនពីរបីថ្ងៃបន្ទាប់ពេលអបអរថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៨ វាហាក់ដូចជានៅថ្ងៃទី២០ ឬ២១ ខែមេសា ឆ្នាំ១៩៧៨ ។

ដោយត្រឡប់ទៅកាន់គំនិតចំពោះអ្នកទោស «សំខាន់» និង «មិនសំខាន់» ឬ «សាមញ្ញ» ដែលលើកឡើងដោយលោក កូប៉េ កាលពីម្សិលមិញ លោកស្រី ហ្គីសេ្ស បានសួរ ឌុច ថាតើ ប៉ន់ ត្រូវបានចាត់ចូលក្នុងផ្នែកណាមួយ ។ ឌុច បានឆ្លើយថា ប៉ន់ គឺជាអ្នកទោសសំខាន់ ព្រោះគាត់ជិតដិតនឹងថ្នាក់ដឹកនាំមានឈ្មោះថា ផល ។ សាក្សីបានពន្យល់ថាៈ ប៉ុន ជាអ្នកសួរចម្លើយ ប៉ន់ ដោយប្រើប្រាស់ «វិធីសាស្ត្រក្ដៅ» (មានន័យថាការធ្វើបាបផ្លូវកាយ និងទារុណកម្ម) ហើយ ឌុច មិនបានឃើញគាត់និយាយទៅកាន់ ប៉ុន ទេ ខណៈដែលគាត់ត្រូវបានគេឃុំឃាំង និងសួរចម្លើយនៅមន្ទីរស-២១ ។

ពីមុន ឌុច បានលើកឡើងថា គាត់បានចូលរួមនៅក្នុងអង្គប្រជុំកាលពីថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ គឺមួយថ្ងៃនៅមុនពេលកងទ័ពវៀតណាមចូលទីក្រុងភ្នំពេញ ។ កិច្ចប្រជុំចង្អៀតនេះផ្ដល់នូវព័ត៌មានសំខាន់ៗ ដូចទៅនឹងអ្វីដែលសាក្សីបានធ្វើសក្ខីកម្ម កិច្ចប្រជុំនេះដឹកនាំដោយ ខៀវ សំផន ដែលជាអ្នកប្រាប់អ្នកទាំងអស់គ្នាកុំឲ្យព្រួយបារម្ភអំពីកងទ័ពសត្រូវ ។ អ្នករាល់គ្នាគួរតែបន្តធ្វើការ និង «ផ្ដោតលើការងាររបស់ខ្លួន» វាជាឃ្លាមួយដែលលើកឡើងជាច្រើនលើកច្រើនសាដោយសាក្សី និងអតីតអ្នកកាន់បញ្ជី សួស ធី នៅក្នុងសក្ខីកម្មរបស់គាត់កាលពីដើមខែមិថុនា ។

លោកស្រី ហ្គីសេ្ស បង្ហាញលេខយោងរបស់ឯកសារដោយប្រុងប្រយ័ត្ន បង្ហាញនូវសម្រង់សម្ដីរបស់ ឌុច ដែលលើកឡើងថាមិនមែនមានគ្នា៦នាក់ទេ មានមនុស្សបីឬបួននាក់ដែលចូលរួមនៅក្នុងអង្គប្រជុំដោយគាត់បានសួរថាៈ

«ខ្ញុំនៅតែប្រកាន់យកចម្លើយរបស់ខ្ញុំ ។ ការចងចាំរបស់ខ្ញុំនៅតែល្អ ឲ្យនៅក្នុងឆ្នាំ២០០៧»

ទោះបីជាយ៉ាងណា ក្រោយពីប្រឈមមុខនឹងសក្ខីកម្មចំនួនពីរទាក់ទងនឹងកិច្ចប្រជុំប្រហាក់ប្រហែលនេះ ឌុច ប្រកាន់យកចម្លើយនាពេលថ្មីៗរបស់គាត់ ៖ នៅក្នុងកិច្ចប្រជុំ ខៀវ សំផន មិនបានឲ្យគេចាកចេញពីភ្នំពេញមួយរយៈកាលដើម្បីរៀបចំប្រឆាំងនឹងកងទ័ពវៀតណាមទេ ។ គាត់បានស្នើឲ្យអ្នកទាំងអស់នៅបន្ត និងធ្វើការ ឌុច បានលើកឡើងដដែលៗ ។

«លោកសាក្សី បើតាមអង្គប្រជុំនេះ លោកបានត្រឡប់ទៅកាន់មន្ទីរស-២១វិញ ។ តើលោកមានចេញបញ្ជាអ្វីដល់អ្នកក្រោម

បង្គាប់របស់លោកដោយធ្វើតាមកិច្ចប្រជុំនេះឬទេ?»

«ទេ! ខ្ញុំគ្រាន់តែបង្គាប់ដល់អ្នកសួរចម្លើយអំពីអ្នកទោសបួននាក់ពីម-៨ ឲ្យដែលត្រូវកម្ទេចប៉ុណ្ណោះ» ។

បន្ទាប់មក ឌុច បានពិពណ៌នានូវអ្វីដែលគាត់បានឃើញ អៀង សារី នៅក្នុងឡានពីចម្ងាយៈ «គាត់មានទឹកមុខមាំ» ។

«បន្ទាប់ពីថ្ងៃទី៣ ខែមករា ខ្ញុំនឿយហត់ និងអស់សង្ឃឹម ។ បន្ទាប់ពីការឃាត់ខ្លួនកម្មាភិបាលរបស់ខ្ញុំ ខ្ញុំគិតថាថ្ងៃណាមួយ វានឹងដល់វេនខ្ញុំ»

បន្ទាប់ពីត្រូវបានសួរសំណួរដោយលោកស្រី ហ្គីស្សេ សាក្សីមានភាពច្បាស់ការណ៍ថាការសម្លាប់រង្គាលនៅមន្ទីរស-២១ កើតមានឡើងនៅក្នុងខែមករា ឆ្នាំ១៩៧៩ មិនមែនក្នុងខែធ្នូ ឆ្នាំ១៩៧៨ ទេៈ «មានការបង្គាប់ឲ្យសម្លាប់អ្នកទោសទាំងអស់ ។ វាជាការបង្គាប់របស់ នួន» ។ លោកស្រី ហ្គីស្សេ បានទទួចថា សាក្សីមួយចំនួនមិនបានដឹងអំពីរឿងនេះទេ ។

«តាមអ្វីដែលខ្ញុំចាំអ្នកទាំងនោះត្រូវបានសម្លាប់នៅត្រឹមខែមករា ដោយសារមានអ្នកទោសជាច្រើន វាមានការលំបាកក្នុងការកម្ទេចមនុស្សគ្រប់គ្នាដោយប្រើតែរយៈពេលបីថ្ងៃ» ។

## ឌុច មិនទទួលខុសត្រូវលើចម្លើយរបស់គាត់ទេ

ការអះអាងដូចខាងក្រោមនេះបង្ហាញអំពីចំណុចបញ្ចប់ក្នុងថ្ងៃនេះ ។ សហមេធាវីការពារក្តី អានតា ហ្គីស្សេ ចាប់ផ្តើមដោយយោងលើចម្លើយរបស់ ឌុច កាលពីឆ្នាំ១៩៩៩ ដែលធ្វើឡើងនៅមុខតុលាការយោធាៈ «មកទល់ពេលនេះ ខ្ញុំមិនទាន់បានជួប ខៀវ សំផន និង អៀង សារី ទេ សូម្បីតែម្តង» ។ សាក្សីបានធ្វើការប្រឆាំងយ៉ាងដាច់អហង្ការចំពោះប្រយោគនេះ ។

លោកស្រី ហ្គីស្សេ បង្ហាញ ថាក្នុងថ្ងៃនេះគាត់ត្រូវតែប្រឈមជាមួយនឹងចម្លើយរបស់គាត់កាលពីឆ្នាំ២០០៧ គាត់ជ្រើសរើសនិងប្រកាន់ខ្ជាប់នូវចម្លើយនេះ ដោយអះអាងថាវាកៀកទៅនឹងព្រឹត្តិការណ៍ដែលបានសួរនៅក្នុងសំណួរ ។

«ការចងចាំរបស់លោកប្រហែលជាច្បាស់ជាងនេះនៅក្នុងឆ្នាំ១៩៩៩ លោកសាក្សី»

«ការប្រជុំរវាងខ្ញុំ និងបង ហែម ឲ្យខៀវ សំផន បានឆ្លាក់ជាប់នៅក្នុងចិត្តខ្ញុំជានិច្ច ។ ខ្ញុំនឹងមិនភ្លេចព្រឹត្តិការណ៍ទាំងពីរនេះទេ» ។

សាក្សីប្រែជាអន្ទះអន្ទែងជាងមុនបង្វិលកៅអីរបស់គាត់ចុះឡើងព្រមទាំងសម្តែងនូវកាយវិការដ៏រស់រវើករបស់គាត់ ។ គ្រវីម្រាមដៃរបស់គាត់ ឌុច បានស្តីបន្ទោសលោកស្រី ហ្គីស្សេ ថាៈ

«អ្នកឯងបានអានត្រឹមតែផ្នែកមួយ ហើយប្រានចោលនូវផ្នែកដទៃទៀត»

សហមេធាវីការពារក្តីបានឆ្លើយតបថា ឌុច បានផ្តិតក្រយៅដៃ និងចុះហត្ថលេខាលើចម្លើយកាលពីឆ្នាំ១៩៩៩នោះ នៅមុខតុលាការយោធា ។ «ឯកសារនេះពោរពេញទៅដោយការសង្ស័យ» សាក្សីបានស្រែកឡើង ។ លោកស្រី ហ្គីស្សេ ដែលនៅតែរក្សាភាពនឹងធឹងពេញមួយថ្ងៃបានបន្តសួរគាត់ទៀតថាៈ

«លោកសាក្សី ហេតុអ្វីបានជាលោកនិយាយថាឯកសារនេះពោរពេញដោយការសង្ស័យ? តើដោយសារតែវាមិនបានសំដៅលើអង្គប្រជុំទាំងស្រុង ឬដោយសារតែលោកមិនបានផ្តិតក្រយៅដៃនិងចុះហត្ថលេខាលើឯកសារដែលឲ្យមិនបានផ្តល់ព័ត៌មានពេញលេញ?

«សូមមេធាវីផ្តល់នូវកំណត់ត្រាជាលាយលក្ខណ៍អក្សរពេញលេញនៃបទសម្ភាសន៍នេះដល់ខ្ញុំ» ។

«លោកសាក្សី យើងមិនមែនជាមន្ទីរស-២១ ដែលជាទីកន្លែងដែលលោកអាចបញ្ជាមនុស្សឲ្យធ្វើអ្វីដែលលោកចង់បានទេ ។ នេះគឺជាការសួរសំណួរ» ។

ដោយសារតែមានការខទានឡើងធ្វើឲ្យមានសភាពតានតឹង លោកប្រធាន និងជាចៅក្រមនៃអង្គជំនុំជម្រះ និល ណុន បានចេញជាបង្គាប់ដល់សហមេធាវីការពារក្តី ហ្គីស្សេ ដោយលើកឡើងថាសាក្សីបានធ្វើការស្នើសុំ ។

លោកស្រី ហ្គីស្សេ ធ្វើការសន្និដ្ឋានលើការសួរចម្លើយរបស់គាត់ក្នុងថ្ងៃនេះ ដោយធ្វើការយោងទៅលើសេចក្តីណែនាំដែលផ្តល់ឲ្យដោយ ខៀវ សំផន នៅក្នុងអំឡុងអង្គប្រជុំដែលបានលើកឡើងខាងលើ ។ ឌុច នៅតែរក្សាជំហររបស់គាត់ ។ លោកប្រធានបានពន្យារពេលស្តាប់ក្តី ដែលនឹងបន្តនៅថ្ងៃស្អែកទៀតគឺនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ នៅម៉ោង៩ព្រឹក ។

**អាលីស មើហ្គើរ**

# ការឈឺចាប់ពីអតីតកាលមិនគួរប្រៀបធៀបគ្នា

កាលពីថ្ងៃសុក្រសប្តាហ៍មុន ខ្ញុំបានចូលរួមកម្មវិធីសម្ពោធពាក្យស្លោកស្តីអំពីការអប់រំអំពើប្រល័យពូជសាសន៍ និងការចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-៧៩) ដែលសហការដោយក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា នៅវិទ្យាល័យព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ នាឱកាសនោះ ខ្ញុំបានសម្ភាសជាមួយដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមួយចំនួន ដែលបានចូលរួមកម្មវិធីសម្ពោធពាក្យស្លោកនៅព្រឹកនោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ប្រាប់ខ្ញុំអំពីជីវិតគាត់កាលពីរបបខ្មែរក្រហម ។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានរំលឹកឡើងវិញនូវបទពិសោធន៍របស់ខ្លួនដោយងាយស្រួលនៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនផ្សេងទៀតហាក់ដូចជាជួបប្រទះនូវបញ្ហាពិបាកក្នុងការរៀបរាប់រឿងរ៉ាវដែលគាត់បានឆ្លងកាត់ ។ គាត់បានយំជាមួយអារម្មណ៍ដ៏ក្តុកក្តួល ហាក់ដូចជារឿងរ៉ាវទាំងអស់នោះទើបតែបានកើតឡើងកាលពីម្សិលមិញ ។ ខ្ញុំគិតថា មនុស្សម្នាក់ៗមានលក្ខណៈពិសេសរៀងខ្លួនៗ ។ ដូច្នេះការឈឺចាប់របស់មនុស្សម្នាក់ទាក់ទងនឹងអតីតកាលមិនគួរយកមកប្រៀបធៀបគ្នានោះទេ ។

ខ្ញុំបានដឹងថា ប្រជាជនកម្ពុជាច្រើនលាននាក់បានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ នៅពេលដែលរបបខ្មែរក្រហមបានដួលរលំទៅអ្នករស់រានមានជីវិតមួយចំនួនបានបន្តជួបប្រទះបញ្ហាផ្លូវចិត្ត ស្របពេលដែលអ្នករស់រានមានជីវិតមួយចំនួនបានបាត់បង់ផ្ទះសម្បែង ទ្រព្យសម្បត្តិ និងសាច់ញាតិ ។ យើងពិតជាមិនអាចធ្វើការសន្និដ្ឋាន ឬប្រៀបធៀបបាននោះទេថា នរណាម្នាក់ទទួលរងផលប៉ះពាល់ធ្ងន់ជាងនរណាម្នាក់នោះ ។ អ្វីដែលយើងដឹងច្បាស់នោះគឺអ្នករស់រានមានជីវិតគ្រប់រូបមានរឿងរ៉ាវផ្ទាល់ខ្លួនដែលអាចចែករំលែកដល់យើងគ្រប់គ្នា ។ មកដល់ពេលបច្ចុប្បន្ន យើងអាចមានសំណាងដោយបានរស់នៅប្រកបដោយភាពគ្រប់គ្រាន់ ដូច្នេះយើងអាចនឹងជួបការលំបាកក្នុងការស្វែងយល់អំពីភាពឯកា និងទំហំនៃការឈឺចាប់របស់មនុស្សដទៃដែលធ្លាប់ជួបប្រទះ ។

មនុស្សមួយចំនួនធ្លាប់បានប្រៀបធៀបអំពីផលប៉ះពាល់ផ្លូវចិត្តរបស់ជនរងគ្រោះម្នាក់ជាមួយជនរងគ្រោះម្នាក់ទៀត ។ ប៉ុន្តែខ្ញុំឆ្ងល់ថាតើគាត់អាចដឹងអំពីស្ថានភាពរបស់ជនរងគ្រោះដទៃដោយមធ្យោបាយណា? ខ្ញុំជឿថា ជនរងគ្រោះម្នាក់ៗមានវិធីសាស្ត្ររៀងៗខ្លួនក្នុងការព្យាបាលរបួសអំពីអតីតកាល ។ នៅពេលដែលជនរងគ្រោះមួយចំនួនព្យាយាមបំភ្លេចរឿងរ៉ាវដែលបានកើតឡើងមកលើខ្លួនជនរងគ្រោះមួយចំនួនផ្សេងទៀតព្យាយាមបន្តរំលឹករឿងរ៉ាវដែលបានកើតឡើង ។ ជាក់ស្តែងការឈឺចាប់ ឬរបួសពីអតីតកាលមិនអាចរៀបរាប់ជាបរិមាណបាននោះទេ ។ ការឈឺចាប់របស់បុគ្គលមួយអាចមិនបានប៉ះពាល់ដទៃ ប៉ុន្តែយើងមិនអាចមើលស្រាលបានឡើយ ។ ផ្ទុយទៅវិញ យើងគ្រប់គ្នាគួរចូលរួមចែករំលែក និងលើកទឹកចិត្តដល់ជនរងគ្រោះដែលកំពុងជួបប្រទះនូវការប៉ះទង្គិចផ្លូវចិត្ត ដើម្បីគាត់ទាំងអស់គ្នាអាចទទួលបានអារម្មណ៍ធូរស្រាលជាងមុន ។

ដូច្នេះ នៅពេលដែលយើងប្រទះឃើញជនរងគ្រោះណាម្នាក់ធ្លាប់ឆ្លងកាត់អតីតកាលដែលឈឺចាប់ យើងគួរព្យាយាមស្តាប់និងស្វែងយល់រឿងរ៉ាវរបស់គាត់ដោយយកចិត្តទុកដាក់ ។

**ស៊ីរិន ចាង**



ស៊ីរិន ចាង រូបខាងឆ្វេង ជួបសម្ភាសន៍ជនរងគ្រោះពីរបបខ្មែរក្រហម (រូបខាងស្តាំបង្អស់) និង ម៉ែន ពិចិត្រ អ្នកបកប្រែ (រូបនៅកណ្តាល)

# ការសម្ពោធពាក្យស្លោកស្ដីអំពីការអប់រំអំពើប្រល័យពូជសាសន៍ នៅវិទ្យាល័យព្រៃល្វា

ក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា បានសម្ពោធពាក្យស្លោករបស់គម្រោងអប់រំអំពីអំពើប្រល័យពូជសាសន៍ និងចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅវិទ្យាល័យព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ កម្មវិធីនេះប្រព្រឹត្តទៅនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោង៨ព្រឹក ក្រោយអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា លោក អ៊ូច សុជាតិ នាយកវិទ្យាល័យព្រៃកប្បាស លោក វ៉ាន់ថាន់ ពៅដារ៉ា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ដេង ពង្សរ៉ាស៊ី ប្រធានគម្រោងអប់រំអំពីអំពើប្រល័យពូជសាសន៍ ។ សិស្សានុសិស្ស៣០០នាក់ និងលោកគ្រូអ្នកគ្រូ២០នាក់ ព្រមទាំងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាប្រហែល១០នាក់បានចូលរួមកម្មវិធីនេះ ។ កម្មវិធីនេះទទួលបានការឧបត្ថម្ភពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍ និងមូលនិធី *Chino Cienega Foundation (CCF)* តាមរយៈលោកស្រី សាលី បេ៊ិនសាន់ *(Sally Benson)* ។

ជាកិច្ចចាប់ផ្ដើមកម្មវិធី លោកជំទាវ លោកនាយកវិទ្យាល័យ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាលោកគ្រូអ្នកគ្រូ ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ព្រមទាំងសិស្សានុសិស្សបានក្រោកឈរគោរព និងច្រៀងភ្លេងជាតិ ។

បន្ទាប់ពីគោរពភ្លេងជាតិ លោកនាយក អ៊ូច សុជាតិ បានគោរពថ្លែងអំណរគុណភ្ញៀវកិត្តិយស ជាពិសេស ក្រសួងអប់រំ យុវជន និងកីឡា លោកជំទាវ ទន់ សាអ៊ីម និងមជ្ឈមណ្ឌលឯកសារកម្ពុជា



ពិធីសម្ពោធពាក្យស្លោកនិយាយពីរបបខ្មែរក្រហម នៅវិទ្យាល័យព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ ក្រោមអធិបតីភាពលោកជំទាវ ទន់ សាអ៊ីម រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា



ពិធីសម្ពោធពាក្យស្លោកនិយាយពីរបបខ្មែរក្រហម នៅវិទ្យាល័យព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ ក្រោមអធិបតីភាពលោកជំទាវ ទន់ សាអ៊ឹម រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា

ដែលបានយកពាក្យស្លោកនេះមកវិទ្យាល័យព្រៃល្វា ។ លោក អ៊ូច សុជាតិ បានរៀបរាប់អំពីស្ថានភាពវិទ្យាល័យព្រៃល្វា ដោយចាប់ផ្ដើមដំបូងអំពីអាគារសិក្សាដែលមានចំនួន១០អាគារ គ្រូចំនួន ៦០នាក់ ក្នុងនោះគ្រូស្រីចំនួន១៨នាក់ ។ បើយោងតាមលោកនាយក ចំនួនសិស្សថ្នាក់ទី១២ ដែលប្រលងជាប់ឆ្នាំមុនបានកើនឡើងច្រើនជាងឆ្នាំកន្លងចំនួន ៥,៧៦% ។ លោកនាយកបានមានប្រសាសន៍ថា ពាក្យស្លោកនេះនឹងក្រើនរំលឹកសិស្សានុសិស្សឲ្យចងចាំអំពីរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៅពេលដែលសិស្សានុសិស្សដើរកាត់ ។

លោកនាយករង វ៉ាន់ថាន់ ពៅដារ៉ា បានថ្លែងបន្ទាប់ពីលោកនាយកវិទ្យាល័យ អ៊ូច សុជាតិ ។ ជាមួយនឹងស្នាមញញឹមនៅលើមុខ លោកនិយាយទៅកាន់សិស្សានុសិស្សថា លោកមានអារម្មណ៍សប្បាយរីករាយមិនខុសអំពីលោកនាយកវិទ្យាល័យប៉ុន្មានទេ ។ ជាកិច្ចបឋម លោកបានថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា លោកជំទាវ ទន់ សាអ៊ឹម ដែលតែងតែគាំទ្រកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជារាបមក ដូចជាការសម្ពោធពាក្យស្លោកនៅថ្ងៃ ក៏ដូចជាការបណ្ដុះបណ្ដាលគរុសិស្សអំពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។ ការបណ្ដុះបណ្ដាលនេះមានសារសំខាន់ក្នុងការអប់រំប្រជាជនកម្ពុជាឲ្យចេះផ្សះផ្សាតាមរយៈការអប់រំអំពីអតីតកាល ។ ដូចដែលអត្ថន័យនៃពាក្យស្លោក នេះបានលើកឡើងដូច្នេះដែរ ។ លោក វ៉ាន់ថាន់ ពៅដារ៉ា បានជំរុញលើកទឹកចិត្តសិស្សានុសិស្សខិតខំប្រឹងប្រែងសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងចូលរួមទប់ស្កាត់កុំឲ្យរបបនេះកើតឡើងម្ដងទៀត មិនតែប៉ុណ្ណោះចូលរួមផ្សះផ្សា និងព្យាបាលរបួសពីអតីតកាល ដើម្បីទទួលបានសុខសន្តិភាព ។

លោកជំទាវ ទន់ សាអ៊ឹម បានចូលរួមថ្លែងបន្ត ។ លោកជំទាវបានមានប្រសាសន៍អំពីគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការសាងសង់វិទ្យាស្ថានស្លឹករឹតនៅថ្ងៃអនាគត ក្នុងការបន្តបង្រៀន និងថែរក្សាប្រវត្តិសាស្ត្រខ្មែរក្រហម ។ លោកជំទាវបានរំលឹកសិស្សានុសិស្សអំពីសារសំខាន់នៃការយល់ដឹងអំពីប្រវត្តិសាស្ត្រ មិនថាប្រវត្តិសាស្ត្រកាលពីសម័យមុននោះទេ ។ លោកជំទាវបានសង្កត់ធ្ងន់ថា ដើម្បីកសាងប្រទេសជាតិឲ្យរឹងមាំ សិស្សានុសិស្សត្រូវសិក្សាស្វែងយល់អំពីប្រវត្តិបើទោះបីប្រវត្តិសាស្ត្រនោះជាប្រវត្តិសាស្ត្រជូរចត់ខ្មៅងងឹតក៏ដោយ ។ សិស្សានុសិស្សទាំងអស់គួរតែចងចាំកិច្ចខិតខំប្រឹងប្រែងរបស់ឪពុកម្ដាយដែលបានខិតខំបញ្ជូនខ្លួនមកសាលារៀន ។

ចំពោះសិស្សានុសិស្សថ្នាក់ទី១២ដែលនឹងប្រលងថ្នាក់ជាតិនាពេលខាងមុខ ត្រូវតែខិតខំបន្ថែមទៀតស្របពេលដែលក្រសួងបានរឹតបន្តឹង និងបានធ្វើការកែទម្រង់ប្រសើរជាងមុន ។ សិស្សានុសិស្សគួរតែចេះបង្កើតក្លឹបសិក្សាឲ្យបានច្រើន ដើម្បីជួយគ្នា និងចែករំលែកចំណេះដឹងគ្នា ។ លោកជំទាវព្រមទាំងបានលើកទឹកចិត្តឲ្យសិស្សានុសិស្សជ្រើសរើសមុខវិជ្ជាសិក្សាដែលខ្លួនចូលចិត្ត និងប្ដេជ្ញាសិក្សាឲ្យបានពូកែ ។ ជាមួយកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធ្វើកំណែទម្រង់ក្រសួងក៏បានគិតគូរដល់ការដំឡើងប្រាក់ខែគ្រូបង្រៀន និងបញ្ចូលមុខវិជ្ជាសិក្សាដល់សិស្សានុសិស្ស ក៏ដូចជាការសិក្សាអំពីប្រវត្តិសាស្ត្រ

កម្ពុជាប្រជាធិបតេយ្យ ។ ជាចុងក្រោយ លោកជិតាវ បានដាស់តឿនសិស្សានុសិស្សថា “ប្រសិនបើយើងមិនជួយខ្លួនឯង មិនមាននរណានឹងជួយយើងបាននោះទេ” លោកជិតាវ បានបន្ថែមទៀតថា ជាមួយនឹងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលសិស្សានុសិស្សកំពុងកាន់នៅក្នុងដៃ មានសារសំខាន់ក្នុងការសិក្សាស្វែងយល់អំពីរបបខ្មែរក្រហម និងគួរចេះចែករំលែកដល់សមាជិកដទៃទៀតក្នុងក្រុមគ្រួសារ ។

បន្ទាប់ពីបញ្ចប់សុន្ទរកថា លោកជិតាវ បានអញ្ជើញទៅសម្ពោធពាក្យស្លោកដែលបានឆ្លាក់នៅលើផ្ទាំងថ្មម៉ាបដែលឈរនៅចន្លោះអគាររដ្ឋបាល និងអគារសិក្សា ។ ពាក្យស្លោកនេះឆ្លុះបញ្ចាំង និងលើកទឹកចិត្តសិស្សានុសិស្សឲ្យសិក្សាស្វែងយល់អំពីរបបកម្ពុជាប្រជាធិបតេយ្យ និងចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍ ព្រមទាំងចេះអត់ឱន និងជំរុញឲ្យមានការផ្សះផ្សាជាតិ ។

**ពាក្យស្លោកពីឃ្លានោះមានអត្ថន័យដូចតទៅ ៖**

**១)** និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឲ្យអត់ឱន អធ្យាស្រ័យគ្នា ។

២) រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។

ទន្ទឹមនឹងការដាក់សម្ពោធពាក្យស្លោកនេះ លោកជិតាវក៏បានចែកសៀវភៅ“ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)” ដល់សិស្សានុសិស្សដែលបានចូលរួមក្នុងកម្មវិធីព្រឹកនេះ ។

ក្រៅអំពីការសម្ពោធពាក្យស្លោក និងការចែកសៀវភៅអំណានដល់សិស្សានុសិស្ស ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម លោក សយ សែន ក៏បានចូលរួមចែករំលែកអំពីបទពិសោធន៍របស់លោកដែលជាជនរងគ្រោះនៃរបបខ្មែរក្រហមដល់សិស្សានុសិស្ស វិទ្យាល័យព្រៃល្វា ។ បើទោះបីជាការរំលឹកឡើងវិញនូវព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមធ្វើឲ្យលោកមានអារម្មណ៍ក្តុកក្តួល ក៏លោករីករាយនឹងចែករំលែកដល់សិស្សានុសិស្ស ដោយសារតែលោកគិតថា ការនិយាយប្រាប់ក្មេងជំនាន់ក្រោយអំពីរបបខ្មែរក្រហមមានសារសំខាន់សម្រាប់ក្មេងជំនាន់ក្រោយ ដើម្បីបានយល់ដឹងអំពីប្រវត្តិសាស្ត្ររបស់ប្រទេសជាតិខ្លួន ។ លោកសង្ឃឹមក្មេងជំនាន់ក្រោយនឹងបានដឹងអំពីរឿងរ៉ាវដែលបានកើតឡើង និងបានជះឥទ្ធិពលដល់សង្គមជាតិបច្ចុប្បន្ន ។

បើតាមលោក សយ សែន ស្រុកត្រាំកក់ស្ថិតនៅមិនឆ្ងាយប៉ុន្មានអំពីស្រុកព្រៃកប្បាសនោះទេ ។ ស្រុកត្រាំកក់បានធ្លាក់ចូលក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមតាំងពីមុនឆ្នាំ១៩៧៥ ។ មិនតែប៉ុណ្ណោះ ផ្ទះរបស់ តា ម៉ុក នៅបន្តសេសសល់មកដល់បច្ចុប្បន្នដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីសារមន្ទីរខេត្តតាកែវ ។ ខេត្តតាកែវគឺជាខេត្តដែលមានគុកសំខាន់មួយរបស់ខ្មែរក្រហមឈ្មោះថា គុកក្រាំងតាចាន់ ដែលអ្នកទោសជាច្រើនត្រូវបានសួរចម្លើយ និងសម្លាប់ ។ លោក សយ សែន គឺជាអ្នកទោសម្នាក់នៅគុកក្រាំងតាចាន់ ដែលលោកមិននឹកស្មានថា លោកអាចនឹងរស់រានមានជីវិតរហូតដល់សព្វថ្ងៃ ។

មិនតែប៉ុណ្ណោះ លោកបានចូលរួមដំណើរការស្វែងរកយុត្តិធម៌ ដោយបានចូលរួមឆ្លើយបំភ្លឺនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ លោកបានរម្លឹកដល់សិស្សានុសិស្សទាំងអស់ឲ្យចងចាំប្រវត្តិសាស្ត្រ និងពេញចិត្តនូវអ្វីដែលខ្លួនមាន ជាពិសេសគឺការអប់រំ ។ លោកបានប្រាប់ថា នៅក្នុងរបបខ្មែរក្រហមមិនមានសាលារៀន ឬការអប់រំនោះទេ ។ ផ្ទុយទៅវិញ មានតែរណ្តៅសាកសពសម្រាប់កប់អ្នកដែលបានស្លាប់តែប៉ុណ្ណោះ ។

មុននឹងបញ្ចប់កម្មវិធី សិស្សានុសិស្សបានលើកដៃសួរសំណួរជាច្រើនទៅកាន់ លោក ដេន ពន្សរ៉ាស៊ី និងលោកនាយករង វ៉ាន់ថាន់ពោធារ៉ា អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ សំណួរទាំងនោះរួមមាន តើរបបខ្មែរក្រហមកើតឡើងដោយរបៀបណា? តើខ្មែរក្រហមជានរណា? តើពាក្យ “អង្គការ” មានប្រភពមកពីណា?

ជាទីបញ្ចប់ យើងសង្កេតឃើញថាកម្មវិធីនេះបានចូលរួមចំណែកអប់រំ ដាស់តឿន និងលើកកម្ពស់ការយល់ដឹង និងការសិក្សារៀនសូត្ររបស់សិស្សានុសិស្សអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងបានជួយលើកទឹកចិត្តសិស្សានុសិស្សឲ្យចូលរួមកិច្ចការទប់ស្កាត់ ផ្សះផ្សា និងអត់ឱន ដែលជាកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា ។

**ស៊ីហ៊ិន ឌូ**

# រសាត់តាមខ្យល់

**(តចប់)**



ក្នុងឱកាសនោះ ពិសីបានណែនាំខ្ញុំឲ្យស្គាល់ "ស្រីរ័ត្ន" ដែលត្រូវជាបងប្អូនជីដូនមួយរបស់នាង ។ ស្រីរ័ត្ន ដែលមានអាយុ១៨ឆ្នាំ គំណាលគ្នានឹង ពិសី ដែរ មានសម្បុរស្រអែមស្រស់ សក់វែងខ្មៅរលោងប្រះស្មា រង្គង់មុខទ្រវែង ថ្គាមខ្ចា កែវភ្នែកមុតថ្លា ច្រមុះស្រួចសមនឹងបបូរមាត់ក្រហមស្ដើង ដៃទន្ទាល់ទាំងគូភ្លឺរលោង នាងមានចរិតយ៉ាងរួសរាយ ហើយនៅពេលដែលនាងនិយាយនាងមានសំដីយ៉ាងទន់ភ្លន់ជាមួយនឹងស្នាមញញឹមយ៉ាងសែនស្រស់ គន់មើលពុំឆ្អែតភ្នែក ។ ខ្ញុំចាប់អារម្មណ៍ទៅលើរូបនាង ហើយខ្ញុំជឿជាក់ថាមិនមែនមានតែរូបខ្ញុំម្នាក់ទេ ក្នុងពេលនោះដែលភ្ញាក់ផ្អើលនឹងសម្រស់ដ៏សែនស្អាតរបស់នាង ។

ថ្ងៃក្រោយបន្ទាប់មកទៀត ដែលជាញឹកញយខ្ញុំបានទទូចអង្វរ ពិសី ជួយយ៉ាងណាឲ្យខ្ញុំបានស្គាល់ស្រីរ័ត្ន ច្រើនជាងនេះថែមទៀត ។ ស្រីរ័ត្ន នាងជាកូនកំព្រា ជាកូនទោលតែមួយដែលម្ដាយនាងជាប្អូនស្រីបង្កើតរបស់ម្ដាយក្មេក អាឃ្មី ឪពុកនាងជាសាស្ត្រាចារ្យត្រូវបានសម្លាប់ក្នុងរបបខ្មែរក្រហម ។

ថ្ងៃមួយ អាឃ្មី បានយកសំបុត្រអញ្ជើញទៅមើលការសម្ដែងសិល្បៈយីកេរឿង "ទុំទាវ" ដែលសម្ដែងដោយក្រុមវិចិត្រសិល្បៈនៃក្រសួងឃោសនាការ និងវប្បធម៌មួយសន្លឹកមកឲ្យខ្ញុំដែលវាបានទទួលពីកន្លែងការសែតរបស់វា ដោយបានណាត់ជួបគ្នាល្ងាចនោះនៅសាលមហោស្រពទន្លេបាសាក់តែម្ដង ។

ពេលដែលខ្ញុំបានទៅដល់សាលមហោស្រព ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលខ្ញុំមិននឹកស្មានសោះថា ស្រីរ័ត្ន មានវត្តមានក្នុងឱកាសនោះដែរ ខ្ញុំសប្បាយរីករាយត្រេកអរក្នុងចិត្តយ៉ាងខ្លាំងពេលដែលបានជួបនាង ។ ល្ងាចនោះខ្ញុំមានសំណាងធំណាស់ដោយបានអង្គុយកៅអីជាប់នឹងនាងថែមទៀត ។

ក្នុងឱកាសដែលសិល្បៈកំពុងតែសម្ដែង សាលត្រូវបានពន្លត់ភ្លើងងងឹតឈឹងសល់តែកូនអំពូលតូចៗពណ៌ក្រហមព្រឿងៗ ខ្ញុំបានចោលភ្នែកលួចសម្លឹងមើលវង់ភក្ត្រពោរពេញទៅដោយមន្តស្នេហ៍របស់នាងជាញឹកញយ ។ ដល់ឃុតកំប្លែងដែលបានសម្ដែងដោយលោកគ្រូសាឃន និងលោកគ្រូប៉ោ ជាមួយនឹងទេពកោសល្យថ្នក់ដ៏ប៉ិនប្រសព្វអស្ចារ្យរបស់គាត់ទាំងពីរនាក់ ខ្ញុំឃើញ ស្រីរ័ត្ន ជាញឹកញយផ្ទុះសំណើចយ៉ាងរីករាយ ជួនកាលនាងក្រឡេកកមកប៉ះនឹងភ្នែកខ្ញុំដែលកំពុងតែអង្គុយរៀបបុករៀបពារក្បែរនាងយ៉ាងសុភាពរាបសារ ។ ក្នុងស្ថានភាពបែបនេះ ខ្ញុំបានរិះគិតតែម្នាក់ឯងថាៈ "ខ្ញុំត្រូវតែរកមធ្យោបាយយ៉ាងណាឲ្យបានស្គាល់នាងកាន់តែជិតស្និទ្ធថែមទៀត" ។

ខ្ញុំមានការភ្ញាក់ផ្អើលក្នុងចិត្តយ៉ាងខ្លាំង ដោយពេលខ្លះខ្ញុំបានជួបនាងនៅផ្ទះ អាឃ្មី នាងបានទទួលស្វាគមន៍ខ្ញុំ ដោយក្ដីនឹករលឹករីករាយរាក់ទាក់ ហើយមានឱកាសខ្លះទៀត នាងបានឈរនិយាយជជែកជាមួយខ្ញុំតែពីរនាក់ ដែលបានធ្វើឲ្យបេះដូងខ្ញុំញាប់ញ័ររំជើបរំជួលយ៉ាងខ្លាំង រហូតដល់ពេលខ្លះខ្ញុំរកនឹកមិនឃើញ មិនដឹងជាត្រូវនិយាយរឿងអីជាមួយនាង តែដោយចរិតដ៏រួសរាយស្រស់ស្រាយរបស់នាង ខ្ញុំបានខំប្រឹងរកនឹករឿងខ្លះមក និយាយឲ្យនាងសើច ។

ប្រមាណជិតមួយខែមកទៀត "ដោយនិស្ស័យរបស់យើងទាំងពីរ" ជាការពិតណាស់យើងទាំងពីរហាក់ដូចជាបានដឹងរៀងៗ

ខ្លួនថា ក្នុងជម្រៅបេះដូងយើងទាំងពីរកំពុងតែមានលាក់បង្កប់រឿងអាថ៌កំបាំងមួយដ៏សែនជ្រៅ ។ ក្រោយពីបានសម្រេចចិត្តដ៏ច្បាស់លាស់ ខ្ញុំនៅបានព្យាយាមបង្ហាញឲ្យនាងឃើញថា នៅក្បែរនាងជីវិតខ្ញុំហាក់ដូចជាបានទទួលនូវសេចក្តីសុខយ៉ាងខ្លាំង ខ្ញុំបាត់បង់អស់រលីងនូវភាពនឿយហត់ និងទុក្ខកង្វល់ផងទាំងពួង ខ្ញុំមិនដែលគិត មិនដែលនឹកនាដល់រឿងស្អីផ្សេងទៀតឡើយ ហើយខ្ញុំមិនចង់ឃ្លាតឆ្ងាយពីនាងទោះជាមួយវិនាទីក៏ដោយ ។

ទំនាក់ទំនងរវាងខ្ញុំ និងស្រីរ័ត្ន គឺជាទំនាក់ទំនងដែលពោរពេញទៅដោយភាពល្អបរិសុទ្ធ និងយ៉ាងថ្លៃថ្នូរ ។ ពេលខ្លះខ្ញុំដណ្តឹងសួរខ្លួនឯងថាៈ «ហេតុអីទៅទើបជាខ្ញុំបានមកជួបនឹងរូបនាង?» ដោយចៃដន្យ ឬក៏ជាព្រេងវាសនា? ជាច្រើនលើកច្រើនសា ខ្ញុំសាកល្បងត្រិះរិះដើម្បីរកនូវចម្លើយពិតប្រាកដមួយសម្រាប់ខ្លួនឯង តែចម្លើយនោះគឺខ្ញុំគ្រាន់តែបានដឹងថាៈ «នាងគឺជានារីតែម្នាក់គត់សម្រាប់បេះដូងខ្ញុំ» ហើយបេះគឺជាចម្លើយពិត ដែលបានផុសចេញពីក្រអៅបេះដូងដ៏បរិសុទ្ធរបស់ខ្ញុំ ។

ក្នុងបេះដូងខ្ញុំទន្ទេញតែពាក្យមួយម៉ាត់ដដែលថាៈ «ខ្ញុំនឹងរៀបការជាមួយនាង» ព្រោះនេះគឺជារឿងស្នេហ៍ដំបូងសម្រាប់ខ្ញុំជារឿងពិត ហើយខ្ញុំជឿថា រឿងរ៉ាវបែបដូចគ្នានេះហើយដែលមនុស្សគ្រប់រូបក្នុងលោកបានឲ្យឈ្មោះថា «ស្នេហា ស្នេហា» នោះ ។

ស្រីរ័ត្ន នាងធ្លាប់បានពោលប្រាប់ខ្ញុំថា ខ្ញុំគឺជាបុរសតែមួយគត់សម្រាប់បេះដូង និងជីវិតនាង ។ នាងនៅបានសំណូមពរថា អ្វីដែលនាងសង្ឃឹមប្រាថ្នាមកលើរូបខ្ញុំមានតែម្យ៉ាងគត់ គឺសូមកុំឲ្យខ្ញុំបំផ្លាញនូវសេចក្តីស្រឡាញ់របស់នាងតែប៉ុណ្ណោះ ។

សម្រាប់ខ្ញុំសំណូមពរនាងគឺជាការលះបង់ដ៏តូចមួយ លើសពីនេះទៅទៀត ខ្ញុំចង់បំពេញចិត្តនាងសព្វបែបយ៉ាងទាំងអស់ ។ យើងបានយល់ដល់ចិត្តថ្លើមគ្នាយ៉ាងច្បាស់ ហើយបើពុំមានឧបសគ្គមករារាំងទេ យើងទាំងពីរនាក់នឹងរៀបការជាមួយគ្នា ។ មានពេលខ្លះនាងនៅបានដេញដោលសួរខ្ញុំ និងសូមឲ្យខ្ញុំប្រាប់នាងតាមត្រង់កុំលាក់លៀមឲ្យសោះថាៈ «តើបេះដូងខ្ញុំធ្លាប់បានប្រគល់ឲ្យនារីណាផ្សេងទៀតដែរឬទេ?» ខ្ញុំបានឆ្លើយទៅនាងវិញភ្លាមថាៈ «អត់ទេអត់ទាល់តែសោះ បើមិនជឿបងហ៊ានស្បថ» ស្រីរ័ត្ន អស់សំណើចនឹងសំដីខ្ញុំ «ទឹកហូរមិនដែលហត់ ប្រុសហារឡើងស្បថមិនគួរឲ្យជឿសោះ» ។

រឿងស្នេហារវាងខ្ញុំ និងស្រីរ័ត្ន គ្មានអ្វីជាអាថ៌កំបាំងឡើយជាពិសេសចំពោះឪពុកម្តាយក្មេកអាឃ្មី និងក្រុមគ្រួសារវា ។ ពិសីបានអបអរសាទរចំពោះសេចក្តីសម្រេចចិត្តរបស់ខ្ញុំនេះ ហើយខ្ញុំក៏បាននិយាយជាមួយ ពីសី និងអាឃ្មី ដើម្បីរកឱកាសណាមួយជួបជាមួយឪពុកម្តាយក្មេកវា សូមឲ្យគាត់ជួយធ្វើជាចាស់ទុំចូលស្តីដណ្តឹងស្រីរដ្ឋឲ្យឆាប់យ៉ាងណាដែលអាចឆាប់ទៅបាន ។

ល្ងាចថ្ងៃមួយ ខ្ញុំបានទៅចូលរួមញ៉ាំបាយល្ងាចជាមួយក្រុមគ្រួសារអាឃ្មី ដោយអាក្តំ ប្អូនថ្លៃវាទើបតែប្រឡងបាក់ឌុបជាប់ថ្មីៗដែលនាំមកនូវភាពយ៉ាងសប្បាយរីករាយសម្រាប់គ្រួសារទាំងមូល ។ ពិសី អាឃ្មី បានគិតគ្នាជាមួយខ្ញុំស្រេចហើយថា ត្រូវឆ្លៀតក្នុងឱកាសដ៏ល្អនេះឲ្យបាន ។

អង្គុយជុំគ្នានឹងតុបាយ លើកម្ហូបដាក់លើតុបណ្តើរម្តាយក្មេកអាឃ្មី និយាយលេងពីនេះពីនោះបណ្តើរ ពិសេសអាក្តំ កូនកម្លោះរបស់គាត់ដែលបានខិតខំរៀនសូត្រប្រឡងបាក់ឌុបជាប់ដោយបាននិទ្ទេសយ៉ាងល្អ ។ គាត់និយាយសរសើរអាក្តំ មិនដាច់ពីមាត់ ។

ពេលហូបបាយឪពុកក្មេកអាឃ្មី ក៏បានសួរទៅអាក្តំថាៈ «ប្រឡងជាប់បាក់ឌុបហើយ តើកូនចង់ធ្វើអីដែរ?» អាក្តំ ក្រឡេកមើលមក ពិសី ហើយបានឆ្លើយថាៈ «បាទពុក ខ្ញុំចង់ទៅរៀនស្រុកគេ» ។

សម្រាប់រូបខ្ញុំ ខ្ញុំមានការពេញចិត្តយ៉ាងខ្លាំងចំពោះជម្រើសរបស់អាក្តំនេះ ។ វារៀនពូកែប្រឡងបាននិទ្ទេសល្អ ឪពុកវាជាបក្សជនហើយធ្វើការនៅក្រសួងអាហាររូបករណ៍ស្រាប់ គ្មានរឿងអីលំបាកសោះ ព្រោះកន្លងមកអ្នកធ្វើការនៅក្រសួងអប់រំបានប្រើប្រាស់ឱកាសបញ្ជូនកូនចៅទៅរៀននៅបរទេសជាបន្តបន្ទាប់រាប់ពុំឈ្នះ ហើយមានអ្នកខ្លះទៀតមានទុយយោបក្សពួកធំឆ្លៀតបានសឹងតែទាំងពូជ ។

ចម្លើយរបស់អាក្តំ អាចនឹងខុសពីបំណងរបស់គាត់ ។ ស្ងៀមមួយស្របក់គាត់ក៏បានតបទៅអាក្តំវិញថាៈ «បើតាមចិត្តពុក ចង់ឲ្យកូនបម្រើក្នុងជួរកងទ័ពវិញ» ។ ពេលនោះម៉ែក្មេកអាឃ្មី សឹងតែធ្លាក់ស្លាបព្រាបាយពីដៃ គ្រាន់តែបានឮប្តីគាត់និយាយដូច្នេះ គាត់បានតបទៅប្តីគាត់ភ្លាមវិញថាៈ «ម៉េចឪវាឯងចង់បញ្ជូនកូនប្រុសខ្ញុំឲ្យ

ទៅផាប់ជិនួសអ្នកណា? ទៅច្បាំងដើម្បីអ្នកណា? ម៉េចឪវាឯងមិនបើកភ្នែកមើលគេឯងជុំវិញខ្លួមផង កុំគិតតែពីគោលជំហរល្អ ស្មោះត្រង់ត្រឹមត្រូវម៉េចខ្លាចមិនបានធ្វើជាគំរូគេ? បើឪអាក្តុំឯងខ្លាចខូចគោលជំហរខ្លាចគេថា មិនស្មោះត្រង់ លះបង់មិនទាន់បានខ្ពស់ដល់កម្រិតនោះ រឿងអាក្តុំចង់ទៅរៀនស្រុកគេ បើឪវាឯងមិនគិតគូរទុក ឲ្យម៉ែអាក្តុំគិតវិញ» ។

ម៉ែក្មេកអាឃ្មី និយាយមិនខុសទេ ព្រោះសឹងតែគ្រប់ក្រសួងមន្ទីរទាំងអស់ អ្នកដែលស្មោះត្រង់ត្រឹមត្រូវមានដែរ តែមិនសម្បូរដូចអ្នកឱកាសនិយមទេ ដើម្បីឲ្យបក្សទុកចិត្ត គេបេះដាក់ខ្លួនធ្វើគំរូមហាជនតាំងពីការរស់នៅ និងការស្លៀកពាក់ឡើងទៅ ។

ខោអាវដែលថ្មី ពួកគេស្អប់ខ្ពើមមិនស្លៀកពាក់ទេ ពួកគេស្លៀកពាក់តែខោអាវចាស់ៗ បើមានបំណះមុខក្រោយទៀតនោះរឹតតែត្រូវប៉ាន់ ។ មានអ្នកខ្លះទៀតលះបង់ដល់កម្រិតខ្ពស់មែនទែន រហូតបើប្រពន្ធមិនអ៊ុតឲ្យទេពាក់មកធ្វើការទាំង «ខ្ទុច» តែម្តង ។ ពួកគេស្លៀកពាក់យកគំរូតាមជំនាញការវៀតណាមមកពីហាណូយ ។

ខ្ញុំធ្លាប់បានឃើញអ្នកធ្វើការជាមួយខ្ញុំ ដែលកំពុងតែកសាងខ្លួន ពួកទាំងនោះពូកែលាក់ប្រវត្តិរូបណាស់ ហើយបើសិនជាមានបងប្អូនរស់នៅឯបរទេស បែកគ្នាជប់ម្ភៃឆ្នាំខំស្កាត់មកលេងទោះជាបងប្អូននឹករលឹកយ៉ាងណា ក៏មិនងាយបានជួបដែរ ។ បងប្អូនមកពីបរទេសច្រើនណាស់ដែលមានការខកចិត្ត អ្នកខ្លះបានជួបដែរ តែទ្វារផ្ទះត្រូវបិទយ៉ាងជិត អ្នកខ្លះត្រូវបានគេឆ្លើយប្រាប់តាមត្រង់ថា «ខ្លាចខូចប្រវត្តិរូប» មិនជួបទេ ។

ពួកអ្នកឱកាសនិយមទាំងនោះពូតែរហូតយើងមើលទៅឃើញថា«ស្មោះត្រង់» មែនទែន ហើយប៉ុនសម្តែងល្ខោន និងប៉ុនយកចិត្តផ្គាប់ផ្គន់ពួកជំនាញការវៀតណាមដែលជាចៅហ្វាយនាយខ្លាំងណាស់ ។ ចំណុចមួយទៀតដែលគួរឲ្យគោរព គឺពួកទាំងនោះពូកែបត់បែន ពិសេសនៅមុនពេលដែលពួកជំនាញការវៀតណាមតាមក្រសួងនានាដកចេញទៅ ។ មានអ្នកស្លូតត្រង់ត្រឹមត្រូវច្រើនណាស់ដែលត្រូវបានទទួលរងគ្រោះដោយសារពួកអ្នកឱកាសនិយមទាំងនោះ ។ ដោយប៉ុនប្រសប់ក្នុងការបត់បែន ខ្ញុំធ្លាប់បានគិតថាពួកនោះមិនមែនស្មោះត្រង់តែមួយ របបនេះទេ គឺពួកនោះចេះធ្វើស្មោះធ្វើត្រង់គ្រប់ជំនាន់ ចាំមើលដល់ពេលស្រុកទេសប្តូររបបឪក្មេកអាឃ្មីកុំសង្ស័យ ច្រៀងបទ «សូមពួកទេព្តា» បានពិរោះដូចពួកគេឲ្យសោះ ។

ដល់ពេលបក្សទុកចិត្តទុកថ្លើមទៅ ពួកគេចាប់ផ្តើមបានទទួលផលប្រយោជន៍ពីបក្សមកវិញ គឺឃើញភ្លាមៗ យ៉ាងទាន់ហន់មិនចាំបាច់ជាតិក្រោយដូចធ្វើបុណ្យកឋិនទេ ខ្ញុំក៏បានឃើញយ៉ាងដូច្នោះដែរ ព្រោះគ្មានរបបណាដែលល្អជាងរបបនេះទៀតទេ បើបក្សទុកចិត្តបក្សឲ្យបុណ្យឲ្យសក្តិ បក្សដោះស្រាយគោលនយោបាយមានវីឡាឲ្យនៅ របបវីឡាឲ្យលក់ មានរបបឡានឲ្យជិះ និងរបបសាំងឲ្យចាក់ ។ មានអ្នកខ្លះបក្សនៅបានយកចិត្តទុកដាក់គិតគូរហូតដល់រៀបការប្រពន្ធឲ្យទៀត ។ល ។

ពេលញ៉ាំបាយនៅផ្ទះអាឃ្មី ល្ងាចនោះ បរិយាកាសប្រែជាអាប់អួរមែនទែន រកតែខ្ញុំបង្កើបរឿងស្រីរ័ត្នក៏មិនកើត នៅអង្គុយស្តាប់ម៉ែក្មេកអាឃ្មី «សូឡូ» យ៉ាងចាស់ដៃម្នាក់ៗស្ងាត់មាត់ដូចគេចុក ។ មុនពេលដែលគាត់បានក្រោកចេញពីកៅអីទៅ គាត់នៅបានសួរបង្កើយទៅប្តីគាត់ថាៈ «ម៉េចឪវាឯងនឹងបានរីកមុខរីកមាត់ពេលដែលកូនខ្ញុំត្រូវបានគេពាក់កម្រងផ្កាហើយហែតាមដងផ្លូវយ៉ាងគគ្រឹកគគ្រេងនោះ? រីកតែឪអាក្តុំឯងចុះ ខ្ញុំមិនរីកជាមួយទេ ជីវិតកូនខ្ញុំអីក៏ថោកម្ល៉េះ?» ។

ពីផីភ្ជាប់ពាក្យរវាងខ្ញុំ និងស្រីរ័ត្ន បានប្រព្រឹត្តទៅយ៉ាងសមរម្យ ដោយមានការជួយជ្រោមជ្រែងពីប្តីប្រពន្ធអាឃ្មី និងឪពុកម្តាយក្មេកវាយ៉ាងអស់ពីចិត្តពីថ្លើម ។ ក្រោយពីភ្ជាប់ពាក្យរួច ខ្ញុំមានសិទ្ធិដើរទៅណាមកណាតែពីរនាក់ ដោយមិនញញើតញញើមប្រខ្លាចមិនសមរម្យនឹងភ្នែកអ្នកដទៃទៀតឡើយ ។ យើងបានសាងអនុស្សាវរីយ៍រួមគ្នាជាច្រើន ហើយបានដឹងច្បាស់ក្នុងចិត្តថាយើងមិនអាចរស់នៅដោយគ្មានគ្នាបានឡើយ ។ យើងទាំងពីរទន្ទឹងរង់ចាំទាំងចិត្តអន្ទះសារស្រមៃដល់ថ្ងៃរៀបការ ដែលនឹងមកដល់នាពេលខាងមុខ ។

ថ្ងៃមួយខ្ញុំបានទទួលការចាត់តាំងពីកន្លែងធ្វើការ ឲ្យចុះទៅបំពេញបេសកម្មការងារមួយនៅខេត្តកំពង់ចាម សម្រាប់រយៈពេលមួយសប្តាហ៍ ។ នេះជាលើកដំបូងហើយ ដែលខ្ញុំត្រូវឃ្លាតឆ្ងាយពីនាងមួយសប្តាហ៍យូរណាស់សម្រាប់រូបខ្ញុំ ខ្ញុំមានសេចក្តីរលឹកអាល័យអាល័យដល់រូបនាងយ៉ាងខ្លាំង ។

រថយន្តនីវ៉ាផលិតនៅសហភាពសូវៀតពណ៌ប្រផេះមួយគ្រឿងដែលមានតែខ្ញុំ និងអ្នកបើកបរកំពុងបោះពួយទៅមុខក្នុងល្បឿនយ៉ាងលឿនតាមបណ្ដោយផ្លូវជាតិឆ្ពោះទៅកាន់ទីរួមខេត្តកំពង់ចាម ។ ខ្ញុំបោលភ្នែកសម្លឹងមើលទេសភាពតាមដងផ្លូវ វាលស្រែសន្ធឹងលាស់ពណ៌បៃតងខ្ចីជាប់ទៅនឹងជើងព្រៃនាមឆ្ងាយដាច់កន្ទុយភ្នែក ពេលដែលខ្ញុំកំពុងតែលង់អារម្មណ៍ជក់ចិត្តនឹងទេសភាពជុំវិញដ៏ត្រកាល ស្រាប់តែខ្ញុំបានឮសម្រែកហ្រាំងឡានដែលអ្នកបើកបរកំពុងតែជាន់យ៉ាងខ្លាំងបន្លឺសកង់យ៉ាងវែង ហើយក្នុងវិនាទីជាមួយគ្នានោះ ខ្ញុំបានឮសូរកញ្ចក់ឡានបែកលាន់សូរគ្រោវ ។

មុននេះបន្តិច នៅក្នុងកែវភ្នែកទាំងគូដ៏ស្រវាំងរបស់ខ្ញុំ ខ្ញុំហាក់នៅចាំបានថា មានរថយន្តមួយគ្រឿងបត់ឆ្វេងកាត់ថ្នល់ហើយជ្រុលមកបុករថយន្តដែលខ្ញុំកំពុងជិះទាំងកម្រោលបណ្ដាលឲ្យក្រឡាប់មួយរំពេច ។ នេះគឺជា គ្រោះថ្នាក់ដ៏ចៃដន្យដែលវាហាក់ដូចជាសុបិនដ៏សែនអាក្រក់មួយទាំងកណ្ដាលថ្ងៃត្រង់សម្រាប់រូបខ្ញុំ ។

ដងខ្លួនខ្ញុំទាំងមូលត្រូវរងរបួសដោយមុតអំបែងកញ្ចក់ជាច្រើនកន្លែង ជើងឆ្វេងរបស់ខ្ញុំមិនអាចកម្រើកបានឡើយ មុនពេលដែលខ្ញុំត្រូវបានសន្លប់បាត់ស្មារតីទៅ ខ្ញុំនៅចាំមានមនុស្សច្រើនកំពុងតែព្យាយាមជួយសង្គ្រោះខ្ញុំ ។ បន្ទាប់ពីនោះមក ខ្ញុំលែងដឹងអ្វីទាំងអស់ពេលដែលខ្ញុំដឹងខ្លួនឡើងវិញ គឺខ្ញុំកំពុងតែស្ថិតនៅក្នុងមន្ទីរពេទ្យដែលពេលនោះជើងឆ្វេង និងដៃឆ្វេងរបស់ខ្ញុំរងរបួសជាទម្ងន់ ។

លោកវេជ្ជបណ្ឌិតដែលមកព្យាបាលខ្ញុំ បានមានប្រសាសន៍ថា គឺជាសំណាងធំណាស់ដែលខ្ញុំនៅរស់ជីវិត ។ លោកគ្រូពេទ្យបានធ្វើការវះកាត់ជើងឆ្វេងរបស់ខ្ញុំដល់ទៅពីរដង យកចេញនូវកម្ទេចឆ្អឹងបែកបាក់ និងបំណែកខ្ទេចខ្ទាំផ្សេងទៀត ។

តាំងពីថ្ងៃដំបូងដែលខ្ញុំបានមកដល់មន្ទីរពេទ្យ ពេលដឹងខ្លួនឡើង ខ្ញុំបានឃើញស្រីរ័ត្ន កំពុងតែអង្គុយយំនៅចុងជើងខ្ញុំ ម្ដាយនាងគាត់ភ័យតក់ស្លុតយ៉ាងខ្លាំងពេលដែលបានឃើញរូបខ្ញុំស្ថិតក្នុងសភាពបែបនេះ ។

ស្រីរ័ត្ន និងម្ដាយនាងបានផ្លាស់ប្ដូរគ្នាទៅមកកំដរខ្ញុំទាំងយប់ទាំងថ្ងៃលើសពីនេះទៅទៀតគាត់នៅបានចំណាយប្រាក់កាសយ៉ាងច្រើនសម្រាប់ថ្លៃថ្នាំសង្កូវព្យាបាលរូបខ្ញុំទៀតផង ចំពោះរូបខ្ញុំមិនដឹងជារកពាក្យអ្វីមកនិយាយឲ្យសមនឹងសន្ដានចិត្តដ៏ល្អរបស់គាត់បានឡើយ មានតែម្រាមដៃដប់លើកសំពះអរគុណគាត់ទាំងទឹកភ្នែក ។

ចំណែកពិសី អាឃ្មី ឪពុកម្ដាយក្មេកវាក៏បានរួមចំណែកខ្វាយខ្វល់នឹងរូបខ្ញុំយ៉ាងខ្លាំង ដោយបានមកអើតមើលខ្ញុំនៅមន្ទីរពេទ្យជាញឹកញយ ។ អាឃ្មី នៅបាននិយាយលួងលោមខ្ញុំ កុំឲ្យខ្ញុំអស់សង្ឃឹមឲ្យសោះ ស្រីរ័ត្ន ក៏ដូច្នោះដែរ នាងបានបញ្ជាក់ដោយវាចារយ៉ាងផ្អែមល្ហែមមកកាន់ខ្ញុំថា ទោះជាខ្ញុំត្រូវបានធ្លាក់ខ្លួនទៅជាមនុស្សពិការក៏ដោយ ក៏នាងនៅតែស្រឡាញ់នៅតែអាណិត នៅតែទទួលរៀបការជាមួយខ្ញុំដដែល ដល់ពេលខ្ញុំបានជាសះស្បើយយើងនឹងរៀបការជាមួយគ្នា ។

ប្រមាណជិតមួយខែក្រោយមក ខ្ញុំអាចប្រែខ្លួន និងក្រោកអង្គុយបាន តែដោយលំបាក ដែលពេលខ្លះត្រូវការជំនួយពីស្រីរ័ត្នផង ។ ជារឿយៗខ្ញុំបានសុំលោកគ្រូពេទ្យត្រឡប់ទៅផ្ទះវិញ តែត្រូវបានគាត់បដិសេធ ព្រោះគាត់ព្រួយបារម្ភខ្លាចលទ្ធភាពនៃការថែទាំខ្ញុំមិនបានសមស្របទៅតាមលក្ខណៈពេទ្យ តែដោយនៅពេទ្យយូរ ខ្ញុំធុញថប់ខ្លាំងពេក ខ្ញុំនៅតែទទូចសុំហើយសុំទៀត ។

គ្រូពេទ្យបានឲ្យខ្ញុំរៀនដើរដោយទប់ខ្លួននឹងឈើច្រត់ទាំងសងខាង ថ្ងៃមួយខ្ញុំត្រេកអរយ៉ាងខ្លាំងនៅពេលដែលគាត់បានប្រាប់ខ្ញុំថាៈ “បានខ្ញុំអនុញ្ញាតឲ្យទៅផ្ទះ” ។

ខ្ញុំបានត្រឡប់មកសម្រាកព្យាបាលនៅនឹងផ្ទះស្រីរ័ត្ន ក្រៅពីគ្រួសារនាង ខ្ញុំពុំមានអ្នកណាផ្សេងជាទីពឹងឡើយ ។ ថ្ងៃមួយម្ដាយស្រីរ័ត្ន និងឪពុកម្ដាយក្មេកអាឃ្មី បានពិគ្រោះគ្នារកមធ្យោបាយថ្មីដើម្បីព្យាបាលរូបខ្ញុំឲ្យបានឆាប់ជា ខ្ញុំឮពួកគាត់និយាយថា គួរតែរកគ្រូខ្មែរមកព្យាបាលវិញម្ដង ។

បីថ្ងៃក្រោយមក លោកគ្រូដែលមានចំណាស់ជិត៦០ឆ្នាំរាងស្គមបន្តិចឈ្មោះ “សឺ” បានមកព្យាបាលខ្ញុំដល់ផ្ទះជារៀងរាល់ព្រឹក ។ លោកគ្រូព្យាបាលជើងឆ្វេងខ្ញុំតាមរបៀបខ្មែរបុរាណសុទ្ធសាធជាមួយនឹងថ្នាំ ដែលគាត់បានផ្សំពីឫសឈើជាច្រើនមុខលាយសម្រាប់ស្អំ និងរឹត គាត់នៅបានខ្នះកាយសរសៃជើងដោយម្រាមដៃដ៏រឹងរបស់គាត់ ដែលពេលខ្លះខ្ញុំទ្រាំឈឺសឹងតែពុំបាន គាត់ថាធ្វើដូច្នេះទាន់សរសៃវានៅក្រាប និងដើម្បីឲ្យសរសៃរស់ជីវិតឡើងវិញ ។

ពេលវេលាជិតមួយខែបានកន្លងផុតទៅ ម្នាក់ៗហាក់ដូចជាគ្មានសង្ឃឹមថា ខ្ញុំនឹងបានគ្រាន់បើជាងកាលពីពេលចេញពីមន្ទីរពេទ្យ

ឡើយ ព្រោះរូបខ្ញុំហាក់ដូចជាកំពុងតែស្ថិតក្នុងស្ថានភាពដដែល ។

ប៉ុន្តែលោកគ្រូនៅបានជួយព្យាបាលខ្ញុំដោយក្តីអំណត់បំផុត គាត់បង្កើនការផ្ចិតផ្ចង់ស្តោះកាន់តែញាប់ជាមួយទឹកមាត់ស្វាដ៏ត្រជាក់ដែលគាត់បានស្តោះព្រួសមកលើជើងខ្ញុំ ។

ថ្ងៃមួយសម្រាប់ពួកយើងទាំងអស់គ្នា វាជាការភ្ញាក់ផ្អើលមួយយ៉ាងសម្បើមអស្ចារ្យលាយឡំនឹងក្តីរំភើបរីករាយឥតឧបមា វាប្រៀបបានទៅនឹងពន្លឺដ៏ចិញ្ចាចចិញ្ចែងមួយបន្ទាប់ពីភាពងងឹតសូន្យសុងមួយរយៈកាលដ៏យូរកន្លងមកនេះ ។

ខ្ញុំស្រក់ទឹកភ្នែកទាំងមិនដឹងខ្លួន «ជើងឆ្វេងខ្ញុំអាចកម្រើកបាន» ដោយក្តីរំភើបត្រេកអរ ទឹកភ្នែកខ្ញុំស្រក់លើខ្នងដៃលោកគ្រូពេលដែលគាត់កំពុងតែត្រកងខ្ញុំ ។

ដោយក្តីរំភើបស្រីរ័ត្ន បានស្ទុះស្រវាឱបខ្ញុំនាងពោលដោយចិត្តត្រេកអរ «បងត្រូវតែរៀនដើរ...បងត្រូវតែរៀនដើរក្នុងពេលឆាប់ៗនេះ» ។

លោកគ្រូនៅបានព្យាយាមបង្ហាត់ឲ្យខ្ញុំចេះការពារខ្លួនឯងដោយដំបូងត្រូវរៀនដើរសសៀរៗទប់នឹងជញ្ជាំងទប់ខ្លួនតោងនឹងបង្កាន់ដៃជាដើម ។ ដៃឆ្វេងរបស់ខ្ញុំអាចធ្វើចលនាបានធម្មតា តែចំណែកជើងឆ្វេងរបស់ខ្ញុំវិញដោយ ត្រូវរបួសធ្ងន់ពេក ចាប់ពីគល់ភ្លៅទៅត្រូវស៊ិតតូចបន្តិច កម្រើកបានតែដើម្បីបោះជំហានទៅមុខឲ្យបានដូចធម្មតា ខ្ញុំត្រូវការឈើច្រត់មួយជាជំនួយ ។

ថ្ងៃរៀបមង្គលការរបស់ខ្ញុំ និងស្រីរ័ត្ន មានភ្ញៀវជាបងប្អូននិងមិត្តភក្តិបានមកចូលរួមយ៉ាងច្រើនកុះករ ។ ម្នាក់ៗនឹកសរសើរសំណាងខ្ញុំគ្រប់ៗគ្នា ហើយអ្នកខ្លះទៀតនឹកកោតស្ញប់ស្ញែងដល់សន្តានចិត្តដ៏ល្អបរិសុទ្ធដល់ភក្តីភាពតែមួយគត់ក្នុងលោករបស់ស្រីរ័ត្នដែលនៅតែសុខចិត្តទទួលរៀបការជាមួយខ្ញុំជាមនុស្សពិការធ្វើជាប្តីនាងដដែល ។

ក្នុងសម្លៀកបំពាក់ «ខោអាវធំ» ពាក់ផ្កា ខ្ញុំឈរទទួលភ្ញៀវទន្ទឹមគ្នានឹងស្រីរដ្ឋក្នុងភាពយ៉ាងសប្បាយរីករាយ ដោយផ្អែកឈើច្រត់របស់ខ្ញុំទុកទៅម្ខាង ។ ខ្ញុំឈរមិនសូវបានយូរប៉ុន្មានទេ ពេលស្បៀយ ភ្លៀវបន្តិចខ្ញុំអង្គុយ ដោយប្រការនេះហើយដែលពេលនោះខ្ញុំត្រូវក្រោកអង្គុយៗក្រោកជាញឹកញយ ។

ពេលអុជបារីជូនភ្ញៀវ ខ្ញុំត្រូវប្រើឈើច្រត់ជាចាំបាច់ ស្រីរ័ត្នឈរញញឹមក្បែរខ្ញុំ នាងញញឹមជាប់មិនដាច់ ដៃទាំងពីរលើកសំពះទទួលពរសព្ទសាធុការពីភ្ញៀវប្រុសស្រីដោយសោមនស្សរីករាយ ។ ក្រោយពេលរៀបការរួច ស្រីរ័ត្នបានចូលធ្វើការនៅធនាគាររដ្ឋធានីភ្នំពេញ ។ នៅផ្ទះខ្ញុំចេះតែធ្វើនេះធ្វើនោះពុំឈប់ឈរ ទោះជា ស្រីរ័ត្នហាមមិនឲ្យខ្ញុំធ្វើអីក៏ដោយ ខ្ញុំនៅបានធ្វើការងារជំនួសប្រពន្ធខ្ញុំដូចជាបោសសំអាត ជូតផ្ទះ ដាំស្ល បោកគក់ខោអាវជាដើម ខ្ញុំមានការខ្មាស់ខ្វល់ក្នុងចិត្តយ៉ាងខ្លាំងព្រោះដោយសារតែរូបខ្ញុំម្នាក់នាំឲ្យគេលំបាកពេញមួយផ្ទះ ។

ជារឿយៗនាងតែងអង្វរខ្ញុំ សូមកុំឲ្យធ្វើកិច្ចការទាំងអស់នោះអី នាងសុខចិត្តរ៉ាប់រងទាំងអស់ តែសម្រាប់ខ្ញុំពេញចិត្តនឹងជួយនាង ព្រោះនាងធ្វើការពេញមួយថ្ងៃ ពេលមកដល់ផ្ទះវិញ នៅមានកិច្ចការផ្ទះរាប់រយជំពូកទៀត ។

តាំងពីធ្លាក់ខ្លួនពិការមក ខ្ញុំកម្រនឹងដើរទៅណាមកណាណាស់ពោលគឺដើម្បីសុវត្ថិភាពខ្លួនឯង ព្រោះនៅទីក្រុងភ្នំពេញស្ទើរតែគ្រប់ច្រកល្ហកទាំងអស់ មានមនុស្សពិការបាត់បង់កាយសម្បទា ដោយសារសង្គ្រាមច្រើនណាស់ ដែលត្រូវបានគេបោះបង់ចោល ហើយកំពុងតែរស់នៅតាមចិញ្ចើមថ្នល់ សំយ៉ាបផ្ទះតែលតោលរសាត់អណ្តែតដូចចក គ្មានអ្វីជាទីពឹង គ្មានការធានា ដើរសុំទានពីកន្លែងមួយទៅកន្លែងមួយ និងតាមទីផ្សារដើម្បីចិញ្ចឹមជីវិត ។

មានជនពិការខ្លះមានអតីតភាពជាយុទ្ធជនសមរភូមិមុខដាច់ដៃដាច់ជើង ហើយមានវ័យក្មេងៗនៅឡើយ ខូចចិត្តប្រែទៅជាមនុស្សយ៉ាងកាចសាហាវគួរឲ្យខ្លាច ពួកគេលែងខ្លាចអាជ្ញាធរ លែងខ្លាចច្បាប់ខ្លាចទម្លាប់អីទាំងអស់ ពេលសុំទានមិនបានក្រពុល់មុខស្រែកសម្លុតគំរាមកំហែងតាមតូបលក់អីវ៉ាន់ ដែលធ្វើឲ្យសង្គម ជាពិសេសអ្នកផ្សារស្អប់ខ្ពើមមើលងាយមើលថោកយ៉ាងខ្លាំង ។

ថ្ងៃខ្លះមានជនពិការដើរសុំទានតាមទីផ្សារច្រើនពេក អ្នកផ្សាររកតែលក់ដូរស៊ីងតែមិនកើត ។ អ្នកដែលមានចិត្តបុណ្យ ចិត្តធ្ងន់ក៏ចេះតែធ្វើទានបន្តិចបន្តួចជាហូរហែទៅ អ្នកខ្លះទៀតមិនត្រឹមតែមិនធ្វើទានទេ ថែមទាំងជេរស្តីឲ្យគ្នាថែមទៀត ។

ខ្ញុំតែងតែស្លៀកពាក់យ៉ាងសមរម្យ និងមានពេលខ្លះខ្ញុំកាន់សៀវភៅមួយក្បាលផងមុនពេលខ្ញុំចេញដំណើរពីផ្ទះទៅផ្សារ ។ ថ្ងៃមួយនៅកណ្តាលផ្សារអូឡាំពិកដែលស្ថិតនៅមិនឆ្ងាយប្រមាណ

ពីផ្ទះ ពេលខ្ញុំកំពុងតែបោះជំហានជាមួយនឹងឈើច្រត់តាមបណ្ដោយផ្លូវតូបលក់ក្រណាត់ ដើរមកដល់មុខតូបមួយគ្រាន់តែបានឮស្នូរឈើច្រត់របស់ខ្ញុំ «កុប...កុប...» ស្រាប់តែម្ចាស់តូបបានពួយខ្ញុំយ៉ាងឥតសំចៃមាត់ «យី...ថ្ងៃនេះ អាពួកកំបាក់សំបុតអស់នេះអីក៏ ខ្វែងខ្វាត់សម្បើមម្ល៉េះ?» ។

ភ្លាមនោះគ្រាន់តែបានក្រឡេកឃើញខ្ញុំ ដោយទឹកមុខភ្ញាក់ផ្អើល គាត់បានសុំទោសខ្ញុំយ៉ាងរួសរាន់ ។ ដោយរូបខ្ញុំធ្លាក់ខ្លួនពិការព្រោះការងារ ខ្ញុំនៅបានទទួលប្រាក់ខែម្ដងៗ ខ្ញុំមិនសូវបានទទួលពាក្យសំដីសមរម្យ ពីអ្នកធ្វើការនៅការិយាល័យគណនេយ្យ និងចាត់តាំងឡើយ ។ ពេលខ្លះ ស្រីរ័ត្ន មានវត្តមានទៅបើកប្រាក់ខែជំនួសខ្ញុំ ក្រោយមក ស្រីរ័ត្ន លែងហ៊ានទៅបើកទៀត ព្រោះមុននឹងបានទទួលប្រាក់ខែ៣០០រៀលនោះ ស្រីរ័ត្ន ត្រូវបានគេសួរនាំដេញដោលយ៉ាងច្រើន ។

មានថ្ងៃមួយនោះនៅនឹងការិយាល័យគណនេយ្យ ស្រាប់តែខ្ញុំបានជួបប្រធាននាយកដ្ឋានខ្ញុំដោយចៃដន្យ គាត់មានអតីតភាពជាប៉េអឹម (លាក់ប្រវត្តិរូបហើយខំប្រឹងកសាងខ្លួនរហូតបានចូលជាបក្សជន) ខ្ញុំបានសម្ដែងការគួរសមចំពោះគាត់ គាត់មិនបានសួរសុខទុក្ខខ្ញុំមួយម៉ាត់ឡើយ ប៉ុន្តែជាមួយនឹងក្រសែភ្នែកដ៏គ្មានសុជីវធម៌របស់គាត់ដែលកំពុងតែសម្លឹងមើលមកខ្ញុំតាំងពីក្បាលរហូតដល់ចុងជើងសាចុះសាឡើង ខ្ញុំនៅបានឮគាត់និយាយមកកាន់ខ្ញុំថា ៖ «ណ្ហើយ...បើពិបាកពេក ដាក់ពាក្យសុំឈប់ពីការងារទៅ អញស៊ីញេឲ្យអ្ហែងភ្លាម...» ។

តាំងពីយូរណាស់មកហើយដែលខ្ញុំខ្លួនឯងតែងតែធ្លាប់បានគិតថាៈ «រស់នៅជាមនុស្សក្នុងលោក ធ្វើយ៉ាងណាជៀសឲ្យផុតពីការមើលងាយមើលថោកពីមនុស្សដូចគ្នា» តែក្នុងស្ថានភាពបែបនេះ រូបខ្ញុំពិតជាជៀសមិនរួចឡើយ ។

ខ្ញុំចង់រកការងារធ្វើជាថ្មីបង្រៀនសិស្ស ឬជួយបង្រៀនភាសាអង់គ្លេសដល់ជនពិការដូចគ្នា ខ្ញុំត្រៀមខ្លួនជាស្រេចនឹងធ្វើអ្វីៗសព្វបែបយ៉ាងទាំងអស់ ដើម្បីបានរួមចំណែកបម្រើសង្គមជាតិ ទោះជាក្នុងកាលៈទេសៈណាក៏ ដោយឲ្យតែសង្គមនៅត្រូវការរូបខ្ញុំ ។

រាល់ទិវារាត្រី ខ្ញុំនៅបានបែបន់សូមឲ្យមនុស្សទាំងអស់ក្នុងលោកកុំបីមានគំនិតមើលងាយមើលថោកដល់មនុស្សដូចគ្នា ហើយគួរតែក្រឡេកមើលមក «ជនពិការ» រាប់ម៉ឺនរាប់សែននាក់ដែលកំពុងតែរស់នៅយ៉ាងលំបាកវេទនាខ្លោចផ្សា មិនគួរណារើសអើងស្អប់ខ្ពើមក្រវាត់គ្នាចោលឲ្យរស់នៅយ៉ាងអានាថានោះឡើយ ព្រោះយ៉ាងហោចណាស់គ្នាក៏នៅមានឈ្មោះជាមនុស្សនៅមានជីវិត មានសាច់មានឈាមនៅស្គាល់ការឈឺចាប់ដូចយើងរាល់គ្នាដែរ ។

ក្រៅពីនោះខ្ញុំនៅមាន «ប្រាថ្នាម្យ៉ាង» គឺសូមឲ្យស្ត្រីជាភរិយាទាំងអស់ដែលមានប្ដីជាជនពិការដូចរូបខ្ញុំ ទោះជាពិការដោយសង្គ្រាម ឬដោយប្រការណាក៏ដោយ បានអានរឿង «រសាត់តាមខ្យល់» ដែលខ្ញុំបានខិតខំចងក្រងមកនេះ និងសូមឲ្យនាងសាងតែអំពើជាកុសល មានចិត្តអាណិតអាសូរមេត្តាករុណាចំពោះប្ដីរហូតជានិរន្តន៍ដូច «ស្រីរ័ត្ន» ឧត្តមភរិយាតែមួយរបស់ខ្ញុំ ។

**ប៉ុក ប៉ុនសូម៉ាង**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷


ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.dccam.org*

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ ញាណ សុជាតិ ទូរស័ព្ទលេខ ០៧០ ៩៨៨ ៦៦៦ ឬ អ៊ីម៉ែល ៖ truthsocheat@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 199, 2016 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.